ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Oct-2013, 15:51
CMS/CFO: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>លើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៦នាទី**

**សវនាការលើកទី២១៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយធ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*
លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក នីកូឡាស គូមជែន
*(Mr.Nicolas Koumjian)*
លោក សេង ប៊ុនឃាង
លោក វ៉េង ហ៊ីត់
លោក វីល្លៀម ស្មីត *(Mr. William SMITH)*
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*
លោក លោក ឃីត រេយ៍ន័រ
*(Mr. RAYRO Keith)*
លោក សាលីម ណាកចាវានី
*(Mr. Salim NAKHJAVANI )*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*
កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JAQUIN)*
លោកស្រី បេនី យេ*(Ms.Beini YE)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី ជេត វណ្ណលី

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*
លោក ស្រី អេឡូឌី ឌុយឡាក់
*(Ms.Elodie DULAC)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:២៤]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តផ្តល់នូវវេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សារបស់ខ្លួនលើសំណុំរឿង០០២/០១ ហើយជាបន្តនឹងបញ្ចប់នូវថ្ងៃនេះ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា លោកស្រី សែ កុលវុឌ្ឍីឡើងរាយការណ៍ស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះ និងអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ កត់សម្គាល់ផងដែរអំពីវត្តមានលោកស្រី អេឡូឌី ឌុយឡាក់ *(Ms.Elodie DULAC)* ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារួចហើយ។ ប៉ុន្តែមិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជម្រះសាលាដំបូងក្នុងរយៈពេលកន្លងមកនៅឡើយ។

ដោយឡែកនៅថ្ងៃនេះលោកមេធាវី ពេជ អង្គ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិអវត្ត-មានដោយមិនមានមូលហេតុ។ សូមអរគុណ។

[០៩:០៨:១៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ យ៉ាងម៉េចទៅលើស្រីមេធាវី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព ភាគីទាំងអស់ជាទីគោរព។ សហភាតារបស់ខ្ញុំ ពេជ អង្គ ហ្នឹងគាត់យឺតបន្តិច ហើយគាត់សូមអភ័យទោស។

បើសិនជាលោកប្រធានចង់ឲ្យ បើចង់ឲ្យគាត់តំណាងឲ្យមេធាវីដែលនៅខាងក្រោយខ្ញុំនេះអាចធ្វើបាន។ ខ្ញុំអាចតំណាងឲ្យតែធ្វើមេធាវីអន្តរជាតិទេខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណហើយ បាទអង្គុយចុះ!

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោក វីណ្ស្គៀម ស្មីត៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ដើមបណ្តឹងរដ្ឋប្បវេណី ភាគីនៅក្នុងបន្ទប់សវនាការ និងនៅខាងក្រៅ ហើយសួស្តី អរុណសួស្តីសាធារណជន ហើយនិងក៏សូមគោរពសួស្តីសាធារណជនដែលកំពុងតាមដានតាមរយៈទូរទស្សន៍ពីក្រៅប្រទេសផងដែរ។

លោក លោកស្រីចៅក្រមនៅក្នុងថ្ងៃនេះ យើងនឹងធ្វើការបង្ហាញសេចក្តីសន្និដ្ឋានរបស់យើងដោយបែងចែកជាបួនផ្នែក៖ ទី១) យើងនឹងធ្វើការបង្ហាញបញ្ចប់សេចក្តីសន្និដ្ឋានរបស់យើង ដើម្បី -- ដោយបង្ហាញអំពីរបៀបអំណាច និងសិទ្ធិរបស់បក្សដែលបានអនុវត្តក្នុង -- ដែលបានអនុវត្តដោយមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅមុន និងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ ទី២) យើងនឹងបង្ហាញអំពីតួនាទីរបស់ជនជាប់ចោទនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរចនាសម្ព័ន្ធអំណាចនៃកម្ពុជាប្រជាធិបតេយ្យ និងធាតុពិតនៃអត្តចរិតរបស់ពួកគេពីមុន និងបច្ចុប្បន្ន។ ទី៣) យើងនឹងបង្ហាញអំពីការចូលរួមរបស់បុគ្គលនីមួយៗគឺរបស់ នួន ជា, ខៀវ សំផន ដែលបានចូលរួមនៅក្នុងគោលនយោបាយឧក្រិដ្ឋហើយបង្កើតឲ្យមានឧក្រិដ្ឋកម្ម។ ចំណុចចុងក្រោយ យើងខ្ញុំនឹងធ្វើការស្នើសុំការដាក់ទោសទៅលើរូប នួន ជា និង ខៀវ សំផន ដែលពួកគាត់គួរតែទទួលបានទោសទៅតាមហ្នឹង ដោយសារការចូលរួមរបស់គាត់នៅឧក្រិដ្ឋកម្មដូចចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។

[០៩:១១:០៣]

លោកប្រធាន! កាលពីថ្ងៃសុក្រ យើងជិតបញ្ចប់អំពីសេចក្តីសន្និដ្ឋានលើភស្តុតាងនៅចំពោះមុខលោកចៅក្រមដែលបង្ហាញអំពីករណីដែលថាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាអនុវត្តអំណាច និងការគ្រប់គ្រងនៅតាមភូមិភាគរដ្ឋបាលនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ យើងបានបង្ហាញបានពាក់កណ្តាលអំពីរបៀបអំណាចនិងគ្រប់គ្រងលើភូមិភាគ ហើយដូចដែលយើងឃើញក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលក្នុងនោះបាន

ផ្តល់ការណែនាំទៅដល់សមាជិកបក្សអំពីការអនុវត្តមាគ៌ា និងគោលនយោបាយបក្ស។ យើងបានបង្ហាញឧទាហរណ៍មួយគឺទស្សនាវដ្តីទង់បដិវត្តចុះខែសីហា ឆ្នាំ១៩៧៧ ដែលក្នុងនោះចេញផ្សាយសុន្ទរកថាដោយតំណាងមជ្ឈិមបក្ស នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ នៅពេលធ្វើសន្និបាទកម្មាភិបាលភូមិភាគបស្ចិម។

លោក លោកស្រីចៅក្រមជាទីគោរព! យើងបានលើកឡើងសុន្ទរកថានេះជាច្រើនដងរួចមកហើយនៅក្នុងពេលជំនុំជម្រះ ដោយសារតែសុន្ទរកថានេះបានជម្រាបយើងនូវអ្វីដែលបានកើតឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ហេតុអ្វីបានជាប្រជាជនច្រើនត្រូវបានគេសម្លាប់? ហើយតើនរណាគេជាអ្នកទទួលខុសត្រូវ? តាមរយៈសុន្ទរកថានេះតែមួយគត់នោះ យើងអាចឃើញថាមេដឹកនាំបក្សគឺងប់ងល់ និងលើកបញ្ហាខ្មាំង ហើយជឿថា ៥០ភាគរយនៃប្រជាជននៅក្នុងភូមិភាគគឺមានសមាសភាពមិនល្អ ហើយ ១៥ ទៅ ២០ភាគរយគឺជាពួកក្បត់។ ដូច្នេះ តាមរយៈសុន្ទរកថានេះតែមួយប៉ុណ្ណោះ យើងអាចឃើញថាមេដឹកនាំបក្សគឺផ្តល់ការណែនាំជាហូរហែ និងជាដរាបឲ្យកម្ទេច ឲ្យវាយប្រហារ និងកម្ទេចខ្មាំង។

[០៩:១២:៥០]

លោកប្រធាន យើងត្រូវតែយល់ច្បាស់ ឬបញ្ជាក់ចំណុចច្បាស់តែម្តង។ នៅពេលនេះយើងមិនមែននិយាយអំពីខ្មាំងក្នុងពេលធ្វើសង្គ្រាមដែលកើតចេញពីការប៉ះទង្គិចគ្នារវាងកងទ័ពកម្ពុជា និងវៀតណាមនៅព្រំដែនខាងកើតនោះទេ។ ខ្មាំងទាំងអស់នេះគឺជាប្រជាជនកម្ពុជារបស់ នួន ជា និង ខ្មែរក្រហម ដែលពួកគាត់ទាំងពីរជឿជាក់ថា ត្រូវតែសម្លាប់ចោលដោយសារតែអ្នកទាំងអស់នោះចេញមកពីវណ្ណៈជាក់លាក់ ឬក៏ដោយសារតែពួកគេធ្វើការជាមួយនឹងអតីតរដ្ឋាភិបាលចាស់ ឬក៏ដោយសារតែពូជសាសន៍ផ្សេង។ មជ្ឈិមបក្សគឺវាយប្រហារទៅលើប្រជាជនខ្លួនឯង ដែលប្រជាជនទាំងអស់នោះមិនបានវាយប្រហារមកលើគាត់ផងនោះ។

លោក លោកស្រីចៅក្រម វាបានបង្ហាញហួសពីវិមតិសង្ស័យតាមរយៈភស្តុតាងថា ការកាប់សម្លាប់មិនអាចដាក់ស្តីបន្ទោសទៅស្តេចត្រាញ់តាមភូមិភាគស្វ័យតនោះទេ ដែលពួកគេធ្វើផ្ទុយនឹងគោលបំណង និងគោលនយោបាយរបស់មជ្ឈិមបក្ស។ មេដឹកនាំតំបន់ និងភូមិភាគគាត់ចូលរួមទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ពួកគេមិនមែនបំពេញការងារមិនស្វ័យតនោះទេ -- ពួកគេមិនមែនធ្វើការងារស្វ័យតនោះទេ ពួកគេកំពុងតែធ្វើការងារទៅតាមការចង់បានរបស់មជ្ឈិមបក្ស ហើយពួកគេអនុវត្តផែនការគោលនយោបាយឧក្រិដ្ឋដែលសម្រេច និងឯកភាពដោយមេដឹកបក្សទាំងអស់ពីមជ្ឈិម ពីភូមិភាគ ពីតំបន់ ពីថ្នាក់យោធា និងពីក្រសួងរបស់

កម្ពុជាប្រជាធិបតេយ្យ។

[០៩:១៤:៣៨]

នៅពេលនេះ ខ្ញុំសូមត្រឡប់ទៅបង្ហាញអំពីកិច្ចប្រជុំក្នុងកម្រិតខ្ពស់របស់គណៈអចិន្ត្រៃយ៍ ដែលស្ថាប័ននេះគឺមានការអនុវត្តអំណាចប្រចាំថ្ងៃថ្នាក់ខ្ពស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ កំណត់ហេតុកិច្ចគណៈអចិន្ត្រៃយ៍មួយចំនួនតូចមិនត្រូវបានកម្ទេចដោយខ្មែរក្រហមនោះទេ ហើយក៏វានៅសល់ផងដែរ។ កំណត់ហេតុទាំងអស់នេះបានបង្ហាញអំពី អំណាចរបស់មជ្ឈិមបក្សលើគ្រប់ទិដ្ឋភាពនៃកម្ពុជាប្រជាធិប-តេយ្យ។ នៅក្នុងកថាខណ្ឌ១៩១ និង ១៩២ នៃសេចក្ដីបញ្ចប់ការដេញដោលជាលាយលក្ខណ៍អក្សរ ក្រុមមេធាវីការពារក្ដី នួន ជា បានព្យាយាមបន្ថយសារៈសំខាន់នៃគណៈអចិន្ត្រៃយ៍ដោយអះអាងថា គឺវាលើកឡើងតែបញ្ហាទូទៅអរូបី ហើយនិងប្រឌិតតែប៉ុណ្ណោះ។ ជាថ្មីម្ដងទៀត វិធីតែមួយគត់ក្នុងការបង្ហាញការលើកឡើងខុសរបស់មេធាវីការពារក្ដីនេះគឺ យើងត្រូវមើលឧទាហរណ៍មួយចំនួននៃកំណត់ហេតុគណៈអចិន្ត្រៃយ៍។ កំណត់ហេតុគណៈអចិន្ត្រៃយ៍ដំបូងបំផុតដែលនៅសល់ គឺកំណត់ហេតុនៃទស្សនកិច្ចទៅភូមិភាគបស្ចិមនៅក្នុងខែសីហា ឆ្នាំ៧៥។ ខ្ញុំនឹងបង្ហាញអំពីទស្សនកិច្ចនេះក្នុងលក្ខណៈលម្អិតជាងមុននាពេលក្រោយ។ ក៏ប៉ុន្តែនៅពេលនេះខ្ញុំសូមដកស្រង់សេចក្ដីសម្រេចមួយចំនួនដែលធ្វើឡើងដោយគណៈអចិន្ត្រៃយ៍នៅក្នុងពេលនោះដែលចំណុចនេះវាបង្ហាញការលើកឡើងរបស់មេធាវីខុស។ ប្រសិនបើយើងមើលផ្នែកពីរ (១)(ខ) នៃកំណត់ហេតុនេះដែល ក្នុងនោះមានចំណងជើងថា "វិធានការជាក់លាក់មួយចំនួន គណៈអចិន្ត្រៃយ៍បានផ្ដល់ការណែនាំដូចខាងក្រោម: ថាតើត្រូវការពារព្រំដែនយ៉ាងម៉េចជាមួយប្រទេសថៃ"។ ខ្ញុំសូមដកស្រង់៖ "ផ្នែកអាវុធត្រូវជ្រើសរើសហើយអាវុធទំនើបនិងចាស់ត្រូវប្រើប្រាស់ រួមទាំងចម្រោងនៅតាមព្រំដែន។ ធ្វើផែនការអំពីការប្រើប្រាស់ចម្រោងទាំងអស់នោះក្នុងរយៈពេលមួយខែ គ្រប់ប្រភេទនៃចម្រោងទាំងអស់ត្រូវតែប្រើប្រាស់ឲ្យចំបាតជើង ខ្នងជើង ស្មងជើង រហូតដល់ពោះ"។

[០៩:១៦:៥៧]

លោក លោកស្រីចៅក្រម! មេធាវីការពារក្ដីបង្ហាញថា គណៈអចិន្ត្រៃយ៍គឺជាស្ថាប័នដែលលើកឡើងតែអំពីបញ្ហាអរូបីទូទៅ ឬក៏កម្រិតខ្ពស់។ ការលើកឡើងនេះគឺជាការលើកឡើងមិនត្រឹមត្រូវអំពីអង្គហេតុ។ នៅក្នុងឱកាសជាច្រើនមេដឹកនាំមជ្ឈិមបក្សបានសម្រេចអំពីជោគវាសនារបស់បុគ្គលទាំងឡាយ។ ពួកគេបានធ្វើសេចក្ដីសម្រេចជាក់លាក់ ហើយដែលនាំឲ្យមានការស្លាប់ប្រជាជនរាប់ម៉ឺនរាប់សែននាក់។ ពួកគាត់ទាំងអស់គឺជាបងធំ ដែលរៀបចំធ្វើការត្រួតត្រា និងកំណត់អំពីគ្រប់ទិដ្ឋភាពនៃជីវិតប្រជាជន

ដើម្បីសម្រេចគោលបំណងបដិវត្តន៍របស់ពួកគេ។ មានឧទាហរណ៍ជាច្រើនតាមរយៈភស្តុតាងនៅចំពោះមុខលោក លោកស្រីចៅក្រមបង្ហាញអំពីចំណុចនេះ។ នៅពេលដែលយើងមើលកំណត់ហេតុដដែលនេះពីខែសីហា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍ផ្តល់ ការណែនាំដូចខាងក្រោមអំពីទីក្រុង ដែលការពីពីរបីខែមុនពួកគេបានបញ្ជាឲ្យធ្វើការជម្លៀស។ ខ្ញុំសូមដកស្រង់៖ "ទីក្រុងយើងត្រូវតែថែទាំមើលការខុសត្រូវ ផ្ទះឈើតូចៗត្រូវតែរុះរើតាមសំណើ ទោះបីជាយើងត្រូវប្រើប្រាស់កម្លាំងចាត់តាំងខ្លះឲ្យទៅរុះរើនោះក៏ដោយ។ អង្គការស្នើថា ផលដំណាំយុទ្ធសាស្ត្រ ដូចជា ដើមដូងត្រូវតែដាំនៅក្នុងទីក្រុង។ ហើយនៅកន្លែងខ្លះអង្គការស្នើថាកុំឲ្យដាំដើមចេក ដោយសារតែដើមចេកទាំងអស់នោះវាធ្វើឲ្យខូចសោភ័ណភាពទីក្រុង"។ ដូចដែលបានបង្ហាញនៅក្នុងកំណត់ហេតុកិច្ចប្រជុំ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ៧៥ គណៈអចិន្ត្រៃយ៍គឺជាអ្នកសម្រេចថាតើត្រូវកសាងវាលយន្តហោះយោធាថ្មីនៅទីណា? ហើយត្រូវតម្លើងស្ថានីយ៍វិទ្យុរ៉ាដានៅកន្លែងណា? កំណត់ហេតុទាំងអស់នេះក៏រួមមានសេចក្តី សម្រេចដូចខាងក្រោម និងការណែនាំផងដែរ។ ខ្ញុំសូមដកស្រង់៖ "មាគ៌ាដែលសំខាន់មួយគឺកងទ័ពជើងគោក ហើយយើងត្រូវផ្តោតសំខាន់ទៅលើរោងចក្រផលិតអាវុធ គ្រាប់ និងមីន។ នៅពេលនោះផងដែរយើងត្រូវតែមានរថក្រោះខ្លះ ឧទាហរណ៍នៅរតនគីរីមានកាំភ្លើងមួយដើមក្នុងមួយភូមិ នៅក្នុងបីបួនឆ្នាំ ខាងមុខយើងឲ្យមានប្រជាជន ១០០.០០០ ទៅ២០០.០០០ នាក់។ ចំពោះកាំភ្លើងបាញ់មួយគ្រាប់ឲ្យចំគោលដៅមួយៗតែម្តង។

[០៩:១៩:៥៥]

លោក លោកស្រីចៅក្រម! ប្រសិនបើយើងមើលកំណត់ហេតុគណៈអចិន្ត្រៃយ៍ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ៧៦ អំពីបញ្ហាសេដ្ឋកិច្ច ដែលក្នុងនោះមានបញ្ជីអ្នកចូលរួមបានបង្ហាញថា នួន ជា និង ខៀវ សំផន បានមានវត្តមានចូលរួម។ នៅពេលនោះសេចក្តីសម្រេចជាក់លាក់ និងជាក់ស្តែងត្រូវបានធ្វើឡើង ក្នុងរួមទាំងបង្កើនផលិតផលអំបិលពី៥០.០០០ទៅ៦០.០០០តោន ហើយនិងយកក្មេងតូចៗបន្ថែមពីតាមមូលដ្ឋានផ្តល់ទៅឲ្យឧស្សាហកម្មដើម្បីគ្រប់គ្រង។ គណៈអចិន្ត្រៃយ៍ក៏បានសម្រេចនៅក្នុងពេលប្រជុំនោះផងដែរ អំពីរបៀបធ្វើការចែកចាយអំណោយស្រូវរបស់ចិនដែលទទួលបាន។ ខ្ញុំសូមដកស្រង់៖ "បញ្ជូនស្រូវទៅមិត្តមុត ៥០០០ការុង, ទៅកោះកុង ២០០០ការុង, តំបន់២៥ ១០.០០០ការុង ហើយចំពោះចំនួនដែលនៅសល់ ប្រើប្រាស់នៅក្នុងក្រុងភ្នំពេញ"។

នៅពេលនេះ យើងមើលកំណត់ហេតុគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ៧៦ ដែលក្នុងនោះមេដឹកនាំបក្សមកពីសៀមរាប ព្រះវិហារ និងភូមិភាគឧត្តរ បានរាយការណ៍អំពីសភាពការណ៍ខ្លាំងនៅ

តំបន់របស់ពួកគេ។ ការណែនាំដូចខាងក្រោម បានធ្វើឡើងដើម្បីថាត្រូវធ្វើយ៉ាងណាជាមួយនឹងអ្នកដែលត្រូវបានគេសង្ស័យនៅភូមិភាគឧត្តរ។ ខ្ញុំសូមដកស្រង់៖ “សួរចម្លើយពួកវា ហើយទុកពួកគេមួយឡែក។ បន្ទាប់មករាយការណ៍ទៅថ្នាក់លើ រួមជាមួយនឹងឯកសារទៅជាមួយផង”។ បញ្ចប់ការដកស្រង់។

[០៩:២១:៣០]

នៅក្នុងកិច្ចប្រជុំនេះដែរ មេដឹកនាំបក្សធ្វើសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងចំនួនស្រូវ អង្ករ ដែលអង្គការត្រូវយកពីតំបន់ទាំងអស់នេះ ហើយនិងការប្រើប្រាស់ទឹកក្នុងចំណោមស្រុកនានានៅក្នុងតំបន់សៀមរាប។ ពិសេសក្នុងនោះបានយោងទៅលើគោលបំណងក្នុងឆ្នាំ១៩៧៥ ក្នុងការនាំចេញស្រូវយ៉ាងហោចណាស់ ១០០.០០០តោន សម្រាប់ការលក់ពីតំបន់នោះ។ តំណាងបួនរូបមកពីមជ្ឈិមបក្សមានវត្តមានចូលរួមក្នុងកិច្ចប្រជុំនោះ ក្នុងនោះរួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន និង ឌឿន។ ប្រាំថ្ងៃក្រោយមក នៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ធ្វើឡើងនៅល្ងាចថ្ងៃ១៣ ខែមីនា ឆ្នាំ៧៦ ពាក់ព័ន្ធទៅនឹងការលាលែងពីតំណាងរបស់សម្ដេច សីហនុ។ ចូលរួមនៅក្នុងនោះ មាន ខៀវ សំផន, នួន ជា។ មេដឹកនាំក៏បានសម្រេចថា ទុកឲ្យសម្ដេច សីហនុ នៅរស់ ក៏ប៉ុន្តែមិនអនុញ្ញាតឲ្យទ្រង់ចាកចេញពីប្រទេសនោះឡើយ។ ចំពោះកូនចៅរបស់សម្ដេច សីហនុ មេដឹកនាំបានសម្រេចថាធ្វើយ៉ាងណាព្យាយាម អូសទាញកូនចៅរបស់សម្ដេចដើម្បីឲ្យចូលប្រទេសយកមកសម្លាប់ចោល។ ខ្ញុំសូមដកស្រង់៖ “បញ្ជូនដំណឹងទៅកាន់កូនចៅរបស់សម្ដេចឲ្យមកជាបន្ទាន់ ដោយពន្យល់ថា ឲ្យកូនចៅរបស់សម្ដេចមកចូលរួមការប្រារព្ធពិធីចូលឆ្នាំនិងពិធីឯករាជ្យ។ យើងចង់ដោះស្រាយបញ្ហានេះឲ្យបានស្អាត ឲ្យជ្រះស្រឡះ។ យើងត្រូវដោះស្រាយដូច្នេះ ដើម្បីជាប្រយោជន៍នៃបដិវត្តរបស់យើង”។ បញ្ចប់ការដកស្រង់។

[០៩:២៣:១៤]

លោក លោកស្រីចៅក្រមជាទីគោរព! កំណត់ហេតុទាំងអស់នោះក៏បានកត់សម្គាល់ថា ដោយសារសេចក្ដីសម្រេចទាំងអស់នោះ ពាក់ព័ន្ធទៅនឹងបញ្ហាសំខាន់ៗ។ សេចក្ដីសម្រេចចុងក្រោយលើបញ្ហាទាំងអស់នេះ គឺជាសេចក្ដីសម្រេចទុកឲ្យមជ្ឈិមជាអ្នកធ្វើ។ បានន័យថា ទុកឲ្យគណៈមជ្ឈិមទាំងមូលជាអ្នកសម្រេចជាសមូហភាព។ ឧទាហរណ៍មួយទៀតនៃការកសាងសង្គម ឬវប្បធម៌របស់សង្គមកម្ពុជា គឺផ្ដួងផ្ដើមដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ យើងអាចមើលឃើញនៅក្នុងកំណត់ហេតុកិច្ចប្រជុំចុះថ្ងៃ០១ ខែមិថុនា ឆ្នាំ៧៦។ កិច្ចប្រជុំជាមួយនឹងតំណាងក្រសួងឃោសនាការ ដែលនៅពេលនោះ នួន ជា បានណែនាំថា “ពាក្យមួយចំនួនជាក់លាក់ ត្រូវតែដកចេញពីចម្រៀងដែលចាក់ផ្សាយក្នុងវិទ្យុ រួមមាន

ពាក្យដូចជា “បវរ” ដែលបានន័យថា ស្អាតបំផុត, “ពណ្ណរាយ” ពោរពេញទៅដោយពណ៌ ហើយនិងសុខមាលភាព ត្រូវតែដកចេញ។ ពាក្យទាំងអស់នេះ គឺស្តាប់ទៅស្រដៀង ឬក៏ដូចគ្នាទៅនឹងពាក្យដែលប្រើប្រាស់ក្នុងរបបចាស់”។ ប៉ុល ពត បានបង្ហាញការយល់ស្របរបស់គាត់ជាមួយនឹង នួន ជា ដែលស្នើសុំថាឲ្យដកបទចម្រៀងមួយទៀតចេញផងដែរ។ ដោយសារតែផ្នែកនៅក្នុងចម្រៀងនោះ ដកស្រង់ចេញចង្វាក់នៅក្នុងរបបសង្គមសីហនុ ហើយណែនាំក្រសួងមិនឲ្យផ្សាយបទចង្វាក់ទាំងចាស់ៗទាំងអស់នោះទេ ដោយសារតែវាប៉ះពាល់ទៅដល់ការអូសទាញរបស់បក្ស។ នេះជាកម្រិត និងវិសាលភាពដែលមេដឹកនាំមជ្ឈិមបក្សគ្រប់គ្រងជីវិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[០៩:២៥:០៦]

ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំគ្នាអចិន្ត្រៃយ៍ កំណត់ហេតុដែលនៅសល់កត់ត្រាបង្ហាញថា ខៀវ សំផន ចូលរួមជាទៀងទាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ អង្គហេតុដែលគាត់បានទទួលស្គាល់នៅពេលដែលគាត់សួរចម្លើយដោយសហចៅក្រមស៊ើបអង្កេត។ ក្នុងចំណោមកំណត់ហេតុគណៈអចិន្ត្រៃយ៍ ១៩ដែលនៅសល់ ក្នុងនោះកត់ត្រាទុកវត្តមានអ្នកចូលរួម ខៀវ សំផន មានវត្តមាន១៦ដង នៅក្នុងកិច្ចប្រជុំទាំងអស់នោះ បើគិតជាភាគរយៈ គឺបានន័យថា៨៤ភាគរយ។ នៅក្នុងសារណាចុងក្រោយរបស់ពួកគេត្រង់កថាខណ្ឌ២៥៩ ដល់ ២៧៧ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសន្និដ្ឋាន ដោយផ្អែកលើភស្តុតាងថា កូនក្តីរបស់គាត់ចូលរួមកិច្ចប្រជុំតែបួនភាគរយ តែប៉ុណ្ណោះនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលទំនងបានប្រជុំនៅក្នុងពេញអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ បានន័យថា ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះជឿជាក់ថា ដោយសារតែភាពបត់បែននិងភាពចៃដន្យ ក្នុងចំណោមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ២០០ ឬក៏ ៣០០នោះ ដែលកំណត់ហេតុទាំងអស់ត្រូវបានកម្ទេចចោល។ កិច្ចប្រជុំទាំងអស់នោះហើយដែលគាត់មិនបានចូលរួមនោះទេ។ ការសន្និដ្ឋានដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី មិនមែនជាការសន្និដ្ឋានមួយសមហេតុផលនោះទេ ដូច្នេះអង្គជំនុំជម្រះត្រូវតែច្រានចោល។

[០៩:២៦:៤៦]

នៅពេលដែល ខៀវ សំផន ទទួលស្គាល់ជូនចៅក្រមស៊ើបអង្កេតថា គាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍, ខៀវ សំផន មិនបានបញ្ជាក់ថា គាត់ចូលរួមកិច្ចប្រជុំទាំងអស់នោះក្នុងរយៈពេលមួយជាក់លាក់នោះទេ។ គាត់បានបង្ហាញឆ្លើយអំពីភាពញឹកញាប់អំពីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍និងទីតាំងដែលកិច្ចប្រជុំទាំងអស់នោះធ្វើឡើង។ ដោយមិនបានកំណត់លក្ខណៈលើកឡើងថាការចូលរួមរបស់គាត់

និងការដឹងឮអំពីកិច្ចប្រជុំទាំងអស់នោះ មានលក្ខណៈកម្រិតនោះទេ។

លោក លោកស្រីចៅក្រមជាទីគោរព! សេចក្តីសន្និដ្ឋានសមហេតុតែមួយគត់ចេញពីសក្ខីកម្មរបស់ ខៀវ សំផន និងភាគរយខ្ពស់នៃកិច្ចប្រជុំដែលគាត់ចូលរួមនៅក្នុងកំណត់ហេតុដែលនៅសល់ គឺ១៦ក្នុងចំណោម១៩នៃកិច្ចប្រជុំ បង្ហាញថា ខៀវ សំផន គឺជាអ្នកចូលរួមយ៉ាងទៀងទាត់មួយរូបនៅក្នុងពេលកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពេញអំឡុងកម្ពុជាប្រជាធិបតេយ្យ។

លោក លោកស្រីចៅក្រមជាទីគោរព! មុនពេលដែលខ្ញុំចូលទៅដល់ផ្នែកបន្ទាប់នៃឯកសារបង្ហាញរបស់ខ្ញុំ ដែលក្នុងនោះនឹងលើកឡើងអំពីអត្តចរិត និងតួនាទីរបស់ជនជាប់ចោទទាំងពីរ ខ្ញុំសូមចង្អុលបញ្ជាក់អំពីអង្គហេតុចំនួនពីរផ្សេងទៀត ឬក៏ភស្តុតាងដែលបង្ហាញថា១ ការគ្រប់គ្រងរបស់មជ្ឈិមបក្សនៅតាមភូមិភាគ ហើយភស្តុតាងទាំងអស់នោះក៏ច្រានចោលការលើកឡើងរបស់មេធាវីការពារក្តីអំពីស្វ័យភាពនៃភូមិភាគនោះគឺជាការលើកឡើងខុស។ សួន កានិល និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា, គឺគាត់បានដឹងអំពីរចនាសម្ព័ន្ធទំនាក់ទំនង, បានលើកឡើងថា៖ “ភូមិភាគមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនិងការទាក់ទងដោយផ្ទាល់ជាមួយនឹងភូមិភាគផ្សេងទៀតនោះទេ។ ក៏ប៉ុន្តែ ត្រូវតែមានការទំនាក់ទំនងផ្ទាល់តាមរយៈមជ្ឈិម។ សួន កានិល ធ្វើការនៅក្នុងមន្ទីរសារទូរលេខភូមិភាគកណ្តាល ហើយបានឆ្លើយជូនអង្គជំនុំជម្រះថា៖ “គ្មានការទំនាក់ទំនងសារទូរលេខណាមួយធ្វើឡើងរវាងភូមិភាគនោះទេ។ លើកលែងតែមានការអនុញ្ញាតពីមន្ទីរ៨៧០” បញ្ចប់ការដកស្រង់។ សក្ខីកម្មនេះ គឺមានភាពស៊ីសង្វាក់ជាមួយនឹងសារទូរលេខដែលនៅសល់មួយចំនួនច្រើន ដែលក្នុងនោះមន្ទីរភូមិភាគស្នើសុំជាក់លាក់ពីមន្ទីរ៨៧០ ឲ្យផ្តល់ព័ត៌មានបន្តទៅឲ្យភូមិភាគដទៃទៀត។ ការហាមឃាត់របស់មជ្ឈិមបក្សនៅលើបញ្ហាជ្រៀតជ្រែក ឬក៏ការជូនដំណឹងរវាងភូមិភាគនោះ គឺវាបានបង្ហាញជំទាស់ទៅលើការអះអាងរបស់ក្រុមមេធាវីការពារក្តីថា ភូមិភាគមិនត្រូវបានអនុញ្ញាតឲ្យធ្វើការដោយស្វ័យត។

[០៩:២៩:៣៦]

ចំណុចចុងក្រោយ លោក លោកស្រីចៅក្រម នៅចាំអំពីសក្ខីកម្មរបស់លេខាតំបន់ស្វ័យតដែលរាយការណ៍ដោយផ្ទាល់ទៅមេដឹកនាំបក្សនៅក្នុងទីក្រុងភ្នំពេញ គឺ សៅ សារុន ដែលជាលេខាតំបន់១០៥ គាត់ជាសាក្សីដែលបង្ហាញអំពីភស្តុតាងផ្ទាល់អំពីទំនាក់ទំនងរវាងមជ្ឈិមបក្ស និងអង្គការតំបន់។ សៅ សារុន ផ្តល់សក្ខីកម្មថា អំណាចពីមជ្ឈិមបក្សតម្រូវឲ្យមានដើម្បីឲ្យដោះលែងអ្នកជាប់ឃុំនៅក្នុងករណីដែលពាក់ព័ន្ធទៅនឹងនយោបាយនិងការកត់បក្ស។ ឧទាហរណ៍គឺពាក់ព័ន្ធនឹងបុគ្គលដែលឃុបឃិតជាមួយ

នឹងពួកឈ្លានពានយួន ឬក៏ខ្មាំង។ លោក សៅ សារុន រៀបរាប់អំពីកិច្ចប្រជុំនៅក្នុងទីក្រុងភ្នំពេញជាមួយ នឹង ប៉ុល ពត, នួន ជា, ខៀវ សំផន និងសុន សេន ដែលនៅពេលនោះគឺ សៅ សារុន គាត់កត់ត្រាអំពី ស្ថានភាពនៅក្នុងតំបន់។ ហើយគាត់ទទួលការណែនាំពីមេដឹកនាំមជ្ឈិមបក្ស។ គាត់ក៏បានរៀបរាប់អំពី ឱកាសមួយដែលនៅពេលនោះ គាត់ជាមួយនឹងមេដឹកនាំដទៃផ្សេងទៀតត្រូវបានគេកោះឲ្យមកប្រជុំនៅ ក្នុងក្រុងភ្នំពេញ។ ហើយកម្មាភិបាលតំបន់១០៥ នៅក្នុងក្រុមរបស់គាត់ត្រូវបានគេចាប់ខ្លួនភ្លាមតែម្តងនៅ ពេលដែលមកដល់អាកាសយានដ្ឋានពោធិ៍ចិនតុង។

លោក លោកស្រីចៅក្រម នេះជាអង្គហេតុដែលបញ្ជាក់អំពីអំណាចរបស់ នួន ជា, ខៀវ សំផន ហើយនិងសមាជិកផ្សេងទៀតរបស់មជ្ឈិមបក្ស។ អង្គហេតុដែលបង្ហាញថាពួកគាត់ដឹង ហើយនិងការ ត្រួតត្រារបស់គាត់លើហេតុការណ៍ទាំងអស់នៅក្នុងភូមិភាគនៅតំបន់នៃកម្ពុជាប្រជាធិបតេយ្យ។

[០៩:៣១:៣៤]

លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំនឹងចូលទៅភស្តុតាងនៃអំពីតួនាទីរបស់ នួន ជា ហើយនិងខៀវ សំផន ដែលគាត់បានអនុវត្តមុនក្នុងអំឡុង និងបន្ទាប់មានការចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយនិងអត្តចរិតរបស់ពួកដែលសម្តែងនៅក្នុងសម័យនោះ។ យើងសូមបញ្ជាក់ថាពីភស្តុតាងពីតួនាទី ហើយនិងអត្តចរិតរបស់គាត់ដែលផ្តល់អំពីភស្តុតាងដ៏សំខាន់ក្នុងការយល់ពីបង្ហាញ៖ ១) អំពីកម្រិតនៃ ការចូលរួមនៅក្នុងគោលនយោបាយឧក្រិដ្ឋ ហើយនិងលទ្ធផលនៃបទឧក្រិដ្ឋនោះ។ ២) អំពីកម្រិតនៃ ចេតនារបស់ពួកគាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋឲ្យកើតឡើង ហើយនិង៣) ថាតើលោក លោកស្រីចៅក្រម គួរជឿការដោះសាររបស់គាត់ថា ពួកគាត់មិនបានចូលរួមនៅក្នុងបទឧក្រិដ្ឋនេះដែរឬទេ?

ខ្ញុំនឹងចាប់ផ្តើមជាមួយនឹងការវិភាគភស្តុតាងដែលទាក់ទងទៅនឹងលោក នួន ជា។ នួន ជា តើនួន ជា ជាអ្នកណា? តើគាត់បានតំណាងឲ្យអ្វី តើគាត់តំណាងឲ្យអ្វី?

នៅក្នុងការជំនុំជម្រះនេះ យើងបានស្តាប់មេធាវីការពារក្តីខ្មែររបស់លោក នួន ជា សួរសាក្សីថា គាត់ជាមនុស្សធម្មតាដែលស្រឡាញ់ប្រទេសរបស់គាត់ ឬតើគាត់ជាជនឃោរឃៅសាហាវដែលបំពាន ដែលធ្វើទារុណកម្មអ្នកដែលនៅជុំវិញគាត់ឬទេ? សំណួរដែលសួរដោយលោក សុន អរុណ ទំនងជាធ្វើ ឲ្យយើងមិនជម្រើសអ្វីមានប្រយោជន៍ទេ។ ប៉ុន្តែតាមពិតមនុស្សលោកគឺមានលក្ខណៈស្មុគស្មាញជាងសត្វ លោកបែបនេះឆ្ងាយណាស់។ យើងមានកម្រិតយល់ដឹងខុសៗគ្នា ហើយយើងមានមុខមាត់នៃឃាតករ ពេលខ្លះយើងពិបាកនឹងមើលឃើញ។ អ្នកដែលទទួលខុសត្រូវក្នុងកាប់សម្លាប់ទ្រង់ទ្រាយធំកម្រនឹងបង្ហាញ

មុខដ៏ងងឹងរបស់ពួកគាត់គេជាសាធារណណាស់។ ឃាតករតែងតែជាមនុស្សដែលបានជួបអ្នកដទៃក្នុងជីវិតធម្មតា។ ប្រវត្តិសាស្ត្របានបង្រៀនយើងថា មេដឹកនាំនយោបាយអាចនឹងប្រកបវិជ្ជាជីវៈជាអ្នកស្រឡាញ់ប្រទេសខ្លាំងណាស់។ ប៉ុន្តែអាចជាអ្នកឃោរឃៅក្នុងបទឧក្រិដ្ឋដ៏អាក្រក់នោះដែរ។ ដូច្នេះ តើ នួន ជា ជាអ្នកណា?

[០៩:៣៤:០៧]

នៅពេលដែល ថេត សម្បត្តិ បានសួរគាត់ថាតើគាត់មានការទើសទាល់ក្នុងចិត្តនៅពេលដែលមានការកាប់សម្លាប់អតីតសមមិត្ត ហើយនិងមិត្តភក្តិរបស់គាត់នោះ? នួន ជា គាត់បាននិយាយដូច្នេះថា សូមដកស្រង់៖ "បក្សបានសម្រេចសម្លាប់គេចោលពីព្រោះពួកគេក្បត់បក្ស ហើយនិងក្បត់ជាតិ ហើយខ្ញុំមិនមានការសោកស្តាយឬភ័យទេនៅពេលដែលគេសម្លាប់អ្នកទាំងនោះ ពួកគេធ្វើខុស ហើយពួកគេក្បត់យើង។ ដូច្នេះគេបានទទួលអ្វីដែលគេសមនឹងទទួលហើយ។ យើងធ្លាប់ជាមិត្តភក្តិ ប៉ុន្តែមិត្តភាព ហើយនិងការងារនយោបាយគឺវាខុសគ្នា"។ សូមបញ្ចប់សេចក្តីដកស្រង់។

លោក លោកស្រីចៅក្រម នួន ជា បានសម្តែងនូវទស្សនៈ ហើយនិងមនោសញ្ចេតនាទទួលស្គាល់ដើម្បីធ្វើយុត្តិកម្មការកាប់សម្លាប់ប្រជាជនក្រៅផ្លូវតុលាការដោយបក្សកុម្មុយនីស្តកម្ពុជា ដែលគេយល់ថាជាពួកជនក្បត់របស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងវីដេអូ -- បទសម្ភាសន៍វីដេអូដូចខាងក្រោមនេះ ដែលខ្ញុំនឹងសូមអនុញ្ញាតតុលាការ ដើម្បីបញ្ចាំងជូន។

[០៩:៣៥:១៩]

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ស៖ កម្មាភិបាលយើង ពួកក្បត់ៗហ្នឹង សមៗទទួលក្នុងការស្លាប់អ៊ីចឹងទេបាទ? សូមអ៊ំបកស្រាយ? ឆ៖ ទេ ខ្ញុំមិនប៉ានថាទេ ពីព្រោះបើថាទៅ គេថាឯងឃោរឃៅ ប៉ុន្តែយើងមើល ទៅមើលអ៊ីចេះ សមមិនសម មើលគ្រោះថ្នាក់របស់ជាតិប៉ុនណា កុំឲ្យមើលពីបុគ្គល។ បើពួកអស់ហ្នឹងនៅ គ្រោះថ្នាក់របស់ជាតិប៉ុនណា។ ត្រូវមើលអ៊ីចឹងបានឃើញ មើលទាំងពីរ អានេះនៅនឹងទស្សនៈ ទំហំវាប៉ុនណា។ គ្រោះថ្នាក់មិនតិចទេណ៎ា មិនមែនតូចតាចទេ មិនមែនរឿងធម្មតា មិនមែនរឿងបាត់បង់ទឹកដីមួយចំអាមពីរចំអាមឯណា រឿងបាត់បង់ទឹកដីប្រទេសកម្ពុជាមួយទាំងមូល។ ហើយបាត់បង់រហូតរាប់សតវត្សរ៍មិនងាយរើទេ ជឿខ្ញុំទៅបើពួកហ្នឹងនៅ។ រាប់សតវត្សរ៍ណ៎ា កូនចៅយើងជំនាន់ក្រោយវាទៅជាស្អី រូបភាពជាខ្មែរប៉ុន្តែខ្លឹមសារវាជាស្អី អាហ្នឹងយើងត្រូវថ្លឹងមើល អាហ្នឹងបានប៉ានវិនិច្ឆ័យថាការដោះស្រាយ*

*ហ្នឹងត្រូវ។ ប៉ុន្តែបើមិនមើលឲ្យទូលាយទេ មើលឃើញចង្អៀត ឃើញពីរឿងអាណិតអាសូរគ្នាអីគ្នាអាហ្នឹងអត់ទេ ប្រទេសជាតិទៅហើយៗ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៣៥:៥៣]

លោក លោកស្រីចៅក្រម ដើម្បីឆ្លើយតបទៅនឹងសំណួរថា តើនរណាជា នួន ជា នោះ? គឺថា គាត់ជាជនជ្រុលនិយម ដែលមានចេតនាកាប់សម្លាប់ដោយខុសច្បាប់នូវអ្នកដទៃទៀត ដើម្បីសម្រេចបាននូវទស្សនះរបស់គាត់ និងរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់ជាជនជ្រុលនិយមក្នុងឆ្នាំ១៩៧០ នៅពេលដែលគាត់ជាមនុស្សនៅលំដាប់ទី២ ជាបងទី២ នៃបក្សកុម្មុយនីស្តកម្ពុជា ហើយនិងជាមេដឹកនាំដែលដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ តាមការវិនិច្ឆ័យទៅនឹងចម្លើយរបស់គាត់ក្នុងការជំនុំជម្រះនេះ ហើយនិងការការពារដោយមេធាវីរបស់គាត់នោះ គាត់នៅតែជាជនជ្រុលនិយមដដែលរហូតដល់ថ្ងៃនេះ។ គាត់ជាមនុស្សឃោរឃៅដែលយល់ថា ចក្រពត្តិនិយមបរទេស, សេ.អ៊ី.អា, កា.ហ្សេ.បេ ហើយនិងគិញ្ញៀតណាមគឺបង្កប់នៅគ្រប់កន្លែងទាំងអស់ គឺជាបុរស។ នៅពេលដែលយើងសួរអំពីថា គ្មានមនុស្សធម៌នៅកម្ពុជាប្រជាធិបតេយ្យនោះ គាត់និយាយថា សូមដកស្រង់៖ “សិទ្ធិមនុស្សខ្ពស់បំផុត គឺសារៈសំខាន់នៃសិទ្ធិមនុស្សនោះ គឺត្រូវកាន់អាចវុធដើម្បីប្រយុទ្ធនឹងខ្មាំង” សូមបញ្ចប់សេចក្ដីដកស្រង់។ គាត់បានបដិសេធថា “សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ គឺមិនមែនជាសិទ្ធិធម្មតាទេ។ គាត់ជាបុរសដែលមានចេតនាសម្លាប់បងប្អូនខ្លួនឯង បងប្អូនបដិវត្តន៍ ដែលប្រយុទ្ធជាមួយគាត់អស់រយៈ១៥ឆ្នាំ ហើយបើមានការសង្ស័យ ហើយពួកគេមិនមានស្វាមីភក្តិ១០០ភាគរយទេ។ គាត់ជាជនជ្រុលនិយមដល់ខ្លឹមសារដែល ប៉ុល ពត ក៏យល់ឃើញថា គាត់ជាមនុស្សរឹងមាំខ្លាំងពេក” សូមបញ្ចប់សេចក្ដីដកស្រង់។

[០៩:៣៨:៥១]

លោក លោកស្រីចៅក្រម! គឺមានការគំរាមកំហែងដ៏ខ្លាំងទៅលើមនុស្សជាតិ ដែលថាគេមិនបើកភ្នែកមើលទេដោយផ្អែកលើតែមនោគមន៍វិជ្ជា ឬក៏ជំនឿសាសនា ហើយគេធ្វើអ្វីគ្រប់បែបយ៉ាងទាំងអស់ ទោះបីមានការខាតបង់ខុសច្បាប់យ៉ាងណាក្ដី គេត្រូវតែធ្វើដើម្បីសម្រេចគោលដៅ។ គេយកគោលដៅជាកត្តាសំខាន់ ចម្លងតាមស្តាលីននិយម ម៉ាក្សឡេនីននិយម ប៉ុន្តែគេមិនអាច -- ភាគច្រើនមិនអាចទទួលយកបាននៅក្នុងសង្គមទំនើបនោះទេ។ នួន ជា ជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គាត់និយាយថា “ទិសដៅសំខាន់អ្វីទាំងអស់” នេះជាមាគ៌ាបក្សដែលបានរៀបចំដោយ នួន ជា ប៉ុល ពត ហើយនិងសម្រេច

ដោយសមាជបក្ស។ គោលនយោបាយដែលបញ្ជាក់ផ្តល់អំណាចទាំងស្រុងគឺថាជាមធ្យោបាយខុសច្បាប់ គឺហិង្សាបដិវត្តន៍គឺជាមូលដ្ឋានសំខាន់នៃការតស៊ូ។

លោក លោកស្រីចៅក្រម គឺផ្អែកតាមគំនិតជ្រុលនិយមនេះហើយដែល នួន ជា ហើយនិងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានឆ្លងកាត់ពីបន្ទាត់មួយអំពីអ្នកនិយមជាតិនិយម ឆ្វេងនិយមដើម្បីប្រទេសជាតិ ហើយក្លាយទៅជាឧក្រិដ្ឋជនដែលនាំឲ្យប្រជាជនស្លាប់រាប់រយ រាប់ពាន់នាក់។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកោតសរសើរ ស្តាលីន ហើយនិងម៉ៅ ហើយយល់ថា គេនឹងយកអ្នកទាំងនោះជាគំរូនៅក្នុងបដិវត្តន៍កុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែនៅក្នុងគំនិតរបស់ពួកគាត់ការខកខានចំណុចខ្សោយរបស់ ម៉ៅ និង ស្តាលីន គឺមិនយកមកពិចារណាទេ។ ដូច្នេះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា បានបណ្តេញប្រជាជនចេញទាំងអស់ពីទីក្រុងភ្នំពេញ ហើយនិងទីក្រុង ហើយនិងទីប្រជុំផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ហើយបានបង្វិលប្រទេសកម្ពុជាឲ្យទៅជាគុកឥតជញ្ជាំងទាំងមូល។ ដូចដែលសហសេវិករបស់ខ្ញុំបានបញ្ជាក់ លោកស្រី ជា លាង កាលពីថ្ងៃកន្លងទៅនោះ។

[០៩:៤១:១៦]

លោក ប្រធាន លោក លោកស្រីចៅក្រម ដើម្បីយល់អំពី នួនជា ជាជនជាប់ចោទ ថាតើគាត់ជឿជាក់ហើយគាត់ការអះអាងពីភស្តុតាងដាក់បន្ទុកនៅក្នុងដំណើរការសវនាការនេះ ដូច្នេះ សូមលោកស្រីចៅក្រមត្រូវតែទទួលស្គាល់ការសារភាពរបស់គាត់ដែលឆ្លើយជាសម្ងាត់ទៅ ថេត សម្បត្តិ នោះ។ នួនជា នៅទីបំផុតគាត់បានបើកចំហទៅឲ្យ ថេត សម្បត្តិ បានដឹងបន្ទាប់ពីការជួបជាច្រើនឆ្នាំ ហើយគាត់បាននិយាយ ហើយគាត់និយាយអំពីការទទួលខុសត្រូវ ការចាប់ខ្លួន ការសម្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏បានបញ្ជាក់ច្បាស់ដែរថា គាត់មិនមានចេតនាដើម្បីឲ្យឃើញបើកចំហឲ្យគេឃើញឲ្យគេដឹងឮនៅតុលាការទេ។ នេះជាអ្វីដែលគាត់បាននិយាយ។ សូមដកស្រង់៖ “បើគេសួរខ្ញុំនៅតុលាការថា អ្នកណាជាអ្នកសម្លាប់មនុស្ស ខ្ញុំនឹងនិយាយ ខ្ញុំទទួលតែការអប់រំនិងនៅសភាតែប៉ុណ្ណោះ។ ដូច្នេះការសម្លាប់គឺជាការគ្រប់គ្រងរដ្ឋបាល រដ្ឋាភិបាលទេ ជាការទទួលខុសត្រូវរបស់ ប៉ុល ពត និង សុន សេន។ ប្រសិនបើគេនៅតែសួរខ្ញុំ បន្ទាប់មកខ្ញុំនឹងនិយាយថា ការកាប់សម្លាប់ហ្នឹងចាប់ផ្តើមពី ឃើស៊ីងហ្គ័រ”។ លោក លោកស្រីចៅក្រម ដូច្នេះគឺជាគំនិតបែបនេះ។ នៅក្នុងការបង្ហាញខ្លួនដំបូងនៅតុលាការនៅ ថ្ងៃទី ១៩ កញ្ញា ឆ្នាំ២០០៧ នួន ជា បានធ្វើការអះអាងដូចខាងក្រោមនេះ ជូនសហចៅក្រមស៊ើបអង្កេត។ សូមដកស្រង់៖ “ចំពោះខ្លួនខ្ញុំបន្ទាប់ពីរំដោះខ្ញុំស្ថិតនៅក្នុងសភា។ ដូច្នេះ ខ្ញុំមិនបានពាក់ព័ន្ធនឹងកិច្ចការនិតី

ប្រតិបត្តិទេ ក្រៅពីបក្សមានគណៈយោធារបស់បក្សដែលប្រធានជា ប៉ុល ពត ជាមួយ សុន សេន ហើយនិង តាម៉ុក ជាអនុ ហើយនិង សោ ភឹម ហើយនិង កែ ពក ជាសមាជិក។ ដូច្នេះ ខ្ញុំមិនមែនស្ថិតនៅក្នុងគណៈយោធាទេ ខ្ញុំជាអនុលេខាបក្ស ហើយនិងប្រធានសភា។ ក្រៅពីហ្នឹងខ្ញុំទទួលខុសត្រូវការអប់រំកម្មាភិបាល ហើយនិងសមាជិកបក្ស។ ដូច្នេះ ខ្ញុំមិនបានពាក់ព័ន្ធអ្វីទេទាក់ទងទៅនឹងការចោទប្រកាន់ទាំងនេះនោះ" សូមបញ្ចប់សេចក្ដីដកស្រង់។

លោក លោកស្រីចៅក្រម គាត់បាននិយាយដដែលៗអំពីការកុហករបស់គាត់ក្នុងពេលពីរបីម៉ោងក្រោយមកនៅក្នុងការសួរតទល់ដែលលោកស្រីអាចនឹងស្ដាប់ពីវីដេអូឃ្លីបដែលខ្ញុំនឹងសុំអនុញ្ញាតបញ្ចាំងនៅពេលនេះ បាទ។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"របស់គណៈកម្មាធិការយោធា គេមានភារកិច្ចការពារប្រទេស និងបោសសម្អាតផ្ទៃក្នុងប្រទេស។ (សំឡេងជាភាសាបារាំង)... ឯខ្ញុំបាទ ខាងនីតិបញ្ញត្តិខ្ញុំមិនដែលចេញច្បាប់អីឲ្យកាប់សម្លាប់ប្រជាជន"។*

[០៩:៤៤:៤៤]

លោក លោកស្រីចៅក្រម គឺសេចក្ដីដកស្រង់នេះយើងពិបាកនឹងស្ដាប់ឮទាំងអស់ ប៉ុន្តែបញ្ជាក់ថាគណៈយោធាគឺថាមានការការពារជាតិ ហើយនិងកម្ទេចខ្មាំងផ្ទៃក្នុង។ ចំពោះខ្ញុំ ខ្ញុំនៅសភា ហើយខ្ញុំមិនដែលបានធ្វើច្បាប់អ្វីដើម្បីសម្លាប់អ្នកណា សម្លាប់ប្រទេសជាតិនោះទេ។ តាមពិត លោក លោកស្រីចៅក្រមបានឃើញលោក នួន ជា គឺបញ្ជាក់ម្ដងទៀត ម្ដងទៀត អំពីការកុហករបស់គាត់នៅក្នុងការសវនាការ ហើយគាត់មិនដឹងពីរឿងយោធា "ខ្ញុំមិនទទួលខុសត្រូវស-២១។ ខ្ញុំរវល់ជាមួយនឹងការធ្វើច្បាប់ ហើយនិងការអប់រំ"។ លោក លោកស្រីចៅក្រម នេះគឺជាការកុហក ពីព្រោះមិនមានស្ថាប័ននីតិបញ្ញត្តិណាមួយពិតប្រាកដទេនៅកម្ពុជាប្រជាធិបតេយ្យ។ សភាតំណាងប្រជាជនកម្ពុជានោះ ដែលលោក នួន ជា ជាប្រធាននោះ គឺជាការកុហកនោះទេ។ នៅក្នុងសម័យនោះ គឺកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជាដែលគេអះអាងថាត្រូវបានបោះឆ្នោតឲ្យធ្វើសភានោះ មាន អ៊ុង វ៉ែន ហើយនិង ប្រាក់ យុត។ អ្នកទាំងពីរនាក់នេះ បានធ្វើជាសាក្សីបញ្ជាក់ថា គាត់បានដឹងថា គេជាប់ឆ្នោតនោះ ក្រោយពីមានហេតុ-ការណ៍នោះ ប៉ុន្តែគេមិនដែលបានទៅចូលរួមប្រជុំណានោះទេ គ្មានការអញ្ជើញការ មិនមានការពិភាក្សាច្បាប់ មិនបានអនុម័តច្បាប់អ្វីទេ។ លោក នួន ជា ខ្លួនឯងបានទទួលស្គាល់ថា នេះជាការការពារប្រឌិតនេះជាការកុហក ដែលប្រាប់ ថេត សម្បត្តិ ថា គាត់មិនដែលបានទៅរដ្ឋសភានោះទេ។ ហើយមិនមាន

គ្មានអ្វីពិភាក្សាទេ គ្មានច្បាប់អ្វីត្រូវអនុម័តទេ"។ សូមបញ្ចប់សេចក្តីដកស្រង់។

[០៩:៤៦:២៤]

ការពិតអំពីសភាតំណាងប្រជាជននោះ គឺត្រូវតែបង្ហាញនៅក្នុងកំណត់ហេតុអង្គប្រជុំនៅថ្ងៃទី០៨ មីនា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ ដែល ខៀវ សំផន បានធ្វើការបកស្រាយអំពីការបោះឆ្នោតដែលទើបតែធ្វើបាន ហើយខ្លួនគាត់ ប៉ុល ពត និងនួន ជា បានពិភាក្សាអំពីវិធីដើម្បីពួកគាត់ចង់បញ្ឆោតពីបញ្ហានេះ ទៅដល់សាធារណជន។ ខ្ញុំសូមដកស្រង់អំពីកំណត់ហេតុនោះ។ "ប្រសិនបើគេសួរ យើងត្រូវតែពន្យល់ថា មិនគប្បីសង្ស័យទេ យើងត្រូវតែឲ្យមើលឃើញថា យើងនឹងត្រូវតែបង្ក្រាបពួកគេ ប៉ុន្តែយើងមិនត្រូវលែងសើចអំពីសភានេះទេនៅចំពោះមុខប្រជាជន ដែលធ្វើឲ្យគេដឹងថាយើងបញ្ឆោតគេនោះទេ។ ហើយសភារបស់យើងគឺវាគ្មានតម្លៃនោះទេ។ តាមពិតវានៅតែជាការងាររបស់បក្សរបស់យើងដដែល"។ សូមបញ្ចប់សេចក្តីដកស្រង់។

លោក លោកស្រីចៅក្រម គឺមានភស្តុតាងជាច្រើនដែលបានបង្ហាញជូនលោក លោកស្រី ដែលបង្ហាញអំពីតួនាទីពិតប្រាកដរបស់ នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជានិងរបបកម្ពុជាប្រជាធិប-តេយ្យ។ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ យើងបានឃើញភស្តុតាងរបស់ នួន ជា ពីការចូលរួមជាមួយយោធា, សេចក្តីប្រកាសរបស់ អៀង សារី របស់ឌុច ហើយនិងសាក្សីជាច្រើនទៀតដែលថា នួន ជា ជាសមាជិកនៃគណៈយោធាបក្ស។

[០៩:៤៧:៥៣]

នៅខែមករា ឆ្នាំ១៩៧៧ មានសុន្ទរកថាដែលគាត់បានប្រកាសទៅកងទ័ពបដិវត្តកម្ពុជានៅក្នុងនាមគណៈយោធា។ មានសារទូរលេខដែលបញ្ជូនទៅគាត់ដោយកងពល១៦៤ ហើយនិងការប្រាស្រ័យរបស់គាត់ជាមួយ សុន សេន ហើយនិងកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ដែលបង្ហាញថា លោក នួន ជា មានការទទួលខុសត្រូវជាទូទៅលើបញ្ហាយោធា និងសន្តិសុខ ក្នុងឋានៈជាអនុលេខាបក្ស។ លោក លោកស្រីចៅក្រម ក៏បានឃើញអំពីភស្តុតាងជាច្រើនដែលមិនអាចប្រកែកបានថា នួន ជា មានការទទួលខុសត្រូវចំពោះមន្ទីរស-២១ ជាមន្ទីរសន្តិសុខ។ ហើយចម្លើយសារភាពជាច្រើនដែលមានចំណារផ្ទាល់ ហើយបានបញ្ជូនទៅ "បងនួន"។ សក្ខីកម្មអង្គរក្សរបស់លោក នួន ជា ហើយនិងនីរសារ ស្វាត្រ ទៀង ថា "គាត់បានយកស្រោមសំបុត្រដែល ឌុច បានផ្ញើឲ្យទៅប្រគល់ផ្ទាល់លោក នួន ជា"។

សេចក្តីលម្អិតនៃសក្ខីកម្មរបស់ប្រធាននៃស-២១ ឈ្មោះ ឌុច អំពីទំនាក់ទំនង ហើយនិងការទាក់

ទងរបស់គាត់ជាមួយ នួន ជា។ ការទទួលស្គាល់ដែលធ្វើឡើងដោយ នួន ជា ទៅលោក ថេត សម្បត្តិ ថាគាត់បានទទួលចម្លើយសារភាពជាច្រើនដែលគាត់មិនអាចអានវាទាំងអស់នោះទេ។ ហើយជាការទទួលស្គាល់ដែរ គាត់ប្រាប់ ថេត សម្បត្តិ ថាគាត់បានការទទួលខុសត្រូវដោយផ្ទាល់លើស-២១ នៅពេលដែល សុន សេន ត្រូវបានអង្គការចាត់តាំងទៅឱ្យសមរភូមិយោធាភូមិភាគបូព៌ា”។

[០៩:៤៩:៣៩]

លោក លោកស្រីចៅក្រម ឯកសារចុងក្រោយដែលបានបង្ហាញនោះ នៅថ្ងៃទី២៧ មិថុនា ឆ្នាំ ២០១៣ យើងបានបង្ហាញជូនអង្គជំនុំជម្រះ ឯកសារម្តងមួយថាលោក នួន ជា មានតួនាទីនៅក្នុងស-២១ ហើយនិងក្នុងយោធា ហើយនិងភស្តុតាងបានបង្ហាញថា នួន ជា បានមានតំណាងជានាយករដ្ឋមន្ត្រីស្ដីទី គឺស្ទើរតែមួយឆ្នាំ ពីខែកញ្ញា ឆ្នាំ១៩៧៦ ដល់ ៧៧។ ភស្តុតាងក៏បានពិភាក្សានៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់យើងកាលពីខែមុនដែរ។ លោក លោកស្រី គិតទៅដល់ហេតុនេះហើយ ខ្ញុំមិនពិនិត្យឯកសារទាំងអស់នោះទេថ្ងៃនេះ ប៉ុន្តែខ្ញុំនឹងប្រើពេលវេលាដែលសេសសល់នៅក្នុងទាក់ទងពីតួនាទីទូទៅ ហើយនិងអត្តចរិតរបស់គាត់ ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្ដីរបស់គាត់នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

នៅក្នុងការជំនុំជម្រះនេះ ហើយនិងក្នុងបទសម្ភាសន៍ពីដំបូង ហើយនិងចម្លើយរបស់គាត់ យើងស្ដាប់ឮគាត់អះអាងថា គាត់មិនមែន -- សូមដកស្រង់ថា គាត់មិនមែនជាបញ្ញវន្តទេ។ នៅក្នុងកថាខណ្ឌ ១៧៥ របស់សេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់លោក នួន ជា មេធាវីរបស់គាត់បានបដិសេធថាគាត់មិនមែនជាមេមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយគាត់អះអាងថាគាត់មិនមានចំណេះដល់កម្រិតនោះទេ។ គាត់មិនមានតួនាទីសំខាន់ក្នុងការបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទេ។ នេះប្រហែលជាថាជាការកុហក ហើយនិងការកុហកដង្ហើមចុងក្រោយដ៏កំសត់របស់គាត់។ នួន ជា គាត់ជាអ្នកសិក្សាច្បាប់នៅសាកលវិទ្យាល័យដ៏ល្អមួយនៅប្រទេសថៃ គាត់ជាបុរសដែលនិយាយភាសាបីបានយ៉ាងល្អប្រសើរ។ គាត់ជាបុរសអង្គុយទល់មុខជាមួយមេដឹកនាំវៀតណាម ហើយនិងចិន ដោយខ្លួនឯងតែម្នាក់ឯង ដើម្បីចរចាកិច្ចព្រមព្រៀងលើបញ្ហាទាំងឡាយដែលសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់ជាបុរសដែលទទួលស្គាល់ថា គាត់បានសិក្សាពីអក្សរសាស្ត្រកុម្មុយនីស្ត ដោយរួមបញ្ចូលទាំងស្តាលីន ហើយនិង ម៉ៅ ជាសំណេររបស់គាត់ ហើយបានរៀបចំបក្សលក្ខន្តិកៈបក្ស ហើយនិងមាគ៌ាបក្សនៅក្នុងចលនាកុម្មុយនីស្តកម្ពុជា។

[០៩:៥២:១១]

នួន ជា បានបញ្ជាក់នៅក្នុងសវនាការថា បញ្ញវន្តខ្សោយ ហើយគាត់ជាអ្នកប្រយុទ្ធ យុទ្ធសាស្ត្រ ហើយនិងជាអ្នកចូលរួមទាំងអស់។ ដូច្នេះ សំខាន់ហើយនៅពេលដែលគាត់និយាយនៅក្នុងសវនាការនេះ នៅពេលដែលខ្លួនគាត់ចាស់ក៏ដោយ ប៉ុន្តែចិត្តបញ្ញារបស់គាត់នៅខ្លាំង។ លោក លោកស្រីចៅក្រម គាត់ក៏បានបដិសេធចំពោះតថភាព ហើយនិងមូលហេតុទាំងឡាយដោយបានអះអាងថា គាត់មិនមែនជាបញ្ញវន្ត។ ដូច្នេះហើយគាត់គាត់មិនអាចយល់ក្នុងការកសាងនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែនៅពេលនោះ គាត់អះអាងថា គោលការណ៍ -- តួនាទីសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា គឺអប់រំកម្មាភិបាលលើគោលនយោបាយទាំងនោះ”។ ប្រហែលថា នួន ជា ហើយនិងមេធាវីរបស់គាត់អាចពន្យល់យើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ថា តើលោកអាចអប់រំកម្មាភិបាលលើកគោលនយោបាយដូចម្តេច បើខ្លួនឯងមិនយល់អំពីគោលនយោបាយនោះផងនោះ។ ដូច្នេះ បើគាត់អះអាងថាគាត់មិនមែនជាបញ្ញវន្ត នេះមិនអាចគួរឲ្យជឿបានទេ។ នេះជាពាក្យរបស់ឧក្រិដ្ឋជនដែលបានចូលរួមនៅក្នុងការបោកបញ្ឆោត ដើម្បីកាត់បន្ថយការទទួលខុសត្រូវខាងព្រហ្មទណ្ឌក្នុងការធ្វើគោលនយោបាយ ផែនការ និងសេចក្តីសម្រេចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ នួន ជា ក៏បានបដិសេធនៅក្នុងកថាខណ្ឌ១៧៤ នៃសេចក្តីសន្និដ្ឋានបញ្ចប់របស់គាត់នោះ ថាគាត់មិនដែលបានដឹង មិនដែលដឹងថាខ្លួនជាបងធំទី២ទេក្នុងកម្ពុជាប្រជាធិបតេយ្យ។ គាត់ប្រើពាក្យនេះដើម្បីប្រឆាំងនឹងសាក្សីសំខាន់ៗដែលធ្វើសក្ខីកម្មប្រឆាំងនឹងគាត់ ហើយដែលអ្នកទាំងនោះហៅគាត់ថា បងទី២ ដូចជា ឌុច, អ៊ឹង រ៉ែន ហើយនិង ភី ភួន។

[០៩:៥៤:០២]

គឺនួន ជា នេះហើយដែលជាអ្នកច្រឡំ ហើយនិងជាអ្នកកុហកដែលយល់ថា ការចងចាំរបស់សាក្សីមិនត្រឹមត្រូវ។ នេះជាឯកសារមួយចំនួនដែលផលិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យដែលមានលេខមួយចំនួន ដែលបានយោងថាគាត់ជាបងទី២។ ជាឧទាហរណ៍ នៅក្នុងចម្លើយសារភាព ស-២១ របស់ចាប មិត ជាលេខាស្រុកមកពីភូមិភាគបូព៌ា ហើយ ឌុច បានសរសេរ -- ឲ្យ ប៊ុន ជាអ្នកសួរចម្លើយថា បងទី២ បានណែនាំនៅថ្ងៃទី២០ កុម្ភៈ ឆ្នាំ១៩៧៨ ដែលថា “ឈ្មោះកម្មាភិបាលមួយចំនួនត្រូវតែដកចេញបើសិនជាឃើញមាននៅក្នុងចម្លើយសារភាព”។ សូមបញ្ចប់សេចក្តីដកស្រង់។

“នៅក្នុងរបាយការណ៍ខែកញ្ញា ឆ្នាំ១៩៧៦ ពី ឌុច ទៅ សុន សេន ហើយនិង សៀវភៅកំណត់ដៃ ស-២១ -- កម្មាភិបាលស-២១ យោងទៅរកផែនការដើម្បីសម្លាប់បងលេខ១, បងលេខ២”។ សូមបញ្ចប់

ការដកស្រង់។

សៀវភៅសរសេរផ្ទាល់ដៃ ម៉ម ណៃ ហៅ ចាន់ ជាអ្នកធ្វើទារុណកម្មរបស់ ឌុច ដ៏សំខាន់មួយនៅ ស-២១ បានយោងទៅសុន្ទរកថារបស់បងទី១ ហើយបានមានសេចក្តីយោងទៅ នួន ជា ផងដែរសូមដកស្រង់៖ "បក្សតែងតែធ្វើឧទាហរណ៍អំពីបដិវត្តន៍សង្គមនិយម ហើយលេខចម្លើយសារភាពផ្សេងទៀតក៏បាននិយាយពីចំណុចនេះដែរ។ ដែលមានសេចក្តីយោងទៅបងទី២ ដោយរាប់បញ្ចូលទាំងចម្លើយសារភាពមេដឹកនាំជាន់ខ្ពស់ដូចជា វន វ៉េត, កុយ ធួន, ប៉ង់, កង ចាប, ជូ ជេត, ហ៊ូ នឹម, ប៊ូ ផាត ហៅ ហាង់"។

លោក លោកស្រីចៅក្រម ការបោកបញ្ឆោតរបស់ នួន ជា លើបញ្ហាទាំងអស់នេះក៏ជាការដែលបង្ហាញម្តងទៀតនៅនៅក្នុងអត្ថបទដែលគាត់ចុះនៅក្នុងសៀវភៅ ថេត សម្បត្តិ ដែលថា នួន ជា រៀបរាប់ពីទំនាក់ទំនងរបស់គាត់ជាមួយ ប៉ុល ពត។ សូមដកស្រង់៖ "ខ្ញុំគ្រាន់តែហៅគាត់ ហើយនិងខ្ញុំ បងទី១ ហើយនិងទី២"។ សូមបញ្ចប់សេចក្តីដកស្រង់។

លោកប្រធាន ខ្ញុំសូមបញ្ចប់ការពិភាក្សារបស់ខ្ញុំអំពីតួនាទីហើយនិងអត្តចរិតរបស់ នួន ជា ដោយវីដេអូឃ្លីបពីរដែលបង្ហាញអំពីចិត្តគំនិតរបស់ នួន ជា ហើយនិងចេតនាឧក្រិដ្ឋដែលបង្កប់នៅក្នុងនោះ។

ទី១ គឺចេញមកពីបទសម្ភាសន៍ដែលបានកត់ត្រាដោយថេត សម្បត្តិ។

[០៩:៥៦:៥១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"នួន ជា៖ បើទុកពួកហ្នឹងបាត់ប្រទេសជាតិ បាត់ប្រជាជន ស្លាប់ប្រជាជន បាត់ប្រទេសកម្ពុជា គ្មានកម្ពុជាសល់ដល់ឥឡូវទេ បើទុកពួកហ្នឹង។ អាហ្នឹងសម្លាប់ជាតិ។ ផ្ទាល់ខ្លួន វាតែងតែមានមនោសញ្ចេតនាខ្លះ ក៏ប៉ុន្តែខ្ញុំបែងចែកផ្ទាល់ខ្លួន ហើយនិងរួមច្បាស់។ បើរួម យើងយកផ្ទាល់ខ្លួនជាមនោសញ្ចេតនាធ្លាប់រាប់អានគ្នា ធ្លាប់អីហ្នឹងគ្នា ហើយអាជាតិទាំងមូល តែងយកពីណា? ខ្ញុំយកជាតិហើយផ្ទាល់ខ្លួនទុកដោយឡែកសិន ដោះស្រាយសិនទៅ។ ថេត សម្បត្តិ៖ អ៊ីចឹងអ៊ំមានការសោកស្តាយចំពោះពួកទាំងនោះទេបាទ? នួន ជា៖ ខ្ញុំដូចគ្មានការសោកស្តាយទេ។ ខ្ញុំសោកស្តាយជាតិខ្ញុំជាង។ ជាតិខ្ញុំប្រឡាក់ប្រឡោកអ៊ីចឹងទៅហើយ។ ខ្ញុំសោកស្តាយជាង ស្តាយមាគ៌ា ស្តាយគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំស្តាយ ដែលពួកហ្នឹងមកធ្វើធ្លាក់ហើយ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៥៨:០៣]

លោក លោកស្រីចៅក្រម នៅក្នុងវីដេអូមួយទៀតអំពីបទសម្ភាសន៍ នួន ជា ដោយអ្នកយកការណ៍ ប៊ី.ប៊ី.ស៊ី ឈ្មោះ ហ្សៀល រីស ហើយគាត់បានបដិសេធនូវការចោទប្រកាន់របស់គាត់នៅក្នុងតុលាការអន្តរជាតិនាពេលខាងមុខនោះ។ សូមអនុញ្ញាតបញ្ចាំងបាទ។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អំពីតួនាទីនៅក្នុងការកាប់សម្លាប់មនុស្សរាប់លាននោះ គឺជាគំនិតរបស់ខ្ញុំ ហើយគឺជាយុត្តិធម៌របស់ខ្ញុំ។ ហើយនៅក្នុងឆ្នាំ១៩៧៦ តើរយៈពេលប៉ុនណានៅក្នុងគុក ប្រសិនបើដាក់គុក២០ឆ្នាំ ហើយខ្ញុំនឹងអាយុ៩០"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៥៩:០១]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំនឹងបញ្ចប់វគ្គនិយាយពីលោក នួន ជា អំពីតួនាទីរបស់គាត់។ ប៉ុន្តែខ្ញុំនឹងនិយាយអំពីតួនាទីរបស់លោក ខៀវ សំផន ហើយនិងអត្តចរិតរបស់គាត់ទាំងក្នុងមុនពេល ក្នុងពេល និងក្រោយពេលកម្ពុជាប្រជាធិបតេយ្យដើម្បីឲ្យយល់អំពីការចូលរួមរបស់គាត់នៅក្នុងគោលនយោបាយឧក្រិដ្ឋ ហើយនិងអ្វីជាលទ្ធផល ហើយនិងថាតើចេតនារបស់ឧក្រិដ្ឋហ្នឹងមានដូចម្តេច? ហើយតើអ្វីជាការការពាររបស់គាត់នៅក្នុងរឿងក្តីនេះនោះ?

ខ្ញុំសូមអនុញ្ញាតប្រើសំណួរដូចគ្នាសួរទៅលើ នួន ជា ដែរថាតើ ខៀវ សំផន ជាអ្នកណា? លោក លោកស្រីចៅក្រម ខៀវ សំផន បង្ហាញខ្លួនគាត់ថា ,នៅក្នុងអង្គជំនុំជម្រះនេះថា, គាត់គឺជាអ្នកផ្លាក់ចូលទៅក្នុងកម្ពុជាប្រជាធិបតេយ្យដោយចៃដន្យទេ។ គាត់បានឡើងខ្ពស់ផុតកំពូលថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែគាត់មិនបានដឹងអំពីអំពើឃោរឃៅដែលបានរៀបចំ និងអនុវត្តដោយសហសេវិករបស់គាត់។ ហើយគាត់សូមឲ្យតុលាការទទួលស្គាល់ថា ហើយគាត់បានលាក់កំបាំងនូវទីបញ្ជាការបក្សធ្វើការ និងរស់នៅជាមួយ ប៉ុល ពត, នួន ជា ហើយកាន់អំណាចនានានៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចជាន់ខ្ពស់របស់បក្ស ហើយនិងរដ្ឋាភិបាល ហើយគាត់ស្នើសុំថា គាត់មិនបានដឹងអីសោះ មិនមានតួនាទីអ្វីសោះនៅក្នុងការសម្លាប់រង្គាល ការដាក់ទៅឲ្យជាទាសករនូវប្រជាជនរបស់ខ្លួន ហើយគាត់នឹងសូមឲ្យតុលាការទទួលស្គាល់ថា គាត់មិនបានដឹងថា តើបក្សជាអ្វីទេ ប៉ុន្តែគាត់ជាមេនៅក្នុងបក្សនោះថាបក្សនឹងធ្វើអ្វីក៏

មិនដឹង។ ថ្ងៃនេះ ខៀវ សំផន បានព្យាយាមបង្ហាញខ្លួនគាត់ថា គាត់ជាជនស្អាតស្អំ ជាអ្នកស្មោះត្រង់ ហើយជាបញ្ញាជន ជាបុរសដែលខុសពីអ្នកដឹកនាំផ្សេងទៀត ហើយគាត់និយាយថា អ្នកផ្សេងទៀតមិនឱ្យគាត់ដឹងអ្វីទេ ហើយគាត់មិនបានសួរសំណួរទេ ពីព្រោះគាត់គោរពនូវគោលការណ៍សម្ងាត់របស់បក្ស ហើយប៉ុល ពត បានប្រើគាត់គឺជា -- ដូចជាទីងមោងដូច្នោះដែរ។

[១០:០១:១១]

នៅក្នុងគំនិតមួយ គាត់ជាកូនអុក ជាអកុសលដែលឃើញថា ខ្លួនគាត់ស្ថិតនៅក្នុងកំពូលនៃរដ្ឋទាសករ ជាសមាជិកនៃស្ថាប័នដ៏មានកំពូលសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលឡោមព័ទ្ធដោយការសម្លាប់រង្គាល ប៉ុន្តែគាត់មិនបានដឹងអ្វីទាំងអស់ដែលកើតនៅវិញជុំខ្លួនគាត់។ គាត់ជាបុរសតែម្នាក់គត់នៅក្នុងកម្ពុជាដែលមិនបានដឹងអ្វី មិនបានឃើញអ្វី ហើយក៏មិនបានឮអ្វីទាំងអស់។

លោក លោកស្រីចៅក្រមជាទីគោរព! ភស្តុតាងដែលយើងខ្ញុំដាក់នៅចំពោះមុខ លោក លោកស្រីចៅក្រម បង្ហាញជារូបភាពផ្សេងទៅវិញ វាបង្ហាញនូវរូបភាពអំពីមេដឹកនាំនយោបាយជំនាញដែលពូកែបោកបញ្ឆោតមួយរូប បង្ហាញអំពីសមាជិករបស់ជួរដឹកនាំស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជា គឺបង្ហាញអំពីបុរសដែលទទួលបានការអប់រំ ហើយដែលឃ្លានស្រេកចង់បានអំណាច ហើយនិងបង្ហាញអំពីបុរសមួយរូបដែលធ្វើការជាមួយនឹង ប៉ុល ពត, នួន ជា យល់ស្របទៅលើការប្រើប្រាស់ហិង្សាក្នុងមធ្យោបាយសម្រេចនិងអនុវត្តអំណាច។ បុរសដែលអំពាវនាវឱ្យមានការកាប់សម្លាប់ប្រជាជនស្លូតត្រង់ បុរសដែលជឿជាក់ថាវាត្រឹមត្រូវក្នុងការកម្ទេចអ្នកទាំងអស់នោះ ដែលឈរបាំងផ្លូវរបស់បក្សកុម្មុយនីស្តកម្ពុជា។ បុរសដែលចូលរួមនៅក្នុងសេចក្តីសម្រេចជម្លៀសក្រុង បំបែកគ្រួសារ និងដាក់ប្រជាជនទាំងមូលឱ្យទៅជាទាសករក្នុងលក្ខខណ្ឌមួយអមនុស្សធម៌បំផុត គ្មាននរណានឹកស្មានដល់។ បុរសរូបនេះឱបក្រសោបតួនាទីជាមេដឹកនាំ ហើយជាមុខមាត់នៃខ្មែរក្រហមនៅមុន នៅក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បំពេញតួនាទីយ៉ាងមានប្រសិទ្ធភាព ប្រើប្រាស់រូបភាពជាសាធារណៈ ដើម្បីអួតអាងថា -- អួតអាងនូវអ្វីដែលគាត់រៀបរាប់ថាជា “មហាជោគជ័យនៃបក្សរបស់គាត់” ហើយអូសទាញនិងប្រមូលភាពស្របច្បាប់សម្រាប់បក្សកុម្មុយនីស្តកម្ពុជាក្នុងខណៈពេលនោះសើចចំអកទៅលើអ្នកដែលរិះគន់របស់បក្សនោះ។

[១០:០៣:២២]

នៅក្នុងឆ្នាំ១៩៧៥ និង ១៩៧៦ បុរសរូបនេះបានច្រានចោលរបាយការណ៍អំពីភាពសាហាវឃោរ

ឃៅនៅក្នុងប្រទេសកម្ពុជាថា "យុទ្ធនាការបង្ខូចឈ្មោះកម្ពុជា ហើយជាការលើកឡើងគ្មានប្រយោជន៍ និងគួរឲ្យរំខាន"។ ក៏ប៉ុន្តែនៅថ្ងៃនេះ គាត់នៅទីនេះនិយាយជូននៅចំពោះមុខលោកចៅក្រម លោក លោកស្រីចៅក្រមថា គាត់គ្មានដឹងអ្វីទាំងអស់។ ក្នុងនាមជាផ្នែកមួយដ៏សំខាន់នៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានចូលរួមនៅក្នុងការបង្កើត រៀបចំផែនការ ការរៀបចំ និងការតាមដានឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់។ ដូចដែលខ្ញុំបានលើកឡើងខាងដើម គាត់នៅជិតស្និទ្ធជាមួយនឹង ប៉ុល ពត, នួន ជា, សុន សេន និងមេដឹកនាំដទៃទៀតនៅក្នុងមជ្ឈិមបក្ស។ អនុញ្ញាតឲ្យខ្ញុំដកស្រង់ដោយសង្ខេបចេញមកពីសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ដែលក្នុងនោះគាត់រៀបរាប់កាលៈទេសៈដែលគាត់ធ្វើការ និងរស់នៅជាមួយនឹងមេដឹកនាំដទៃទៀត។

ជាដំបូងកិច្ចសម្ភាសន៍ ដែលគាត់បានផ្តល់ជូនស្ថានីយវិទ្យុវប្បធម៌បារាំងនៅក្នុងខែសីហា ឆ្នាំ ២០០៧ ដែលក្នុងនោះគាត់ទទួលស្គាល់ថា គាត់ធ្វើការងារកៀកជាមួយនឹង ប៉ុល ពត យ៉ាងម៉េច។

"សំណួរ៖ តើលោកខ្លាចថា លោកនឹងក្លាយជាជនខ្លាចអំពីការបោសសម្អាតដែរទេ? ហើយក្លាយជាជនរងគ្រោះនៃការបោសសម្អាតដែរឬទេ? ខៀវ សំផន ឆ្លើយ៖ អត់ដែលខ្លាចទេ ខ្ញុំឲ្យតម្លៃនូវវិន័យនេះ ហើយទី២ ខ្ញុំដឹងថាខ្ញុំរស់នៅជិតកន្លែង ប៉ុល ពត ជាមួយនឹងមេដឹកនាំកម្ពុជា ហើយពួកគេឃើញខ្ញុំទុកចិត្តខ្ញុំ"។ ទី២ ខ្ញុំសូមចាក់នូវកិច្ចសម្ភាសន៍ក្នុងខ្សែវីដេអូថ្មីៗ ដែលក្នុងពេលនោះគាត់ផ្តល់ទម្ងន់បន្ថែមទៅលើការទទួលស្គាល់របស់គាត់ត្រង់ ចំណុចនេះ។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខៀវ សំផន៖ ប៉ុល ពត មានវិធី មានរបៀបរបបធ្វើការរបស់គាត់ច្បាស់ណាស់។ ឯយើងក៏ដឹងស្គាល់រូប ប៉ុល ពត ទាំងអស់ដែរ។ បើខ្ញុំ ខ្ញុំមាន កាលខ្ញុំនៅ ខ្ញុំមានអីទៅខ្លាចដូច ប៉ុល ពត ទេ ដឹងច្បាស់អីចឹង និយាយគ្នាធម្មតា ប៉ុន្តែខ្ញុំគោរពគាត់ អាណិតគាត់"*។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:០៥:៣៧]

ហើយការទទួលស្គាល់មួយទៀតពីលោក ខៀវ សំផន នៅក្នុងសៀវភៅឆ្នាំពី-- ចុះឆ្នាំ២០០៤ ខ្ញុំសូមដកស្រង់ ដែលខ្ញុំក៏បានលើកពីខាងដើមផងដែរ "បានន័យថា ប៉ុល ពត តំណាងមេដឹកនាំប្រវត្តិសាស្ត្រ ដែលមិនដែលខុសអ្វីនោះទេ ជាពិសេសនៅពេលដែលធ្វើសេចក្តីសម្រេចសំខាន់ៗ។ តាមអ្វីដែលខ្ញុំ មើលឃើញនៅក្នុងកិច្ចប្រជុំពង្រីកការិយាល័យអចិន្ត្រៃយ៍ គ្មានអ្វីដែលភ័យខ្លាចលេចឡើងនោះទេនៅក្នុងកិច្ច

ប្រជុំទាំងអស់នោះ។ ជាពិសេសទៅទៀត ការប្រជុំនោះគឺវាធ្វើឡើងសាមញ្ញដូចពេលជួបជុំគ្រួសារអ៊ីចឹង។ ពេលនោះសមាជិកខ្លះនោះក៏និយាយលេងសើចផងដែរ” បញ្ចប់ការដកស្រង់។ ដូច្នេះ ខៀវ សំផន យល់ដឹងអំពីតថភាពហើយគាត់គឺជាមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់គឺជារូបភាព និង គឺជាក្រុមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ នៅពេលដែលគាត់អង្គុយរួមជាមួយនឹងគ្នាធ្វើការ និងនិយាយលេងជាមួយគ្នាប្រជាជនរាប់លាននាក់ផ្សេងទៀតត្រូវបានគេបំបែកចេញពីគ្រួសារ ហើយនៅពេលដែលយើងសួរអំពីភស្តុតាងផ្សេងនោះ មេធាវី ខៀវ សំផន បានអះអាងថា គាត់គឺអាចមានពិរុទ្ធភាពដោយសារតែការដែលគាត់មិនដឹងអ្វី។ ខ្ញុំសូមដកស្រង់ចេញពីលិខិតចំហឆ្នាំ២០០១ ខែសីហា ដែល ក្នុងនោះគាត់និយាយថា៖ “ចំពោះជនស្នេហាជាតិដែលបានបាត់បង់អ្នកដែលជាទីស្រលាញ់របស់ខ្លួននៅក្នុងពេលនោះខ្ញុំសូមការអនុគ្រោះ។ ខ្ញុំសូមបង្ហាញអំពីការដែលខ្ញុំមិនដឹងអ្វីទាល់តែសោះ ខ្ញុំធ្វើការងារនោះដើម្បីការរស់រានមានជីវិតនៃជាតិ និងការរីកចម្រើននៃជាតិ។ ខ្ញុំមិនដែលគិតថាវានាំឲ្យមានការកាប់សម្លាប់ដូច្នេះទេ”។ យើងខ្ញុំលើកឡើងថា ការអះអាងនេះគឺជាការព្យាយាមលាក់បាំងនូវការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមធំមួយនេះ។ ខៀវ សំផន មិនមែនគាត់មិនដឹងអ្វីនោះទេ នៅក្នុងកិច្ចសម្ភាសន៍ដែលបានធ្វើឡើងមិនយូរពីមុននោះ គឺគាត់ត្រូវបានសួរ ហើយគាត់បានលើកឡើងនៅក្នុងនោះថា គាត់ត្រូវបាន ប៉ុល ពត បោក បញ្ឆោត។

[១០:០៧:៥៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“ខៀវ សំផន (និយាយភាសាបារាំង)៖ អត់ទេពីព្រោះពេលក្រោយមកទៀតនោះខ្ញុំមានអារម្មណ៍ថាពួកគាត់ត្រូវ ជាអ្វីដែលលោក ប៉ុល ពត បានធ្វើ គឺថាគាត់ត្រូវ។ គាត់មានមូលហេតុក្នុងការធ្វើយ៉ាងដូច្នេះ”។ (បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

**លោក វីណ្ល៉េម ស្មីត៖**

លោក លោកស្រីជាទីគោរព! លោក ខៀវ សំផន មិនមែនមិនដឹងអ្វីនោះទេ។ ដូចដែលគាត់បាននិយាយ គាត់មិនមែនត្រូវអ្នកណាបោកគាត់នោះទេ ជាការពិតគឺគាត់ចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ គាត់រួមទស្សនៈជាមួយ ប៉ុល ពត, នួន ជា។ ដូច្នេះហើយទើបគេជឿទុកចិត្តគាត់ ហើយគាត់បានថ្លែង ហើយនៅតែជាមេដឹកនាំរយៈពេលជាង ប្រហែលជា២៨ឆ្នាំ។ ភស្តុតាងដែលយើងដាក់នៅចំពោះមុខលោក លោកស្រីចៅក្រម នឹងវិភាគជាលម្អិត នៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់

យើងបង្ហាញថា ខៀវ សំផន មានតួនាទីសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ជាសមាជិកមជ្ឈិមបក្ស គាត់ជាមុខមាត់នៃរបបសម្លាប់រង្គាលនេះ។ គាត់ចូលរួមដោយផ្ទាល់នៅក្នុងអំពើទាសករ កម្មវិធីពលកម្មដោយបង្ខំ តាមរយៈការគ្រប់គ្រងរបស់គាត់នៅក្រសួងពាណិជ្ជកម្មនិងឃ្លាំងរដ្ឋ។ គាត់ដើរតួនាទីផ្ទាល់ក្នុងការបង្កើតកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់ជាប្រមុខរដ្ឋ។ គាត់បានត្រួតគ្រប់គ្រងទៅលើការដាក់ឃុំឃាំងនៅក្នុងផ្ទះលើរូបសម្ដេចនរោត្តម សីហនុ។ គាត់ក្លាយទៅជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម។ គាត់ជាសមាជិកនិងប្រធានមន្ទីរនយោបាយ៨៧០ ដែលជានីតិប្រតិបត្តិទទួលខុសត្រូវត្រួតត្រាគ្រប់គ្រងការអនុវត្តគោលនយោបាយមជ្ឈិមបក្ស។ គាត់ធ្វើការស៊ើបអង្កេតសមាជិកជាន់ខ្ពស់នៃបក្សដែលបាន ត្រូវបានគេសង្ស័យ។ ដូចដែលខ្ញុំបានលើកឡើងពីខាងដើម កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅសល់បានបង្ហាញថា ខៀវ សំផន បានចូលរួម ៨៤ភាគរយនៅក្នុងកិច្ចប្រជុំទាំងអស់នោះ។ កំណត់ហេតុទាំងអស់នោះ បានកត់ត្រាត្រង់ៗ ច្បាស់លាស់ ដែលបង្ហាញអំពីការរៀបចំរបស់ដឹកនាំ និងការតាមដានទៅលើឧក្រិដ្ឋកម្មចាប់តាំងពីការបោសសម្អាតខ្មាំង រហូតទៅដល់ការដាក់ជាទាសករនូវការប្រើប្រាស់ការងារដោយបង្ខំ។

[១០:១០:០៩]

ខ្ញុំក៏បានយោងខាងដើមផងដែរ លើកំណត់ហេតុកិច្ចប្រជុំចុះថ្ងៃ០៨ ខែមីនា ឆ្នាំ៧៦ អំពីការងារមូលដ្ឋាន ដែលនៅទីនោះលេខាតំបន់រាយការណ៍ជូន ប៉ុល ពត, នួន ជា និង ខៀវ សំផន អំពីការចាប់ខ្លួនដែលពួកគេបានធ្វើឡើង។ នៅក្នុងកិច្ចប្រជុំនោះ មេដឹកនាំបានបញ្ជាឲ្យលេខាទាំងអស់នោះ ឲ្យបញ្ជូនឯកសារអំពីអ្នកដែលត្រូវបានសង្ស័យថាជាខ្មាំងដើម្បីពិនិត្យ យកមកពិនិត្យមើល។ ឯកសារដំបូង ទំព័រដំបូងបានបង្ហាញអំពីអ្នកដែលបានចូលរួមក្នុងប្រជុំនោះ។

លោក លោកស្រីចៅក្រម ឃើញនៅជួរដំបូង ឈ្មោះមេដឹកនាំ -- គឺជាឈ្មោះមេដឹកនាំកំពូលគឺមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន ដែលហៅថា សមមិត្ត ហែម។ លេខាបីរូបដែលរាយការណ៍នៅក្នុងពេលប្រជុំនោះ រួមមាន សមមិត្ត ហង់។ លោក លោកស្រីចៅក្រម ឃើញឈ្មោះរបស់គាត់នៅខាងក្រោមផ្នែកខាងស្ដាំង។ ហង់ ទទួលខុសត្រូវតំបន់ព្រះវិហារ ឈ្មោះរបស់គាត់ ប៊ូ ផាត។ គាត់គឺជាមិត្តជិតស្និទ្ធយូរមកហើយ ហើយជាអ្នកទទួលការឧបត្ថម្ភពី ខៀវ សំផន។ គាត់ធ្វើការឲ្យ ខៀវ សំផន នៅទសវត្សឆ្នាំ៥០ នៅកន្លែង -- នៅទស្សនាវដ្ដី ឡុបសែវ៉ាទ័រ នៅទីក្រុងភ្នំពេញ។ គាត់រាយការណ៍មជ្ឈិមបក្ស គាត់ប្រាប់នៅក្នុងនោះថា តំបន់របស់គាត់បានចាប់ខ្លួនមនុស្សជាង១០០នាក់ ដោយសារតែ

ចាត់តាំងពីខែមករា ឆ្នាំ៧៦ ដោយសារតែការរត់មកព្រះវិហារនៅតំបន់ផ្សេង។ នៅដើមឆ្នាំ៧៨ ប៊ូ ផាត ត្រូវបានចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅស-២១ ដែលកន្លែងនោះ គេសម្លាប់គាត់ចោល។ ចម្លើយសារភាពរបស់គាត់ ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងរួចហើយ។

[១០:១១:៥៦]

អ្នកចូលរួមម្នាក់ទៀត នៅកិច្ចប្រជុំនៅថ្ងៃ០៨ ខែមីនា ឆ្នាំ៧៦នោះ ដែល ខៀវ សំផន ស្គាល់ច្បាស់នោះ គឺ សឿ វ៉ាស៊ី ហៅ ឌឿន។ ឈ្មោះគាត់នោះ នៅផ្នែកខាងស្តាំ បន្ទាប់ពី ខៀវ សំផន តែម្តង។ ឌឿន ជាអតីតអនុលេខាភូមិភាគឧត្តរ ក្រោយខែមេសា ឆ្នាំ៧៥ គាត់បានក្លាយទៅជាប្រធានមន្ទីរនយោបាយ៨៧០ ដែលជាសាខានីតិប្រតិបត្តិនៃមជ្ឈិមបក្ស។ សមាជិកតែមួយនៃមន្ទីរនោះ គឺរួមមាន ខៀវ សំផន ផងដែរ។ ឌឿន រស់នៅ ក-៣ រួមជាមួយនឹង នួន ជា និងខៀវ សំផន។ ពួកគេធ្វើការរួមគ្នាហូបរួមគ្នា ចូលរួមនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍រួមគ្នា។ ដូច ហង់ ដែរ ឌឿន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅស-២១។ ភស្តុតាងដែលយើងខ្ញុំបានបង្ហាញនៅចំពោះមុខលោក លោកស្រីចៅក្រម បង្ហាញថា ខៀវ សំផន ទទួលតួនាទីបន្តពី ឌឿន ក្នុងនាមជាប្រធានមន្ទីរនយោបាយ៨៧០។ ជាការពិត អ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំ ប្រាំបី -- ថ្ងៃ០៨ ខែមីនា ឆ្នាំ៧៦ លើកលែងតែ ប៉ុល ពត, នួន ជា និង ខៀវ សំផន ទាំងអស់នោះ ត្រូវបានសម្លាប់ចោលតែទាំងអស់ -- ត្រូវបានសម្លាប់ចោលនៅស-២១ ទាំងអស់ លើកលែងតែ ប៉ុល ពត, នួន ជា និងខៀវ សំផន តែប៉ុណ្ណោះ។ អ្នកទាំងអស់នោះ គឺជាបុគ្គលដែល ខៀវ សំផន ស្គាល់ច្បាស់ ធ្វើការងារជាមួយ។ ពួកគេគឺជាកម្មាភិបាលស្មោះត្រង់ ពួកគេត្រូវបានគេសង្ស័យ ហើយត្រូវបានគេផ្តាច់ជីវិតនៅគុកធំរបស់មជ្ឈិមបក្ស គឺ ស-២១។

[១០:១៣:២៤]

នៅចំពោះមុខលោក លោកស្រីចៅក្រម ខៀវ សំផន បានក្រោកឈរឡើង ហើយលើកឡើងការអះអាងថា គាត់មិនដឹងអ្វីនោះទេ។ ការពិតគឺផ្ទុយពីនោះ។ គាត់មិនត្រឹមត្រូវតែបានដឹងការចាប់ខ្លួន គាត់គាំទ្រវាទៀត។ គាត់ចូលរួមនៅក្នុងការបង្កើតការអនុវត្តផែនការឧក្រិដ្ឋ ដែលនាំទៅដល់ការស្លាប់មនុស្សរាប់សែននាក់។ ខៀវ សំផន អត្តចរិតរបស់ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ ត្រូវបានកត់ត្រានៅក្នុងកិច្ចសម្ភាសន៍ជាច្រើន ហើយនិងចម្លើយរបស់គាត់ ដែលក្នុងនោះគឺគាត់បានឆ្លើយជាច្រើនឆ្នាំមកហើយ។ ជាសរុបមកគាត់ជឿថា អំពើទាំងអស់នេះគឺត្រឹមត្រូវ។ ដូចដែលគាត់បាននិយាយនៅក្នុងកិច្ចសម្ភាសន៍ថ្មីមួយថា "ប៉ុល ពត មិនមែនតែចាប់កម្មាភិបាលដោយចោះៗនោះទេ"។ នេះជាបញ្ហាដែលគេ

មានការស៊ើបអង្កេត។ គាត់បានប្រាប់ ស្ទីវហ្វិន ហេដឌ័រ នៅក្នុងឆ្នាំ១៩៨០ ថា “មិនមែនមានតែម្នាក់ទេ ដែលត្រូវចាប់ខ្លួននិងសម្លាប់ចោលថាជាជនស្លូតត្រង់នោះ”។ ការផ្លាស់ប្តូរចំណុចនេះ គឺខ្ញុំបានលើកឡើង និងបញ្ជាក់ជូនលោក លោកស្រីចៅក្រមរួចមកហើយ។ ខ្ញុំសូមដកស្រង់៖ “ចុះអ្នកដូច ហ៊ូ យន់ និង ហ៊ូ នឹម និងអ្នកផ្សេងទៀត ដែលត្រូវបានគេសម្លាប់ចោល ដោយសារតែចោទថាក្បត់នោះ គឺយ៉ាងម៉េចដែរ? ហ៊ូ យន់ និងហ៊ូ នឹម គឺជាមិត្តរបស់លោក ហើយខ្ញុំដឹងថា លោកក៏ដឹងថាមេដឹកនាំបក្សផ្សេងទៀត ក៏ត្រូវបានគេសម្លាប់ដែរ ដោយសារតែចោទថាជា សេ.អ៊ី.អា ខេ.ជី.ប៊ី–កា.ហ្សេ.បេ ឬក៏ភ្នាក់ងារវៀតណាម។ ចុះលេខាភូមិភាគទាំងអស់ អនុលេខា សមាជិក និងលេខា អនុលេខាកងពល សមាជិកកងពលវិញ។ ខ្ញុំហាក់ដូចជាពិបាកជឿណាស់ មានគិញជាច្រើនដែលចក្រពត្តិនិយម និងគិញវៀតណាមនៅក្នុងបក្ស នោះ។ ខ្ញុំយល់ឃើញថា ពួកគេគឺជាភ្នាក់ងារ។ អ្នកទាំងអស់នោះត្រូវបានគេសម្លាប់ចោល ហើយត្រូវបានគេចោទប្រកាន់ថា ដូចជាត្រឹមត្រូវ ហើយត្រូវបានគេសម្លាប់ចោល។ ហើយតើអ្នក លោកគិតយ៉ាងម៉េចដែរ គេចោទខុសលើអ្នកទាំងអស់នោះ ហើយអ្នកទាំងអស់នោះអាចជាជនស្នេហាជាតិ ជនកុម្មុយនីស្តស្មោះត្រង់ ឬក៏យ៉ាងម៉េចដែរ? តាមដែលលោកដឹង ពួកគេគឺជាយ៉ាងម៉េចដែរ គឺជាអ្នកដែលជាជនស្លូតត្រង់ ឬក៏យ៉ាងណា? ពួកគេមិនមែនជាជនស្លូតត្រង់នោះទេ។ នេះជាចម្លើយ។ សូម្បីតែម្នាក់? សូម្បីតែម្នាក់ក៏មិនមែនជាជនស្លូតត្រង់ដែរ។ អ៊ីចឹងបានន័យថា អ្នកដែលត្រូវគេសម្លាប់នោះ គឺជាជនក្បត់? ជាការពិត នេះតាមដែលខ្ញុំដឹង”។

[១០:១៦:១៥]

លោក លោកស្រីចៅក្រមជាទីគោរព! អ្វីទាំងឡាយដែល ខៀវ សំផន បានលើកឡើងនោះ គឺជាដែលពេលខ្លះវាមិនត្រឹមត្រូវ។ ចំពោះគាត់ វាបុគ្គលដែលបក្សកុម្មុយនីស្តកម្ពុជាកំណត់ថាឲ្យស្លាប់នោះ គឺដោយសារតែពួកគេសមនឹងស្លាប់។ វាគ្មានអ្វីសង្ស័យអំពីយថាភាពនៃការទទួលស្គាល់របស់លោក ខៀវ សំផន ចំពោះលោក ហេដឌ័រ នោះទេ។ នៅក្នុងចម្លើយនោះ គឺ ហេដឌ័រ បានរៀបរាប់កិច្ចសម្ភាសន៍នេះដូចតទៅ៖

“ខ្ញុំនៅចងចាំច្បាស់អំពីការសន្ទនា ដោយសារតែវាពាក់ព័ន្ធទៅនឹងអារម្មណ៍ ការតទល់មុខគ្នា និងការប្រឈមដាក់គ្នា គឺជាអ្វីដែលខ្ញុំនៅចាំ”។ នៅក្នុងកិច្ចសម្ភាសន៍ដូចគ្នា ដែលក្នុងនុំង គួសបញ្ជាក់អំពីការចាប់ខ្លួន និងការកាប់សម្លាប់ថា ជាការត្រឹមត្រូវ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានចូលរួមនៅក្នុងករណីទាំងអស់នេះ។ ខ្ញុំសូមដកស្រង់៖ “មានសមមិត្តនៅខាងបស្ចិមដែលត្រូវបានចោទថា ជា

ភ្នាក់ងារយួន ពួកគេទទួលខុសត្រូវចំពោះករណីនេះ។ គេចោទគាត់ ក៏ប៉ុន្តែពួកគេមិនជោគជ័យនោះទេ ដោយសារតែយើងបានស៊ើបអង្កេតករណីនេះទាន់ពេល"។ លោក លោកស្រីចៅក្រម ក៏ចាំការបោះពុម្ពផ្សាយសៀវភៅរបស់លោក ខៀវ សំផន ឆ្នាំ១៩៨៧ ផងដែរ ដែលក្នុងនោះគាត់ប្រៀបធៀបតួលេខនៃការស្លាប់ក្រោមកម្ពុជាប្រជាធិបតេយ្យថា តិចជាងចំនួនស្លាប់នៅក្នុងគ្រោះថ្នាក់រថយន្តនៅក្នុងប្រទេសផ្សេងៗទៀត។

យើងខ្ញុំសូមលើកឡើងថា ការថ្លែងការណ៍នេះគឺវាពាក់ព័ន្ធ ហើយវាបង្ហាញអំពីលោក ខៀវ សំផន ហើយវាបានបង្ហាញឲ្យយើងឃើញថា គាត់គឺជាអ្នកដែល ខៀវ សំផន នេះគឺជាបុគ្គលដែលមានភាពឆ្មើងឆ្មៃ ហើយគាត់គ្មានការសោកស្ដាយនោះទេ។ សេចក្ដីថ្លែងការណ៍ទាំងអស់នេះបង្ហាញអំពីការចូលរួមរបស់គាត់ផ្ទាល់នៅក្នុងសហឧក្រិដ្ឋកម្មរួម និងការមិនគោរពជីវិតមនុស្ស។ យើងសូមស្ដាប់សំឡេង និងសម្ដីរបស់លោក ខៀវ សំផន សាជាថ្មីនៅក្នុងវីដេអូនេះ។

[១០:១៨:២២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខៀវ សំផន៖ បាទ សូមត្រូវយល់ថា បើគ្មាន ប៉ុល ពត បើគ្មានខ្មែរក្រហម ចាប់ពីការធ្លាក់ពីអំណាចឆ្នាំ១៩៧០ហ្នឹង ប្រទេសកម្ពុជាហ្នឹងប្រហែលជាធ្លាក់ទៅក្នុងកណ្ដាប់ដៃកុម្មុយនីស្តវៀតណាមបាត់ទៅហើយ។ អ៊ីចឹងសូមកុំភ្លេចចំណុចនេះឲ្យសោះ។ អ៊ីចឹងមានន័យថាយ៉ាងម៉េច? គឺអត់អីមានន័យថា យ៉ាងម៉េចបើយើងធ្លាក់ទៅក្នុងកណ្ដាប់ដៃវៀតណាមនោះ។ ចំពោះយើងដែលជាជនជាតិខ្មែរនេះមានន័យថាយ៉ាងម៉េចធ្លាក់ទៅក្នុងកណ្ដាប់ដៃវៀតណាម? គឺបានន័យថា មិនចាំបាច់ត្រូវការពេលវេលាយូរអីទេ ដើម្បីឲ្យប្រទេសកម្ពុជាបច្ចុប្បន្ននេះក្លាយទៅជាកម្ពុជាក្រោមនោះ។ អ៊ីចឹងសូមយល់ពីចំណុចនេះ។ តើនៅកម្ពុជាក្រោមទុំងមានប៉ុន្មានលាននាក់? ហើយគេរស់នៅយ៉ាងដូចម៉េចដែររាល់ថ្ងៃនេះ ថាជនជាតិខ្មែរនៅកម្ពុជាក្រោមនោះលោកដឹងទេ? ខ្ញុំសូមប្រាប់លោកថា កម្ពុជាក្រោមហ្នឹងគឺជាមន្ទីរស-២១ដ៏ធំបំផុត។ បាទ ដូច្នេះបើយើងធៀបមន្ទីរស-២១ ដ៏តូចមួយនៅប្រទេសកម្ពុជានេះ លោកចង់ភ្លេចមន្ទីរស-២១ដ៏ធំសម្បើមនៅកម្ពុជាក្រោម ឬក៏យ៉ាងម៉េច?"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:២០:២០]

**លោក វីល្លៀម ស្មីត៖**

ចំពោះលោក ខៀវ សំផន ស-២១គឺជាកន្លែងតូចមួយ បញ្ហាតូចមួយសម្រាប់គាត់។ កន្លែងតូចមួយដោយសារតែគាត់ថា ការឈឺចាប់ទៅលើប្រជាជននោះ គឺវាមិនពាក់ព័ន្ធ។ កិច្ចសម្ភាសន៍ដដែលនេះនៅពេលដែលសួរអំពីក្មេងដែលត្រូវបានគេសម្លាប់នៅស-២១ គាត់ប្រកាសថា ខ្ញុំសូមដកស្រង់៖ “ក្មេងមួយចំនួនតូចនោះ ថាមិនមែនជាហេតុផលត្រូវលុបចោល បំបាត់ចេញពីអំឡុងពេលទាំងមូលនៅក្នុងប្រវត្តិសាស្ត្រនោះទេ” បញ្ចប់ការដកស្រង់។

នៅក្នុងអត្តចរិតដូចគ្នាដែលបានបង្ហាញនិងប៉ះពាល់ទៅដល់ការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន កថាខណ្ឌ១៤៦ នៃសារណាជាលាយលក្ខណ៍អក្សររបស់ពួកគេ មេធាវីការពារក្តីលើកឡើងអំពីបញ្ជារបស់ ខៀវ សំផន នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលបញ្ជាឲ្យកាប់សម្លាប់មន្ត្រីជាន់ខ្ពស់សាធារណរដ្ឋខ្មែរ ដោយអះអាងថាបញ្ជានោះពាក់ព័ន្ធទៅនឹង -- ខ្ញុំដកស្រង់៖ “ប្រជាជនតែប៉ុណ្ណោះ”។ ខ្ញុំសូមផ្តល់ឧទាហរណ៍មួយទៀតអំពីការយល់ឃើញរបស់ ខៀវ សំផន និយាយអំពីការកាប់សម្លាប់ក្រៅប្រព័ន្ធតុលាការថាជាការត្រឹមត្រូវ។ នៅក្នុងកិច្ចសម្ភាសន៍ថ្មីមួយ គាត់បានរៀបរាប់ជាលម្អិតអំពីបញ្ជាចាន់ ចក្រី ដែលជាមេបញ្ជាការភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅស-២១ ក្នុងឆ្នាំ៧៦ ក្រោយពេលគេចោទចាន់ ចក្រី អំពីការឃុបឃិតនៅក្នុងការបំផ្ទុះជាតិគ្រាប់បែកជិតក-៣ ដែលជាកន្លែងការងារ និងការរស់នៅរបស់ នួន ជា និង ខៀវ សំផន។

[១០:២១:៥០]

នៅក្នុងសៀវភៅរបស់គាត់ចុះឆ្នាំ២០០៧ ខៀវ សំផន បង្ហាញច្បាស់ច្រើនណាស់អំពីការគាំទ្ររបស់គាត់ក្នុងការចាប់ ចាន់ ចក្រី និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត។ ខ្ញុំសូមដកស្រង់៖ “ភស្តុតាង ដែល ហ្វីលីព ស្សូត បានលើកឡើងអំពីវៀតណាម បង្កើតចលនាខ្មែររំដោះ” រួមជាមួយនឹងភស្តុតាងដែលអ្នកស្រាវជ្រាវផ្សេងទៀតបានរកឃើញ បានបង្ហាញច្បាស់ថា ការតាមដានរបស់ប៉ុល ពតក្រោយពីគោលការណ៍៣៧៨លើ ចក្រី, ឈូក និង យ៉ា ហើយនិងកម្មាភិបាលផ្សេងទៀត ដែលសហការជាមួយនឹងវៀតមិញ គឺត្រឹមត្រូវ។ ដូច្នេះ ហ្វីលីព ស្សូត លើកឡើងខុសនៅពេលគាត់សរសេរថា សូមដកស្រង់៖ “តួនាទីរបស់គុកស-២១ និងចម្លើយសារភាពមិនមែនជាមូលដ្ឋានផ្តល់ព័ត៌មាននោះទេ ក៏ប៉ុន្តែវាផ្តល់នូវភស្តុតាងនៃការក្បត់ ដែលចាំបាច់ត្រូវចាប់បុគ្គលណាម្នាក់ដែលគេសម្រេចថានឹងចាប់” បញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រមជាទីគោរព! នេះមានន័យថា ខៀវ សំផន ជឿជាក់ថា និងនៅតែជឿជាក់ថា "គុករបស់របបនោះដែលខ្លាំង ដែលអ្នកដែលត្រូវបានគេសង្ស័យថាជាខ្មាំងនោះត្រូវយកទៅធ្វើទារុណកម្មសម្លាប់ចោល និងធ្វើការស៊ើបអង្កេត"។ នៅពេលខ្ញុំសួរអំពីចំណុចនេះ –ដែលខ្ញុំទើបតែដកស្រង់– ហ្វីលីព ស្ប៊ូត និងសាក្សីជំនាញបានលើកឡើងដូចតទៅ៖ "នេះគឺជាការពន្យល់តាមន័យសាមញ្ញរបស់ខ្មែរក្រហម និងបក្សកុម្មុយនីស្តកម្ពុជា"។ រួមជាមួយសហសេវិករបស់គាត់ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន, ខៀវ សំផន គូសវាសរៀបចំ និងត្រួតត្រាគ្រប់គ្រងទៅលើការសម្លាប់រង្គាល និងការជម្លៀសដោយបង្ខំលើទីក្រុង និងទីជនបទ ហើយការកែប្រែប្រទេសនេះឲ្យទៅជាប្រទេសមួយដែលគេហៅថា ប្រទេសទាសករ។

[១០:២៣:៥៤]

អ្វីដែលពន្យល់អំពីការចូលរួមរបស់ ខៀវ សំផន នៅក្នុងឧក្រិដ្ឋកម្មនោះ គឺជាអ្វីទៅ? ចម្លើយនោះគឺថាគាត់ជឿជាក់ថាឧក្រិដ្ឋកម្មទាំងអស់នេះចាំបាច់ ដែលមានហេតុផលដាច់ខាត។ ហេតុអ្វីបានជាវាមានហេតុផល? ពីព្រោះវាប្រឈមទៅនឹងជម្រើសខុសមួយរវាងការអនុញ្ញាតប្រជាជនឲ្យរស់នៅក្នុងសេរីភាពនិងការការពារប្រទេស។ ខៀវ សំផន បានសម្រេចលះបង់ប្រជាជនរបស់ខ្លួន។ សូមឲ្យមើលពាក្យសម្តីរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ២០០៦៖ "ឈប់និយាយអំពីការកាប់សម្លាប់ ប្រសិនបើចង់ឲ្យប្រទេសមួយទទួលឯករាជ្យ និងសេរីភាពនោះ យើងត្រូវតែលះបង់សម្រាប់ជាតិ។ ប្រជាជនអាចមិនមានសេរីភាពច្រើនទេ មេដឹកនាំនយោបាយត្រូវតែអនុវត្តគោលនយោបាយផ្តាច់ការ និងតឹងរ៉ឹងមួយ"។ ពាក្យទាំងអស់នេះបានសង្ខេបយ៉ាងត្រឹមត្រូវអំពីអត្តចរិតរបស់ ខៀវ សំផន ក្នុងអំឡុងពេលដែលបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងប្រទេសកម្ពុជា។ គឺជាការលើកឡើងអំពីការចាំបាច់ក្នុងការកសាងប្រទេសក្នុងល្បឿនមួយឲ្យលឿនបំផុត និងការការពារបក្សប្រឆាំងនឹងខ្មាំងដែលគេមើលឃើញ ហើយនិងការត្រូវជម្លៀសទីក្រុង និងការកាប់សម្លាប់អ្នកប្រឆាំង និងការដាក់ទាសករប្រទេសនេះទាំងមូល។

[១០:២៥:១៦]

នៅក្នុងសេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សររបស់គាត់ ខៀវ សំផន បានព្យាយាមបន្ថយនូវការចូលរួមសំខាន់របស់គាត់ដែលគាត់ធ្វើឲ្យប្រទេសនេះក្លាយជាទាសករ។ ការបង្កើតគឺការបង្កើតកម្ពុជាប្រជាធិបតេយ្យ។ គាត់រៀបរាប់ខ្លួនគាត់ថាគាត់ត្រូវបានគេឃុំនៅក្នុងទីតាំងមួយដែលមានការយាមកាមនៅក្នុងទីក្រុងដែលគ្មានមនុស្ស។ គាត់លើកឡើងថា គាត់គ្រាន់តែតាមដានការពិភាក្សាស្តីអំពីការទៅលើ

បញ្ហារដ្ឋធម្មនុញ្ញនិងការបោះឆ្នោត សម្រាប់សភាថ្មីតែប៉ុណ្ណោះ។ គាត់និយាយថា គាត់ទទួលតួនាទីនេះដោយសារតែសម្ដេច នរោត្តម សីហនុ គាត់បដិសេធ។ នេះគឺជាការប្រៀបធៀបអំពីជោគវាសនារបស់បុគ្គលពីររូប ក្នុងនោះសម្ដេច សីហនុ គាត់បានបដិសេធមិនទទួលតួនាទីនៅក្នុងរដ្ឋនេះទេ ហើយមួយទៀត ខៀវ សំផន បានជួយអនុវត្តនូវគម្រោង ដែលផ្ដល់ឲ្យមើលឃើញនូវប្រជាធិបតេយ្យដោយស្របច្បាប់។ បន្ទាប់មក គឺការទទួលនូវតួនាទីមួយដែលមានលក្ខណៈផ្លូវការនៅក្នុងប្រទេសនេះ។ លោក ខៀវ សំផន បានប្រើប្រាស់មន្ទីរនេះដើម្បីបង្កើននូវរបប ហើយចេញនូវសេចក្ដីសាធារណៈគាំទ្រទៅលើគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្ដកម្ពុជានៅក្នុងឆ្នាំ១៩៧៦, ៧៧ និង៧៨។

[១០:២៦:៤៧]

ភស្តុតាងបង្ហាញច្បាស់ថាគាត់បានបញ្ចេញរបាយការណ៍ដ៏លម្អិតដែលទាក់ទងទៅនឹងសេចក្ដីព្រាងរដ្ឋធម្មនុញ្ញនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ នៅក្នុងរបាយការណ៍នោះគាត់បានប្រកាសអំណាចធ្វើច្បាប់ស្ថិតនៅក្នុងរដ្ឋសភាដែលជាប់ឆ្នោត។ តាមពិតដូចដែលខ្ញុំបញ្ជាក់ខាងដើម រដ្ឋសភាគឺជាឆាកល្ខោននោះទេ។ ក្នុងឋានៈជាសមាជិកមជ្ឈិមបក្ស ខៀវ សំផន បានដឹងពីរឿងនេះ គាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ហើយនៅក្នុងសភានោះគាត់បានរៀបរាប់ថាគ្មានតម្លៃ។ ខៀវ សំផន គាត់បានសម្របសម្រួលនូវការបោះឆ្នោតដែលគួរឲ្យខ្មាសអៀននោះដែលថា បង្កើតសភាដោយបន្តុំដែលបង្ហាញថា -- បង្ហាញនៅក្នុងរបាយការណ៍ថ្ងៃ០៨ ខែមីនា ឆ្នាំ១៩៧៦។ នៅក្នុងដំណាក់កាលនេះ សម្ដេច សីហនុ បានដាក់សុំលិខិតលាលែងទៅ ខៀវ សំផន បានបដិសេធការចូលរួមនៅក្នុងរដ្ឋទាសករ ហើយបានទុកព្រះអង្គស្ថិតនៅក្នុងការសេចក្ដីរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយគាត់មិនចង់ចូលរួមជាមួយនឹងអ្នកណាម្នាក់។ តាមក្ដី -- ជាពិសេសនៅក្នុងកម្មវិធីកាប់សម្លាប់របស់បក្សកុម្មុយនីស្ដកម្ពុជា។ គេបានដាក់សម្ដេចសីហនុឃុំខ្លួននៅក្នុងរាជវាំង ខៀវ សំផន ស្ថិតនៅជាសមាជិកជាមេដឹកនាំដ៏សកម្មរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយបន្តធ្វើបែបនេះជាច្រើនឆ្នាំមកទៀត។

[១០:២៨:១៤]

លោក លោកស្រីចៅក្រមយើងពិនិត្យមើលថាតើ ប៉ុល ពត ពិភាក្សាពីជោគវាសនាដូចម្ដេចរបស់សម្ដេច នរោត្តម សីហនុ នៅក្នុងប្រជុំសម្ងាត់ដែល នួន ជា, ខៀវ សំផន បានចូលរួមដែលនៅក្នុងថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ សូមដកស្រង់៖ “តាមពិតសីហនុគឺជាខ្លាកញ្ជាស់។ មានតែស្បែក និងឆ្អឹង គឺគ្មានចង្កូម គ្មានអំណាចទេ។ ហើយព្រះអង្គនៅរង់ចាំតែថ្ងៃស្លាប់តែប៉ុណ្ណោះ។ ហើយយើងមិនសម្លាប់ព្រះអង្គ

ទេ ប៉ុន្តែប្រជាជនហើយនិងជាតិ ព្រះអង្គមានកំហុសធ្ងន់ណាស់។ ហើយយើងនឹងរក្សាទុកព្រះអង្គ ប៉ុន្តែទុកឲ្យព្រះអង្គដាច់ខ្យល់ស្លាប់ខ្លួនឯង។ យើងត្រូវតែបញ្ចប់ យើងត្រូវបញ្ចប់សក្តិភូមិវាត្រូវតែដូច្នេះ។ កូនអុកគឺត្រូវតែស្ថិតក្នុងចំណុចនេះ។ របបសក្តិភូមិទាំងមូលត្រូវបានកម្ទេចទាំងស្រុង ហើយនិងបំបាត់ចោលដោយបដិវត្តន៍អស់ហើយ។ ស្តេច គឺមានជាង២០០០ឆ្នាំមកហើយត្រូវតែ នៅទីបញ្ចប់ត្រូវតែស្អាត”។ សូមបញ្ចប់សេចក្តីដកស្រង់។

លោក លោកស្រីចៅក្រម ខៀវ សំផន ហើយនិង នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំមួយដែលនិយាយអំពីការធ្វើឃាតទៅលើអតីតព្រះមហាក្សត្រ។ កត់សម្គាល់ពាក្យទាំងអស់នេះលោក លោកស្រីចៅក្រជាពាក្យសំខាន់ “យើងមិនសម្លាប់ព្រះអង្គទេ ប៉ុន្តែប្រសិនបើព្រះអង្គនៅតែតវ៉ារកសេរីភាព យើងត្រូវតែបញ្ចប់ព្រះអង្គ”។ នេះជាពាក្យដែលថា ខៀវ សំផន បានក្រសោបយកទាំងស្រុងដែលថារបបដែលគាត់បានយល់ស្រប ដឹកនាំ ហើយនិងយល់ស្របតាម។ ក្នុងរយៈពេលបីឆ្នាំ ដែលបុរសនេះបានបង្ហាញខ្លួនថាជាអ្នកស្រឡាញ់សន្តិភាព សុចរិត ហើយនិងស្មោះត្រង់ ហើយគាត់ជាអ្នកត្រួតត្រាលើការឃុំខ្លួនព្រះអង្គនៅក្នុងលំនៅទៅវិញ។ ខៀវ សំផន បានបន្តធ្វើជាមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា -- កម្ពុជាប្រជាធិបតេយ្យរហូតដល់ថ្ងៃចុងក្រោយរបស់របបនោះ។ យើងបានឃើញភស្តុតាងដែលបានផ្តល់ដោយសាក្សីជាច្រើន ដែលនិយាយអំពីកិច្ចប្រជុំខែមករា ឆ្នាំ១៩៧៦ ដែលចេញបទបញ្ជាឃោធាទៅដល់មេបញ្ជាការមេដឹកនាំផ្សេងៗ មុនពេលដែលគាត់ចេញដំណើរជាមួយ ប៉ុល ពត និង នួន ជា។ សូម្បីតែក្រោយឆ្នាំ១៩៧៥ នៅពេលដែលប្រជាជនបាននិយាយអំពីអំពើឃោរឃៅ និងទំហំនៃបទឧក្រិដ្ឋកម្មកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានវាយប្រយុទ្ធ ហើយនិងទាមទារយកអំណាច ហើយគាត់នៅតែបន្តធ្វើបែបនោះ២០ឆ្នាំ មុនពេលនឹងចុះចាញ់ឆ្នាំ១៩៧៨។

[១០:៣១:២៣]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំបញ្ចប់អំពីតួនាទី ហើយនិងអត្តចរិតរបស់ជនជាប់ចោទទាំងពីរ ប៉ុន្តែខ្ញុំនឹងចូលទៅផ្នែកថ្មីអំពីការចូលរួមក្នុងបទឧក្រិដ្ឋកម្ម។ តើអនុញ្ញាតឲ្យខ្ញុំបន្ត ឬត្រូវសម្រាកនៅត្រឹមនេះសិន លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោក វីល្លៀម ស្មីត។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញវិញ

ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៤៩ នាទី)*

[១០:៤៩:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅព្រះរាជអាជ្ញា ដើម្បីបន្តការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះខ្ញុំចូលទៅដល់ផ្នែកមួយដើម្បីជម្រាបជូនអង្គជំនុំជម្រះអំពីការចូលរួមជាច្រើនរបស់លោក ខៀវ សំផន និងរបស់លោក នួន ជា ដែលចូលរួមក្នុងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ ដែលជាកម្មវត្ថុនៃការជំនុំជម្រះនេះ។

ចាប់ផ្ដើមអំពីការបំលាស់ទីប្រជាជនដោយបង្ខំ ការជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយការកាប់សម្លាប់ ហើយនិងអំពើអមនុស្សធម៌ដែលកើតឡើងនៅក្នុងការជម្លៀសនោះ។ ចម្លើយទៅនឹងថាតើអ្វីជាការចូលរួមរបស់ នួន ជា និង ខៀវ សំផន នោះទៅនឹងបទឧក្រិដ្ឋនេះ? គឺថាវាមានលក្ខណៈច្បាស់ហើយ ភស្តុតាងបានបង្ហាញលើសពីវិមតិសង្ស័យថា ទាំង នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងកិច្ចប្រជុំនោះបានសម្រេចជាឯកច្ឆន្ទថាប្រជាជនភ្នំពេញ ហើយនិងទីក្រុងផ្សេងៗទៀតនៅកម្ពុជានឹងត្រូវបានគេបង្ខំឲ្យចាកចេញពីក្រុងនោះ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានកាន់អំណាច។

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ នៅចាប់ផ្ដើមដំបូងនៃកិច្ចសវនាការនេះ លោក នួន ជា បានបញ្ជាក់ថា ការសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយនិងក្រុងផ្សេងទៀតត្រូវបានធ្វើឡើងនៅក្នុងការប្រជុំរបស់មជ្ឈិមបក្សដែលបានធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ១៩៧៤ គាត់បានរៀបរាប់អំពីកម្មវិធីរបៀបវារៈនៃការប្រជុំនោះដូចខាងក្រោមនេះ សូមដកស្រង់៖ "ការប្រជុំបានធ្វើសេចក្ដីសម្រេចលើបញ្ហា

ខាងក្រោមជាឯកច្ឆន្ទមួយ ក្នុងករណីរំដោះបានទីក្រុងភ្នំពេញ យើងត្រូវតែជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយនិងពីទីប្រជុំជនផ្សេងទៀតដោយជាបណ្ដោះអាសន្ន ដើម្បីវិភាគសភាពការណ៍នៅសម័យមួយរយៈកាល។ ជាពិសេស ដើម្បីវិភាគអំពីចិត្តគំនិតរបស់វៀតណាម"។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១០:៥២:២៨]

ពីដំបូងលោក នួន ជា បានរៀបរាប់ពីការប្រជុំនេះ ជាវគ្គប្រជុំពិសេសរបស់គណៈអចិន្ត្រៃយ៍ ក្រោយមកគាត់បានបញ្ជាក់នៅពេលដែលលោកចៅក្រម ឡាវ៉ែន៍ សួរចម្លើយ ថាជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ហើយនិងសមាជិកនៃគណៈមជ្ឈិម ដែលបានសម្រេចនៅពាក់កណ្ដាលឆ្នាំ១៩៧៤ ដើម្បីជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយនិងពីទីប្រជុំជនទីរួមខេត្តផ្សេងៗទៀត។ កិច្ចប្រជុំដែលលោក នួន ជា បានរៀបរាប់នេះ គឺបានយោងទៅនៅក្នុងបញ្ហាមួយចំនួននៅក្នុងឯកសារទស្សនាវដ្ដីទង់បដិវត្ត។ ទង់បដិវត្តនៅខែកញ្ញា ឆ្នាំ១៩៧៧ បានចុះផ្សាយសុន្ទរកថារបស់ ប៉ុល ពត និយាយអំពីខួបទី១៧ នៃបក្សកុម្មុយនីស្តកម្ពុជា បានយោងទៅរកការប្រជុំថ្ងៃ -- ខែមិថុនា ឆ្នាំ១៩៧៤ ដែលនិយាយថា "សម្រេចវាយសម្រុករំដោះទីក្រុងភ្នំពេញ ហើយនិងទូទាំងប្រទេសឲ្យបាន"។ សូមចប់ការដកស្រង់។

លោក លោកស្រីចៅក្រម នឹងនឹកឃើញអំពីលោក ស្ទីវ ហេដឌ័រ ដែលបញ្ជាក់នៅក្នុងសក្ខីកម្មរបស់គាត់ គឺថាអត្ថបទភាសាខ្មែរនៃទង់បដិវត្តនោះ និយាយអំពីការប្រជុំរបស់មជ្ឈិមបក្ស ហៅថាមជ្ឈិមបក្ស មិនមែននិយាយថា ជាគណៈអចិន្ត្រៃយ៍ -- ជាគណៈមជ្ឈិមដូចមាននៅក្នុងការបកប្រែនោះទេ។ ដូច្នេះនៅក្នុងការប្រជុំនៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានសម្រេចជម្លៀសទីក្រុងភ្នំពេញ គឺមិនមែនជាការប្រជុំរបស់គណៈមជ្ឈិម -- គណៈអចិន្ត្រៃយ៍ ហើយក៏មិនមែនជាការប្រជុំរបស់គណៈមជ្ឈិម។ ចំណុចនេះជាកត្តាសំខាន់ដែលអង្គជំនុំជម្រះត្រូវពិចារណាថា តើអ្នកណាខ្លះវត្តមាននៅក្នុងការប្រជុំនេះ? តាមការទទួលស្គាល់ ហើយនិងសក្ខីកម្មរបស់គាត់ លោក នួន ជា គឺជាមេដឹកនាំម្នាក់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ។ តើអ្នកណាផ្សេងទៀតដែលបានប្រជុំគ្នានៅខែមិថុនា ពាក់កណ្ដាលឆ្នាំ១៩៧៤ ដែលបានសម្រេចជាឯកច្ឆន្ទ ដើម្បីជម្លៀសទីក្រុងភ្នំពេញ?

[១០:៥៤:៤៣]

ចម្លើយទៅនឹងសំណួរនេះ គឺបានផ្ដល់ទៅលោក លោកស្រីចៅក្រម ដោយលោក ភី ភួន ដែលពេលនោះ គាត់ជាអង្គរក្សរបស់ ប៉ុល ពត ហើយបានវត្តមាននៅក្នុងអង្គប្រជុំនោះ។ ភី ភួន បាននឹកឃើញថា គេបានប្រជុំនៅរដូវវស្សា នៅក្នុងឆ្នាំ១៩៧៤ នៅក្នុងខែមិថុនា ឬកក្កដា។ គាត់បានបញ្ជាក់ថា

ការប្រជុំនោះគឺប្រើពេលជាងពីរសប្តាហ៍ ហើយធ្វើឡើងនៅមន្ទីរបក្ស នៅភូមិមាយ ស្រុកស្ទឹងត្រង់ ហើយបានចូលរួមដោយសមាជិកមួយចំនួនតូច តិចជាងសមាជបក្សដែលគាត់បានឃើញពីមុន។ សំខាន់បំផុត ភី ភួន បានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ ក្រុមនៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ។ គាត់បានបញ្ជាក់ថា ប៉ុល ពត ក៏នៅទីនោះ, នួន ជា នៅទីនោះ, អៀង សារី នៅទីនោះ ខៀវ សំផន នៅទីនោះ។ គាត់ក៏បានឃើញ សោ ភឹម, កុយ ធួន, តាម៉ុក, វន វ៉េត, រស់ ញឹម ហើយនិង សុន សេន នៅក្នុងការប្រជុំនោះដែរ។ សក្ខីកម្មរបស់ ភី ភួន បញ្ជាក់ថា ខៀវ សំផន វត្តមាននៅក្នុងការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានធ្វើនៅមន្ទីរមាយ នៅខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៤ ហើយវាស៊ីសង្វាក់ទៅនឹងប្រភពផ្សេងៗទៀតនោះដែរ។

[១០:៥៦:១២]

លោក លោកស្រីចៅក្រមបានជ្រាបហើយថា អៀង សារី ហើយនិង ខៀវ សំផន បានធ្វើដំណើរទៅបរទេសនៅខែមុននោះ។ ទៅប្រទេសមួយចំនួន ហើយអឺរ៉ុបខាងកើត និងអាហ្វ្រិក។ គាត់ត្រឡប់មកពីដំណើរនោះទៅប៉េកាំង នៅថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៤ ហើយបានជិះយន្តហោះទៅហាណូយថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៤ ហើយនៅខែមិថុនា ឆ្នាំ១៩៧៤ បានត្រឡប់មកកម្ពុជាវិញ។ រយៈពេលដែលពួកគាត់មកពីដំណើរនេះបានបញ្ជាក់ដោយឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារកាទូត ហើយនិងសក្ខីកម្មរបស់ សួង ស៊ីគឿង និងហើយនិង នឹម សែម ដែលគាត់បានចូលរួមនៅក្នុងគណៈប្រតិភូនោះ ដែលធ្វើដំណើរជាមួយ ខៀវ សំផន ហើយនិង អៀង សារី។ សក្ខីកម្មរបស់ ភី ភួន បានស៊ីសង្វាក់នឹងចម្លើយរបស់លោក អៀង សារី ដែលបានទទួលស្គាល់ថា គាត់បានមកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៤ ហើយថានៅក្នុងពេលនោះគាត់មានការពិភាក្សាជាមួយ ប៉ុល ពត អំពីការជម្លៀសទីក្រុងភ្នំពេញ។ ដូច្នេះ លោក លោកស្រីចៅក្រម គឺមិនមានភស្តុតាងណាដែលដាក់ ខៀវ សំផន នៅផ្សេងទៀតទេ ប៉ុន្តែគាត់នៅកម្ពុជាតាមផ្នែកដែលយើងមើលឃើញនេះ គឺគាត់បានសហការយ៉ាងជិតស្និទ្ធ ហើយនិងធ្វើការយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំផ្សេងទៀត។ តាមពិត លោក-លោកស្រីចៅក្រម លោក ខៀវ សំផន បានវត្តមាននៅទីតាំងមួយនៅខែមិថុនា ឆ្នាំ១៩៧៤ នៅភូមិមាយនោះ គឺបានបង្ហាញនៅក្នុងសក្ខីកម្មរបស់គាត់ ដោយភរិយារបស់គាត់ ដែលនិយាយថាប្តីរបស់គាត់នៅក្នុងកន្លែងប្រជុំនោះនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤។ សូ សុជាតិ បានប្រាប់តុលាការថា គាត់បាននៅមន្ទីរមាយ។ ខ្ញុំសូមដកស្រង់៖ “នៅពេលដំបូងដែលខ្ញុំបានឲ្យកំណើតកូនទី១” ហើយគាត់បានជម្រាបតុលាការថា កូនប្រុសរបស់គាត់កើតនៅថ្ងៃទី០៤

ខែឧសភា ឆ្នាំ១៩៧៤ ហើយ ខៀវ សំផន បានចេញពីប្រទេសនៅពេលនោះ ហើយបានប្រសូត្រកូនមួយ ហើយប្រហែលមួយខែក្រោយមកគាត់ក៏ត្រឡប់មកវិញ។

[១០:៥៨:២៨]

នៅថ្ងៃសុក្រ លោក លោកស្រីចៅក្រម បានខ្ញុំពិនិត្យមើលការកុហក ហើយនិងការឆ្លើយដោះសារបស់ នួន ជា នៅក្នុងការជំនុំជម្រះនៅពេលគាត់ឆ្លើយសំណួរទាក់ទងទៅលោក ខៀវ សំផន។ ការកុហកមួយរបស់គាត់នោះ ការប៉ុនប៉ងដើម្បីការពារជនជាប់ចោទរបស់គាត់ គឺថាទាំង អៀង សារី និង ខៀវ សំផន មិនវត្តមាននៅក្នុងកិច្ចប្រជុំនោះទេ។ ប៉ុន្តែ អៀង សារី ខ្លួនឯងបានបដិសេធការអះអាងរបស់ នួន ជា ដូចដែលខ្ញុំបានលើកឡើងមូលហេតុខាងដើម។ អង្គជំនុំជម្រះមិនអាចផ្តល់តម្លៃការប៉ុនប៉ងរបស់លោក នួន ជា ដើម្បីកាត់ចម្ងាយរបស់លោក ខៀវ សំផន ចេញពីបញ្ហានេះទេ។

លោក លោកស្រីចៅក្រម នៅការប្រជុំថ្ងៃ -- ខែមិថុនា ឆ្នាំ១៩៧៤ គឺជាការប្រជុំមួយក្នុងការប្រជុំទាំងឡាយដែលជនជាប់ចោទបានចូលរួមក្នុងការធ្វើផែនការជម្លៀសទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀត។ នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំនេះដែលបានធ្វើឡើងនៅដើមខែមេសា ឆ្នាំ១៩៧៥ នៅទីបញ្ជាការប-៥ នៅក្នុងឃុំពាម ខេត្តកំពង់ឆ្នាំង ដែលជាផែនការចុងក្រោយដើម្បីវាយរំដោះយកភ្នំពេញ ដូចដែលបានពិភាក្សាដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។

[១០:៥៩:៥០]

នៅថ្ងៃសុក្រ ខ្ញុំបានពិភាក្សាអំពីតួនាទីមូលដ្ឋាន ប-៥ ដែល ខៀវ សំផន និង នួន ជា បានទទួលស្គាល់ថា ពួកគេនៅមូលដ្ឋានជួរមុខរបស់បក្សនៅខាងលិចឧដុង្គ នៅឃុំពាម នៅក្នុងពីរបីសប្តាហ៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ លោក ខៀវ សំផន បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា គាត់បាននៅទីកន្លែងនោះនៅចុងខែមីនា ឆ្នាំ១៩៧៥។ នួន ជា បានទទួលស្គាល់ថា គាត់បាននៅ ប-៥ នៅខែមេសា ឆ្នាំ១៩៧៥ ហើយកម្មវត្ថុនៃការពិភាក្សានៅប-៥នោះ ជាមូលដ្ឋាននោះ គឺការរំដោះហើយនិងការជម្លៀសទីក្រុងភ្នំពេញ។ នៅថ្ងៃសុក្រខ្ញុំក៏បានបង្ហាញជូនភាពយន្ត ប៉ុល ពត, នួន ជា និង ខៀវ សំផន បាននៅជាមួយគ្នាបានមើលផែនទីនៅមូលដ្ឋាន ប-៥។

លោក លោកស្រីចៅក្រម នៅចាំសក្ខីកម្មរបស់ ភី ភួន ដែលរៀបរាប់អំពីការប្រជុំនៅ ប-៥ នៅខែ មេសា ឆ្នាំ១៩៧៥ដែរ ត្រូវបានចូលរួមដោយក្រុមមេដឹកនាំដដែល ដូចដែលធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៧៤ដែរ មានប៉ុលពត មាន នួនជា, ខៀវ សំផន, តាម៉ុក, សុន សេន, កុយ ធួន, វន វេត, និង

សោភឹម។ ភី ភួន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា មេដឹកនាំបក្សបានវត្តមាននៅក្នុងការប្រជុំនេះហើយពិភាក្សាហើយឯកភាពទៅលើផែនការនៃការជម្លៀស។ គាត់បាននិយាយយ៉ាងជាក់លាក់ថា គាត់បានឮនួនជា ហើយនិង ខៀវ សំផន និយាយនៅក្នុងកិច្ចប្រជុំនេះ។ ខ្ញុំសូមដកស្រង់ "ខ្ញុំកត់សម្គាល់ថា អ៊ំ នួនជាបានឡើងមានមតិ ហើយជាអ្នកនិយាយមុន។ គាត់និយាយថា គឺជាការចាំបាច់ ហើយត្រូវមានការយល់ព្រម ហើយការជម្លៀសគឺជាការសំខាន់។ ហើយគាត់និយាយអំពីជំហររបស់គាត់ គាត់យល់ព្រមជាមួយនឹងផែនការ។ សំណួរ៖ ចុះលោក ខៀវសំផន វិញតើគាត់និយាយអ្វីទេ មុនពេលដែលគាត់យល់ស្របទៅលើផែនការ? ចម្លើយ៖ អ៊ំ ខៀវ សំផន ក៏បានព្រមព្រៀងលើផែនការនោះដែរ។ ហើយការប្រជុំទាំងមូលក៏បានទះដៃហើយបានឯកភាពទៅលើគំនិតនោះ"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១១:០២:១០]

ដូចកិច្ចប្រជុំនៅខែមិថុនា ឆ្នាំ១៩៧៤ដែរ ហើយនិងផ្អែកលើដំណើរការធ្វើសេចក្តីសម្រេចសមូហភាពដូចដែលខ្ញុំពិភាក្សាពីថ្ងៃសុក្រនោះ គឺសេចក្តីសម្រេចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ គឺជាសេចក្តីសម្រេចឯកភាព។ ភី ភួន បានបញ្ជាក់ថា៖ "ការប្រជុំនឹងនិយាយអំពីបញ្ហាយោធា ព្រមទាំងការវិធានការជម្លៀសផងដែរ" បញ្ចប់ដកស្រង់។ គាត់បានរៀបរាប់អំពីការពិភាក្សារវាងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងកិច្ចប្រជុំទាក់ទងទៅនឹងមូលហេតុនៃការជម្លៀសទីក្រុង ទីប្រជុំជននានា ហើយគាត់បាននិយាយថា សូមដកស្រង់៖ "មុនពេលយើងរំដោះទីក្រុងភ្នំពេញ យើងត្រូវតែរំដោះទីប្រជុំជនខេត្តផ្សេងទៀត ហើយអ្នកដែលចូលរួមនៅក្នុងសមរភូមិបានចែករំលែកគំនិតរបស់គេ ហើយគេនិយាយថាប្រសិនបើគេនៅក្នុងទីក្រុង បក្សនឹងមានការលំបាកក្នុងការត្រួតត្រាពួកគេ។ ដូច្នេះ ដោយហេតុថាពួកគេនៅទីនោះយូរដូច្នេះយើងពិបាក មិនឲ្យរកម្មាភិបាលត្រួតត្រាបាន។ ដូច្នេះយើងត្រូវតែជម្លៀសដើម្បីឲ្យយើងអាចកាន់ក្តាប់ទីក្រុងប្រជុំជនបានស្រួល"។ ចប់សេចក្តីដកស្រង់។

[១១:០៣:២៧]

លោក លោកស្រីចៅក្រម ភី ភួន បានកំណត់អត្តសញ្ញាណលោក នួន ជា យ៉ាងច្បាស់ថាជាមនុស្សម្នាក់ដែលនិយាយនៅក្នុងការប្រជុំនៅប-៥ អំពីបទពិសោធន៍នៃការជម្លៀសទីក្រុងផ្សេងទៀត ទីប្រជុំជនផ្សេងទៀត និយាយថា លោក នួន ជា បាននិយាយទៅការជម្លៀសអ្នកដែលនៅក្នុងតំបន់រំដោះគេហៅថា "ជាបទពិសោធន៍"។ មិនមែនអ្នកណាម្នាក់នៅក្នុងអង្គប្រជុំនោះនិយាយអំពីការព្រួយបារម្ភពីបញ្ហាដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនទូទាំងប្រទេសចេញពីទីក្រុងដែលមានទំហំធំដូចភ្នំពេញ

នេះទេ។

លោក លោកស្រីចៅក្រម បានឮសេចក្ដីសន្និដ្ឋានលោកស្រី ជា លាង ដែលជាសហសេវិករបស់ខ្ញុំអំពីទម្លាប់អនុវត្តរបស់បក្សកុម្មុយនីស្ដកម្ពុជា ជាពិសេសដោយគ្មានក្ដីមេត្តា ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៣ និង ៧៥។ ភី ភួន បានបញ្ជាក់ថា វាផ្អែកជាចម្បងទៅលើបទពិសោធន៍របស់បក្ស ដូចជាការជម្លៀសទីក្រុងឧដុង្គដែលមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាសម្រេចថា គេត្រូវតែជម្លៀសទីក្រុងភ្នំពេញផងដែរ។ គាត់បាននៅក្នុងវគ្គសិក្សាដែលគាត់បានឮពី នួន ជា និង ខៀវ សំផន ថាពិភាក្សាអំពីបទពិសោធន៍ពីឧដុង្គ ហើយនិងទម្លាប់របស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងការជម្លៀសទីប្រជុំជននិងទីក្រុងដែលគេកាន់កាប់។ នៅក្នុងវគ្គសិក្សាទាំងពីរនោះ នួន ជា ហើយនិង ខៀវ សំផន បានពន្យល់ពីគោលបំណងនៃការជម្លៀសនោះមានពីរ៖ “១) គឺប៉ុនប៉ងកុំឲ្យខ្មាំងអាចនឹងធ្វើឲ្យកម្លាំងរបស់យើងឃ្លីងឃ្លោងបាន។ ទី២) ដើម្បីការពារកម្មាភិបាលកុំឲ្យមានអំពើពុករលួយខាងស្មារតី និងនយោបាយពីប្រជាជនក្រុង” បញ្ចប់ដកស្រង់។ នេះគឺជាភស្ដុតាងដ៏សំខាន់នៃរឿងក្ដីនេះ បង្ហាញពីចេតនាហើយនិងការដឹងរបស់ជនជាប់ចោទអំពីការយល់ព្រមទៅលើការផែនការរួម ទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង។ ហើយគាត់បានដឹងទាំងស្រុងអំពីលទ្ធផលដែលបានគ្រោងទុកពីការសម្រេចទាំងអស់នោះ។ ហើយក៏បានបង្ហាញភស្ដុតាងថា សេចក្ដីសម្រេចជម្លៀសទីក្រុងភ្នំពេញមិនមានទាក់ទងទៅនឹងស្បៀងអាហារនោះទេ។ ហើយក៏មិនពាក់ព័ន្ធទៅនឹងការគំរាមកំហែងនៃការទម្លាក់គ្រាប់បែកអាមេរិកាំងដែរ។

[១១:០៥:៥៨]

វាជាយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាដើម្បីត្រួតត្រាប្រជាជន ដើម្បីបង្ខំពួកគេឲ្យធ្វើការនៅសហករណ៍ ហើយនិងដើម្បីវែកមុខខ្មាំងរបស់គេ។ វាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួមដ៏ធំមួយដែលភស្ដុតាងបានបង្ហាញជូនអង្គជំនុំជម្រះថា ដើម្បីប្រព្រឹត្តលើពលរដ្ឋកម្ពុជាថាជាទ្រព្យ ជាឧបករណ៍ដាក់ឲ្យពួកគេជាទាសករ ដោយគាបសង្កត់តាមសហករណ៍ពលកម្មដោយបង្ខំ ធ្វើការដោយមិនមានបង់ប្រាក់នៅក្នុងលក្ខខណ្ឌអមនុស្សធម៌ ហើយនិងបដិសេធនូវសេចក្ដីត្រូវការ និងសិទ្ធិជាមូលដ្ឋាន។ វាផ្នែកនៃការធ្វើទុក្ខបុកម្នេញ ហើយនិងការបំបាត់តម្រង់ទៅរកក្រុមទិសដៅមួយចំនួន ដែលគេចាត់ទុកថាជាខ្មាំង ជាពិសេសមន្ត្រី និងនាយទាហាររបស់សាធារណរដ្ឋខ្មែរ ហើយនិងអ្នកទទួលការអប់រំ អ្នកសាសនាហើយនិងជនជាតិភាគតិច ដែលមានចំណងទៅនឹងប្រទេសផ្សេងទៀតដែរ។ ការចូលរួមរបស់ជនជាប់

នៅក្នុងការពាក់ព័ន្ធនៅក្នុងផែនការឧក្រិដ្ឋកម្មបន្តធ្វើពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ នួន ជា និង ខៀវ សំផន គឺជាផ្នែកមួយនៃក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលបានប្តេជ្ញាចិត្តសម្រេចលើការជម្លៀសប្រជាជនចេញពីទីក្រុងឲ្យជាអចិន្ត្រៃយ៍។

[១១:០៧:២៥]

ខៀវ សំផន បានទទួលស្គាល់ថា មានបញ្ហាស្មុគស្មាញជាច្រើនបានលើកឡើងអំពីការជម្លៀសនេះ។ ហើយគណៈមជ្ឈិម ហើយនិងគណៈអចិន្ត្រៃយ៍បន្តលើកឡើង ហើយនិងសម្រេចលើបញ្ហានានាដែលទាក់ទងទៅនឹងប្រជាជនជម្លៀសជាបន្តបន្ទាប់។ បន្ថែមលើការចូលរួមនៅក្នុងការប្រជុំដែលសម្រេចជាឯកច្ឆន្ទក្នុងការជម្លៀសទីក្រុងភ្នំពេញ ហើយមានភស្តុតាងដ៏សំខាន់អំពីអំពើ ហើយនិងការប្រកាសដោយជនជាប់ចោទ ដែលបង្ហាញពីសមាជិកភាព ហើយនិងការចូលរួមរបស់ពួកគាត់ ទៅនឹងផែនការឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការជម្លៀសទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀត។ ទាំង នួន ជា, ទាំង ខៀវ សំផន គឺជាផ្នែកនៃក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលបានតាមដាន ហើយនិងបញ្ជាការវាយប្រហារចុងក្រោយលើភ្នំពេញ ហើយនិងការជម្លៀសប្រជាជនទាំងអស់ ហើយនិងគាត់បញ្ជាពីមូលដ្ឋានមុខនៅឧដុង្គ។ នៅថ្ងៃសុក្រ ខ្ញុំបានពិភាក្សាភស្តុតាងដែលបង្ហាញអំពីការត្រួតត្រាដែលមានប្រសិទ្ធភាព និងការបញ្ជារបស់បក្សលើភូមិភាគ ហើយនិងកម្លាំងយោធាបក្សកុម្មុយនីស្តកម្ពុជា។ ជាពិសេសនៅសប្តាហ៍មួយ -- ពីរសប្តាហ៍មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ យ៉ាងហោចណាស់ ពីរថ្ងៃដំបូងនៃការជម្លៀស ហើយនិងប្រហែលជាមួយសប្តាហ៍ នួន ជា និង ខៀវ សំផន គឺនៅមូលដ្ឋានបញ្ជាជួរមុខ ដោយមាន ប៉ុល ពត និង នួន ជា ហើយនិងមេដឹកនាំភូមិភាគទាំងបួន ដែលធ្វើការអនុវត្តការជម្លៀសទីក្រុងភ្នំពេញ មាន សោ ភឹម, តាម៉ុក, កុយ ធួន ហើយនិង វន វេត។

[១១:០៩:១២]

លោក លោកស្រីចៅក្រម ក្រុមមេដឹកនាំនេះ គឺជាក្រុមដ៏សំខាន់ដដែល ដែលបានកំណត់ខ្លួននៅក្នុងឆ្នាំ១៩៧២ ដោយរណសិរ្សរួបរួមជាតិកម្ពុជាថា ជាក្រុមអ្នកបញ្ជាការរបស់យោធាចលនាតស៊ូគឺជាកងកម្លាំងរំដោះជាតិកម្ពុជា។ ហើយនៅក្នុងអត្ថបទសារព័ត៌មាន នៅថ្ងៃទី២៣ មីនា ឆ្នាំ១៩៧២ បានប្រកាសដោយការិយាល័យព័ត៌មានរណសិរ្សរួបរួមជាតិកម្ពុជា កំណត់អ្នកដែលស្ថិតនៅលើថ្នាក់កំពូលនិងការដឹកនាំ វាមានដូចខាងក្រោម របស់ ស៊ី.ភី.អិន.អិល.អេ.អេហ្វ៖ ប្រធាន ខៀវ សំផន ជាអគ្គមេបញ្ជាការនៃកងកម្លាំងរំដោះជាតិកម្ពុជា, អនុប្រធាន សាឡុត ស (ប៉ុល ពត) ប្រធានមេដឹកនាំយោធា

របស់កងទ័ព, អនុប្រធាន នួន ជា ប្រធានមេដឹកនាំនយោបាយនៃយោធា ប្រធាន សូ វណ្ណា ដែលគេ -- យើងដឹងថាគាត់ជា សោ ភឹម ជាអនុប្រធាននៃមេដឹកនាំយោធានៃកងទ័ព, សមាជិក ឈិត ជឿន ដែលយើងស្គាល់ភាគច្រើនតាមឈ្មោះគាត់ តាម៉ុក ជាប្រធានមន្ទីរភស្តុភារ ហើយសមាជិក សុន សេន ជានាយសេនាធិការ។ លោក លោកស្រីចៅក្រម មិនមែនជារឿងចៃដន្យទេ បុរសទាំងប្រាំរូបនេះដែលបានវត្តមាននៅដើមខែមេសា ឆ្នាំ១៩៧៥ នៅមន្ទីរប-៥ នោះដែលសម្រេចផែនការចុងក្រោយនៃការជម្លៀសទីក្រុងភ្នំពេញហើយក៏មិនជារឿងចៃដន្យដែរ បុរសទាំងប្រាំនាក់នេះនៅតែស្ថិតនៅក្នុងមូលដ្ឋានជួរមុខនៅរបស់បក្សក្នុងពេលវាយរំដោះភ្នំពេញចុងក្រោយ ហើយបន្តនៅទីនោះតទៅទៀត។

[១១:១១:០៩]

នួន ជា និង ខៀវ សំផន ជាផ្នែកមួយនៃក្រុមតូចនៃមេដឹកនាំជាន់ខ្ពស់របស់បក្សដែលត្រួតត្រាហើយនិងបញ្ជាកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាក្នុងពេលជម្លៀស។ គេបានទទួលដំណឹងតាមវិទ្យុទាក់ទងហើយនិងសារទូរលេខអំពីស្ថានាភាពទាំងអស់នៅសមរភូមិទាំងអស់។ បញ្ហាអ្វីក៏ដោយដែលគេប្រឈមមុខ គេតែងតែបានដឹងទាំងអស់ គេធ្វើសេចក្ដីសម្រេច ហើយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាជាអ្នកសម្រេចនូវ -- អនុវត្តនូវការបញ្ជា។ ខៀវ សំផន អះអាងថាគាត់មិនមានតួនាទីសំខាន់នៅប-៥ ឬក៏មូលដ្ឋានបក្សផ្សេងទៀតទេ ប៉ុន្តែភស្តុតាងដែលបានស្តាប់នៅក្នុងសវនាការនេះគឺបង្ហាញថា តាមពិតគាត់ជាមេដឹកនាំម្នាក់ជាន់ខ្ពស់ដែលចូលរួមយ៉ាងសកម្មទៅនឹងកិច្ចព្រមព្រៀងយោធា ដែលនៅពីក្រោយ ឬគាំទ្រការជម្លៀស។

លោក លោកស្រីចៅក្រម ចាំកម្មាភិបាលពីរនាក់ដែលវត្តមាននៅក្នុងប-៥ បានធ្វើសក្ខីកម្មថាអ្នកទាំងពីរនោះបញ្ជាក់ថា “ខៀវ សំផន បានចូលរួមយ៉ាងសកម្ម ហើយនិងពាក់ព័ន្ធយ៉ាងសំខាន់ក្នុងមតិរបស់គាត់”។ សាឡុត បាន ហៅ សូ ហុង ជាក្មួយ ហើយជាអង្គរក្សរបស់ ប៉ុល ពត “បានឃើញ ខៀវ សំផន បានចូលរួមការប្រជុំនៅមន្ទីររបស់ ប៉ុល ពត នៅឃុំពាម នៅមុនពេលការវាយប្រហារទីក្រុងភ្នំពេញ ហើយបានជួយក្នុងការធ្វើបញ្ជីនូវយុទ្ធូបករណ៍ គ្រាប់រំសេវផង។ លើសពីនេះទៅទៀត អ្វីជាសក្ខីកម្មរបស់គាត់ ខៀវ សំផន គឺជាមេដឹកនាំម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបានសម្រេចលើផែនការជម្លៀសចុងក្រោយ”។ ភី ភួន ក៏បានបញ្ជាក់ផងដែរថា នៅពេលដែលគាត់នៅប-៥ គាត់បានបញ្ជូនសាររវាង ខៀវ សំផន ហើយនិងសមរភូមិនានា។ មេបញ្ជាការវរសេនាធំ ហើយនិងកងវរសេនាតូចដែលបានមកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានដឹងថាមេដឹកនាំរបស់បក្សនៅជិតហ្នឹង

ហើយគេជាអ្នកទទួលខុសត្រូវក្នុងការសម្រេចបញ្ហាដែលសំខាន់ៗ។ យើងបានដឹងពីឧទាហរណ៍ដ៏សំខាន់នៅក្នុងបទបង្ហាញរបស់សហសេវិករបស់ខ្ញុំ ជា លាង ពីសប្តាហ៍មុននៅពេលដែលមេបញ្ជាការយោធាបក្សកុម្មុយនីស្តកម្ពុជា ក្រសួងឃោស-នាការដែលបាន -- ឆេនបើក បានសួរ ថាតើមន្ត្រី លន់ នល់ អាចជួបជោគវាសនាដូចម្តេចនៅពេលគេប្រមូលនៅទីនោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥? ចម្លើយរបស់គាត់នោះ គាត់ឆ្លើយថាមេដឹកនាំកំពូលនយោបាយសំខាន់ៗ គឺមិននៅឆ្ងាយពីទីក្រុងនោះទេ ហើយពួកគេនោះហើយដែលយើងត្រូវសម្រេចលើពួកគេនោះ។

[១១:១៣:៥៧]

មេដឹកនាំពីរនាក់ក្នុងចំណោមនោះ គឺជនជាប់ចោទពីរនាក់នៅក្នុងសាលសវនាការថ្ងៃនេះហើយ។ ភស្តុតាងដែលបានបង្ហាញ គឺច្បាស់លាស់ណាស់ គឺពួកគេបានសម្រេច គេសម្រេចកម្ទេច លុបបំបាត់នូវមន្ត្រីទាំងអស់នេះ ហើយភស្តុតាង ឬសេចក្តីសម្រេចរបស់គាត់ជាភស្តុតាងដ៏រឹងមាំអំពីការកាប់សម្លាប់មន្ត្រីនៅភ្នំពេញ អ្នកជម្លៀស ហើយនិងជម្លៀស សម្លាប់នៅតាមផ្លូវ នៅទិសដៅដែលទៅដល់ ហើយនិងនៅទួលពោធិ៍ជ្រៃដូចលោកស្រី ជា លាង សហសេវិកខ្ញុំបានរៀបរាប់ពិស្តាររួចហើយ។ នួន ជា និង ខៀវ សំផន ជាសមាជិកដ៏សំខាន់ដែលបានធ្វើសេចក្តីសម្រេចចូលរួមក្នុងការលុបបំបាត់ នាយ និងកូនទាហាន លន់ នល់ ហើយគាត់ទាំងពីរនេះជាអ្នកទទួលខុសត្រូវចំពោះហេតុការណ៍ឧក្រិដ្ឋទាំងអស់នេះ។ នួន ជា ក៏បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះតាមរយៈការចូលរួមនៅក្នុងការបង្កើតមាគ៌ាយុទ្ធសាស្ត្រ និងនយោបាយរបស់បក្ស រួមទាំងការប្រើប្រាស់ហិង្សាបដិវត្តន៍ប្រឆាំងនឹងជនស៊ីវិល។ ការយល់ឃើញដែលថា ខ្មាំងរបស់បក្ស គឺនៅផ្តុំនៅក្នុងក្រុង ហើយនិងការសម្រេចថា ទីជនបទ គឺជាមូលដ្ឋានគាំទ្ររបស់បក្ស។ មូលដ្ឋានដែលបក្ស នឹងវាយប្រហារ ប្រមូលផ្តុំ និងធ្វើការបិទដង្ហើមក្រុងមូលធន។

[១១:១៥:២៤]

បើទោះជា នួន ជា មានការតវ៉ាថា គាត់មិនមែនជាបញ្ញាជន សេចក្តីសន្និដ្ឋានបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ នួន ជា បានទទួលស្គាល់តួនាទីរបស់គាត់ក្នុងការបង្កើត និងការអភិវឌ្ឍគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ សុន្ទរកថាសំខាន់ចំនួនពីរ ដែលថ្លែងឡើងដោយ នួន ជា ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏បង្ហាញភស្តុតាងអំពីការយល់ស្របរបស់ នួន ជា នៅក្នុងផែនការ និងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលអនុវត្តក្នុងពេលជម្លៀសទីក្រុងភ្នំពេញ។ ក្នុងសុន្ទរកថាមួយដែលគាត់ថ្លែងជូនកងទ័ពបដិវត្តន៍កម្ពុជាក្នុង ខែមករា ឆ្នាំ៧៧ នួន ជា បានដកស្រង់អំពីការជម្លៀសទីក្រុងឧដុង្គ បាណាម

និងកន្លែងផ្សេងទៀត ឬក្រុងផ្សេងទៀត ជាគំរូនៃមាគ៌ាយុទ្ធសាស្ត្រសំខាន់របស់បក្សក្នុងការគ្រប់គ្រងប្រជាជន និងដណ្ដើមប្រជាជន។ នួន ជា បានរៀបរាប់ចំណុចនេះដូចតទៅ៖ "យើងចាប់យកមនុស្សគ្រប់គ្នានៅក្នុងក្រុងបាណាម បណ្ដេញជនជាតិវៀតណាម ជនជាតិចិន យោធា និងនគរបាលចេញ ហើយយើងយកមនុស្សទាំងអស់នោះពង្រឹងប្រជាជនចេញពីខ្មាំង"។ នួន ជា បានបញ្ជាក់អំពីការឯកភាពរបស់គាត់ និងការយល់ស្របរបស់គាត់ជាមួយនឹងមាគ៌ាបក្ស៖ "មាគ៌ារបស់យើងគឺ យើងវ៉ៃដណ្ដើមប្រជាជន យើងយកមួយ យើងយកបានពីរ យើងយកបាន ១០០ យើងយកបាន១.០០០ ហើយយកបានរហូតដល់ពេលយើងអាចវាយដណ្ដើមយកប្រជាជនពីក្រុងភ្នំពេញបានដែរ។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងគឺជាមាគ៌ាត្រឹមត្រូវ"។

[១១:១៦:០១]

លោក លោកស្រីចៅក្រមជាទីគោរព! នៅក្នុងសុន្ទរកថា ខែមិថុនា ឆ្នាំ៧៨ ថ្លែងជូនគណៈប្រតិភូមកពីបក្សកុម្មុយនីស្តដាណឺម៉ាក នួន ជា បានបញ្ជាក់ការដឹងឮរបស់គាត់ និងយល់ស្របរបស់គាត់ ជាមួយនឹងគោលបំណងពិតនៃការជម្លៀសក្រុង និងទីជនបទកម្ពុជា គឺដើម្បីធ្វើយ៉ាងណាស្វែងរក និងកម្ទេចខ្មាំង។ នៅក្នុងសុន្ទរកថានោះ នួន ជា បានបញ្ជាក់យ៉ាងច្បាស់ថា មានខ្មាំងច្រើននៅក្នុងក្រុង ហើយលើកឡើងថា ហេតុផលជម្លៀសក្រុង គឺដើម្បីកម្ទេចខ្មាំងដែលមានផែនការចាប់ -- ដែលមានផែនការប្រឆាំងឬក៏ផ្ដួលបក្សកុម្មុយនីស្តកម្ពុជា ដែលពាក្យសម្ដីរបស់ នួន ជា ថ្លែងដូចតទៅនេះ គឺ នួន ជា បានមានការឯកភាពជាមួយនឹងផែនការនៅក្នុងការជម្លៀសទីក្រុងភ្នំពេញ និងការស្វែងរកខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។

ក្នុងនាមជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន តែងតែចេញនូវសេចក្ដីថ្លែងការណ៍គាំទ្រ និងការបញ្ជាឱ្យមានកាវាយប្រហារលើទីក្រុងភ្នំពេញ រួមទាំងការចេញការថ្លែងការណ៍ជាចំហ ធ្វើការវាយប្រហារទៅលើមន្ត្រីសាធារណរដ្ឋខ្មែរ រួមទាំងការវាយប្រហារលើអ្នករស់នៅទីក្រុងភ្នំពេញ។

នៅក្នុងសេចក្ដីថ្លែងការណ៍ ខែមករា ឆ្នាំ១៩៧៣ គឺគាត់បានអួតអំពីសមរភូមិនៅស្វាយព្រៃតាមផ្លូវជាតិលេខ២ យើងបានកម្ទេចភូមិយុទ្ធសាស្ត្រ១០របស់ខ្មាំង។

[១១:១៨:៥៧]

នៅក្នុងខែមេសា ឆ្នាំ៧៤ ក្រោយពេលទីក្រុងឧដុង្គត្រូវបានជម្លៀសដោយបង្ខំ ហើយមន្ត្រីសាធារណរដ្ឋខ្មែរជាច្រើននាក់ត្រូវបានគេឡោមព័ទ្ធ និងសម្លាប់ចោល ខៀវ សំផន បានសរសើរអំពីការកម្ទេច

ខ្មាំង៥.០០០នាក់ និងការកម្ទេចទាហានអាយ៉ងរបស់សាធារណរដ្ឋខ្មែរនៅឧដុង្គ ហើយគាត់ក៏បានរៀបរាប់ថាទីក្រុងភ្នំពេញ គឺជាកន្លែងលាក់ខ្លួនចុងក្រោយរបស់ពួកក្បត់។ គឺ ខៀវ សំផន នេះឯង ដែលបានប្រកាសនៅពេលចាប់ផ្ដើមការវាយសម្រុកចុងក្រោយលើទីក្រុងភ្នំពេញ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ ដែលក្នុងនោះ គាត់កោះអំពាវនាវឲ្យកងទ័ពទាំងអស់ និងកម្មាភិបាលធ្វើការវាយសម្រុកឲ្យបានខ្លាំងក្លា និងរឹងប៉ឹងបំផុត ប្រឆាំងនឹងខ្មាំងនៅក្នុងទីក្រុងភ្នំពេញ និងទីក្រុងទីប្រជុំជនដទៃទៀត។ ក្នុងរយៈពេលប៉ុន្មានខែ ឈានទៅដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ខៀវ សំផន បានចាត់ទុកភ្នំពេញជាកន្លែងលាក់ខ្លួនចុងក្រោយរបស់ខ្មាំង។ ខៀវ សំផន បានអង្វរអំពាវនាវកម្មាភិបាលធ្វើការបោសសម្អាតសកម្មភាពស្ងប់ស្ងាត់របស់ខ្មាំងពីភូមិភាគរំដោះទាំងអស់។ គាត់លើកសរសើរអំពីការបាញ់ផ្ដោងទីក្រុងភ្នំពេញដោយការវាយប្រហារតាមកងកាំភ្លើងធំដ៏សកម្មរបស់កងកម្លាំងរបស់យើង។ គាត់បានបដិសេធដែលអាចឈានទៅរកសន្តិភាពក្នុងការបញ្ចប់សង្គ្រាម និងការជៀសវាងក្នុងការវាយប្រហារទីក្រុងភ្នំពេញ។ ហើយគាត់បានគាំទ្រទៅលើការផ្ដាច់ដង្ហើមទីក្រុងភ្នំពេញតាមរយៈការបិទផ្លូវយោធា។ សេចក្ដីថ្លែងការណ៍នេះបានបង្ហាញអំពីបំណងរបស់ ខៀវ សំផន ក្នុងការកំណត់គោលដៅអ្នករស់នៅក្នុងទីក្រុងភ្នំពេញ និងការញុះញង់អំពើហិង្សាប្រឆាំងប្រជាជនទាំងនោះ ដែលបក្សចាត់ទុកថាជាជនសង្ស័យនយោបាយ។ សេចក្ដីថ្លែងការណ៍ទាំងអស់នេះបង្ហាញអំពីតួនាទីសំខាន់របស់គាត់នៅក្នុងមជ្ឈិមបក្ស ហើយនិងការក្ដោបយកការប្រើប្រាស់នូវហិង្សានយោបាយប្រឆាំងនឹងប្រជាជនកម្ពុជា។ នេះមិនមែនជាពាក្យរបស់មេបញ្ជាការគ្មានដឹងអ្វីនោះទេ គឺជាពាក្យរបស់បុរសម្នាក់ដែលទទួលយកតួនាទីរបស់គាត់ក្នុងនាមជាមេតស្ម័ជនកុម្មុយនីស្ត ដែលគាត់ប្ដេជ្ញា និងប្ដូរផ្ដាច់នៅក្នុងផែនការ និងរបៀបវារៈរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១១:២១:២០]

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ៧៥ ប្រាំថ្ងៃក្រោយពីការជម្លៀសដោយបង្ខំបានចាប់ផ្ដើម ខៀវ សំផន បាននិយាយតាមវិទ្យុក្រុងភ្នំពេញថា៖ "នេះគឺជាមហាជោគជ័យជាប្រវត្តិសាស្ត្ររបស់ប្រជាជនប្រជាជាតិយើង។ វាបានបើកឲ្យមានផ្លូវត្រឹមត្រូវ និងភ្លឺស្វាងបំផុត ដឹកនាំប្រជាជនកម្ពុជា និងកងទ័ពប្រជាជនរំដោះជាតិកម្ពុជាក្នុងការលុកលុយសង្គ្រាមប្រជាជនប្រឆាំងនឹងខ្មាំងនៅគ្រប់សមរភូមិ ទទួលធ្វើការកម្ទេចជាបណ្ដើរ ហើយនិងការធ្វើការវាយប្រហារមិនឈប់ឈរ និងផ្ដាច់កម្លាំងហិរញ្ញវត្ថុ សេដ្ឋកិច្ច នយោបាយ យោធារបស់ខ្មាំង។ រួមទាំងស្រូវ និងម្ហូបអាហារ រហូតដល់ពួកគេដល់ចំណុចមួយរើលែងរួច។ ចុងក្រោយខ្មាំងស្លាប់យ៉ាងសោកសៅ"។ ពាក្យទាំងអស់នេះគឺសំខាន់ណាស់ វាបានបង្ហាញភស្តុតាងអំពី

ការគាំទ្ររបស់ ខៀវ សំផន យ៉ាងច្បាស់លាស់ទៅលើគោនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្រោយមកត្រូវបានអនុវត្ត។ ការជួលរលំទីក្រុងភ្នំពេញ និងការជម្លៀសទីក្រុងគឺជាមហាជោគជ័យដ៏អស្ចារ្យជាប្រវត្តិសាស្ត្រ។ គាត់បានលើកឡើងអំពីពាក្យទាំងអស់នេះ នៅពេលដែលគាត់បានដឹងតាមរយៈការទទួលស្គាល់របស់គាត់ថា ការជ្លៀសដោយបង្ខំលើប្រជាជនរាប់លាននាក់កំពុងតែកើតឡើង។

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេលនេះខ្ញុំសូមលើកឡើងអំពីឧក្រិដ្ឋកម្មជាក់លាក់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងការជម្លៀដោយបង្ខំដំណាក់កាលទី១។ វាបង្ហាញយ៉ាងច្បាស់ថាការជម្លៀសបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នួន ជា និង ខៀវ សំផន បានរៀបចំផែនការបញ្ជាការជម្លៀសដោយបង្ខំលើប្រជាជនរាប់លាននាក់ពីលំនៅដ្ឋានស្របច្បាប់របស់ពួកគេនៅក្នុងទីក្រុងភ្នំពេញដោយគ្មានមូលដ្ឋានស្របច្បាប់ ហើយមិនអនុញ្ញាតឲ្យពួកគេត្រឡប់មកលំនៅដ្ឋានរបស់ខ្លួនជារៀងរហូតក្នុងពេលដែលពួកគេកាន់អំណាច។ ដូចដែលលោកស្រី ជា លាង បានលើកឡើងរួចមកហើយភស្តុតាងទាំងអស់នោះមិនបានបង្ហាញជាមូលដ្ឋានស្របច្បាប់ក្រោមច្បាប់អន្តរជាតិ អនុញ្ញាតឲ្យបក្សកុម្មុយនីស្តកម្ពុជាជម្លៀសដោយបង្ខំលើទីក្រុងភ្នំពេញទាំងមូល ដោយយើងមិនទាន់គិតទីប្រជុំជនផ្សេងទៀតនៅក្នុងប្រទេសកម្ពុជានោះទេ។

[១១:២៣:៣៤]

លក្ខខណ្ឌដែលបានដាក់លើប្រជាជននៅក្នុងការជម្លៀស គឺជាអំពើមួយអមនុស្សធម៌ប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ វាគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបញ្ជូនប្រជាជនរាប់លាននាក់ទៅទីជនបទដែលក្តៅហែង ហើយឲ្យពួកគេដើរអស់រយៈពេលជាច្រើនថ្ងៃ ច្រើនសប្តាហ៍ ពេលខ្លះរហូតដល់ច្រើនខែ ដោយមិនមានរៀបចំការធ្វើដំណើរ និងការផ្តល់ម្ហូបអាហារ ទឹក ឬក៏ជំនួយខាងពេទ្យ។ ជនជាប់ចោទបានដឹងយ៉ាងច្បាស់អំពីលក្ខខណ្ឌអមនុស្សធម៌ ដែលអ្នកត្រូវបានជម្លៀសត្រូវបានបញ្ជូនចេញពីទីក្រុងទៅកាន់ទីជនបទ។ ការជម្លៀសបានធ្វើឡើង បានកំពុងតែធ្វើឡើងនៅពេលដែល នួន ជា និង ខៀវ សំផន ធ្វើដំណើរពីឧដុង្គទៅភ្នំពេញ។ ពួកគេបានឃើញផ្ទាល់ភ្នែកនូវការជម្លៀសដោយបង្ខំ។ ជាពិតទៅ នួន ជា បានរៀបរាប់នូវ ថេត សម្បត្តិ នូវអ្វីដែលគាត់បានឃើញក្នុងពេលដែលគាត់ធ្វើដំណើរទៅទីក្រុងភ្នំពេញ។ ជនដែលត្រូវបានជម្លៀសដើរតាមផ្លូវ មើលទៅស្លេកស្លាំង និងអស់កម្លាំង ហើយជួបប្រទះស្ថានភាពដ៏អាក្រក់នៅពេលធ្វើដំណើរ។ អ្នករស់នៅក្នុងទីក្រុងភ្នំពេញមិនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកទីក្រុង ឬទីប្រជុំជនវិញនោះទេក្នុងរយៈពេលបីឆ្នាំកន្លះ ដែលខ្មែរក្រហមកាន់អំណាច។

ផ្ទះរបស់ពួកគេត្រូវបានផាក់ប្តូន និកម្ទេច។ នេះគឺជាអំពើឧក្រិដ្ឋតាំងពីដើមដំបូងរហូតដល់ពេលបញ្ចប់។ ជនជាប់ចោទគ្មានមូលដ្ឋានសមហេតុណាមួយដែលបង្ហាញអំពីចំណុចនេះទេ។ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវឧក្រិដ្ឋរបស់ជនជាប់ចោទចំពោះការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត នួន ជា បានទទួលស្គាល់នៅក្នុងបន្ទប់សវនាការនេះថា សេចក្តីសម្រេចនិងបញ្ជារបស់មេដឹកនាំបក្សគឺថា អ្នករស់នៅទីក្រុងភ្នំពេញទាំងអស់ត្រូវតែចាកចេញពីទីក្រុងរួមទាំងអ្នកឈឺ មនុស្សចាស់ជរា អ្នកជំងឺក្នុងមន្ទីរពេទ្យគ្មានការលើកលែង។ ជនជាប់ចោទ និងមេបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតបានដឹងថា ការស្លាប់ក្នុងទ្រង់ទ្រាយធំនេះ គឺនឹងកើតឡើងដោយចៀសមិនផុតនៅពេលដែលពួកគេសម្រេចជម្លៀសអ្នកជំងឺមនុស្សចាស់ស្ត្រីមានផ្ទៃពោះ កូនក្មេងទើបនឹងកើត ឲ្យដើរទៅតាមទីជនបទក្នុងប្រទេសកម្ពុជាក្នុងខែចេត្រនៅឆ្នាំនោះដោយគ្មានបានផ្តល់នូវម្ហូបអាហារទឹក ឬក៏ថ្នាំសង្កូវនានា។

[១១:២៦:០១]

លោក លោកស្រីចៅក្រម បានស្តាប់ភស្តុតាងពីប្រជាជនដែលស្លាប់ក្នុងពេលជម្លៀសដោយបង្ខំនោះ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងបានទទួលស្គាល់ការដឹងឮអំពីការស្លាប់រាប់សែននាក់នេះ។ ខៀវ សំផន បានប្រាប់ចៅក្រមស៊ើបអង្កេតថា គាត់បានដឹងអំពីលទ្ធភាពដែលថាអាចមានការស្លាប់ក្នុងទ្រង់ទ្រាយធំក្នុងពេលជម្លៀសដោយបង្ខំ។ ខ្ញុំសូមដកស្រង់៖ "ពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុងភ្នំពេញខ្ញុំយល់ឃើញយ៉ាងច្បាស់ថាប្រជាជនអាចទំនងនឹងដួលនៅតាមផ្លូវ"។ នៅក្នុងវីដេអូមួយដែលយើងចាក់កាលពីថ្ងៃសុក្រ ខៀវ សំផន បានទទួលស្គាល់ថា ប្រជាជនជាច្រើនបានស្លាប់នៅពេលដែលការជម្លៀសនោះបានធ្វើឡើង។ អៀង សារី និងអ្វីដែលគាត់ហៅថា -- នូវអ្វីដែលយើងហៅថាជាការលើកឡើងមិនអស់សេចក្តី គាត់បានរៀបរាប់នូវអំពីការរំដោះក្នុងខែដំបូងថា វាពិបាកណាស់ហើយគាត់ទទួលស្គាល់ថាមនុស្សពីរពាន់ទៅបីពាន់នាក់ស្លាប់ក្នុងពេលជម្លៀសទីក្រុងភ្នំពេញហើយនិងរាប់ពាន់នាក់ទៀតស្លាប់នៅស្រែ។ អៀង ធីរិទ្ធ បានប៉ាន់ស្មានថា ប្រជាជនពីរម៉ឺននាក់ស្លាប់ដោយសារអត់អាហារ និងជំងឺនៅក្នុងឆ្នាំ៧៥ ដោយសារតែគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពាក់ព័ន្ធទៅនឹងការកាប់សម្លាប់មន្ត្រីលន់នល់ ក្នុងអំឡុងពេលជម្លៀស លោក លោកស្រីបានឃើញជាច្រើនដងរួចមកហើយអំពីបញ្ជាសម្លាប់ដែលចេញដោយ ខៀវ សំផន នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ហើយលោក លោកស្រីចៅក្រមក៏បានឃើញនិងមើលឃើញនៅតាមខ្សែវីដេអូដែល នួន ជា បានទទួលស្គាល់ថាជួរដឹកនាំនយោបាយបញ្ជាឲ្យកម្ទេចមេដឹកនាំសាធារណរដ្ឋខ្មែរកំពូល។

[១១:២៧:៥២]

លោក លោកស្រីចៅក្រម បានស្តាប់សក្ខីកម្មពីសាក្សីផ្ទាល់ភ្នែកដែលមានវត្តមាននៅពេលដែល ឡុង បូរ៉េត ចុះចាញ់នឹងកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជានៅក្រសួងព័ត៌មាន និងនៅពេលដែល សិរិមតៈ និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀតត្រូវបានបង្ខំដោយបក្សកុម្មុយនីស្តកម្ពុជាចាកចេញពីស្ថានទូតបារាំង។ អៀង សារី បានទទួលស្គាល់អំពីការកាប់សម្លាប់ ឡុង បូរ៉េត,សិរិមតៈ និងលន់នន់ នៅក្នុងពេលសន្និសីទសារព័ត៌មានចុងឆ្នាំ១៩៧៥។ ខៀវ សំផន និង នួន ជា ការទទួលខុសត្រូវរបស់ពួកគេសម្រាប់ការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរក្នុងពេលជម្លៀសទីក្រុងភ្នំពេញបានបង្ហាញហួសពីវិមតិសង្ស័យ។ ខ្ញុំនឹងលើកឡើងអំពីការទទួលខុសត្រូវរបស់ពួកគេលើការកាប់សម្លាប់ទាហានមន្ត្រីសាធារណរដ្ឋខ្មែរ នៅពេលដែលខ្ញុំលើកឡើងពិភាក្សាអំពីទួលពោធិ៍ជ្រៃនាពេលក្រោយ។

សហព្រះរាជអាជ្ញាបានបង្ហាញហួសពីវិមតិសង្ស័យថា ជនជាប់ចោទទាំងពីរមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេសពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំលើប្រជាជនទីក្រុងភ្នំពេញ។ នៅពេលនេះខ្ញុំលើកឡើងអំពីការជម្លៀសដោយបង្ខំដំណាក់កាលទីពីរ។ លោកស្រី ជាលាង –សហសេវិករបស់ខ្ញុំ–បានលើកឡើងលម្អិតអំពីភស្តុតាងពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ។ យោងទៅលើឯកសារដែលគាត់លើកឡើង ហើយក្នុងនោះខ្ញុំនឹងបង្ហាញដូចដែលពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុង និងការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ ហើយខ្ញុំនឹងបង្ហាញអំពីការជម្លៀសដោយបង្ខំដំណាក់កាលទីពីរដែលបានចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ការជម្លៀសដោយបង្ខំដំណាក់កាលទីពីរគឺកើតចេញពីលទ្ធផលដោយផ្ទាល់នៃសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំង នួនជា និង ខៀវ សំផន។ សហសេវិករបស់ខ្ញុំក៏បានលើកឡើងថា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតរដ្ឋទាសករដំបូងនៅក្នុងយុគសម័យទំនើប។ គ្រប់ទិដ្ឋភាពនៃរដ្ឋទាសករត្រូវបានដំណើរការនិងគ្រប់គ្រង ក្រោមការសម្លឹងមើលដោយចិត្តទុកដាក់ពីមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ រដ្ឋទាសកររបស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំប្រព័ន្ធឧក្រិដ្ឋបន្តជាដរាបនៃការធ្វើទុក្ខបុកម្នេញ ការដាក់ឲ្យទៅជាទេសភាព ការបង្ខំ -- ការជម្លៀសដោយបង្ខំ ពលកម្មដោយបង្ខំ ការប្រព្រឹត្តអមនុស្សធម៌ និងការធ្វើមនុស្សឃាតដែលធ្វើឡើងជាចម្បងលើប្រជាជនថ្មី។ វាបន្តរហូតដល់ថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩។ ឧក្រិដ្ឋកម្មទាំងអស់នេះប្រព្រឹត្តក្នុងពេលដែលមានប្រព័ន្ធដាក់ឲ្យទៅជាទេសភាព ដែលត្រូវបានរៀបចំគ្រោង និងត្រួតពិនិត្យគ្រប់គ្រងដោយ នួន ជា, ខៀវ សំផន និងសហការីដទៃទៀត។ គាត់ទាំងអស់នេះ បានរៀបចំឡើង និង

អនុវត្តតាមរយៈឋាននុក្រមតឹងរ៉ឹង និងរឹងប៉ឹង ឋាននុក្រម ដែលកម្មាភិបាល និងកងកម្លាំងយោធាទទួលបញ្ជាពីថ្នាក់លើ និងក្រោយមកឆ្លើយតបទៅនឹងបញ្ជាទាំងអស់នេះ ដែលមជ្ឈិមបក្សដាក់ចុះមក។ នេះគឺជាការបង្ហាញនូវភស្តុងដ៏ច្រើនអំពីប្រព័ន្ធរាយការណ៍នឹងប្រព័ន្ធទំនាក់ទំនង ដែលខ្ញុំបានលើកឡើងកាលពីសប្តាហ៍មុន។

[១១:៣១:១៩]

ភស្តុតាងទាំងអស់នេះ ក៏បានបញ្ជាក់ដោយភស្តុតាងអ្នកជំនាញ នៅក្នុងសក្ខីកម្មរបស់លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ គាត់បានរៀបចំអំពីរចនាសម្ព័ន្ធដែលថាវាមានលក្ខណៈជាពីរ៉ាមីត គឺបញ្ជាចុះមកពីលើ។ វាជារចនាសម្ព័ន្ធពីរ៉ាមីត គ្រប់ទាំងអស់ គឺគោរពទៅតាមលើរហូតដល់ក្រោម ហើយវាជាថ្នាក់ដឹកនាំសមូហភាព។ វាគឺជាកម្លាំងវុញច្រានរបស់អង្គការ។ បានន័យថា គឺខាងក្រោមគោរពតាមខាងលើ។ ដូច្នេះ បានន័យថាបញ្ជាទាំងអស់នេះ គឺថាវាមានការគោរពពីថ្នាក់ក្រោម ពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។ ហ្វីលីព ស្សូត បានលើកឡើងអំពីចំណុចនេះ "វាកើតចេញមកពីខាង ហើយវាកើតពីថ្នាក់ខាងលើ។ គោលការណ៍គឺវាដូចគ្នាគ្រប់ទីកន្លែង គ្រប់គ្នាទាំងអស់ គឺបានន័យថា អ្នកដែលភាគច្រើននេះគឺជាក្រុមតូចមួយ។ អ្នកដែលភាគច្រើននេះ គឺថាគឺជាអ្នកកម្មករ ហើយក្រុមតូចមួយនោះ គឺទទួលនូវបុព្វសិទ្ធិ ៩៩ភាគរយនៃប្រជាជនគឺថាមហាជនដែលមានចំនួនភាគច្រើនោះ គឺជាទាសករ។ ពួកគេគ្មានជម្រើសគ្រប់ទិដ្ឋភាពរបស់ពួកគេ លើជីវិតរបស់ពួកគ"។

នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង រឿងរ៉ាវដែលកើតឡើងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ជាពិសេសការជម្លៀសនោះ គឺកើតចេញពីប្រព័ន្ធនៃការដាក់ជាទាសករ។ ការជម្លៀសដោយបង្ខំដំណាក់ទី២ គឺជាការបន្តអនុវត្តប្រព័ន្ធនេះតែប៉ុណ្ណោះ។ វាមិនមែនជាការជម្លៀសដោយបង្ខំដំណាក់កាលទី១ ទៅលើប្រជាជននោះទេ។ បក្សកុម្មុយនីស្តកម្ពុជា ប្រព័ន្ធពលកម្មដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រព័ន្ធនៃការជម្លៀសដោយបង្ខំ គឺបានអនុវត្តនៅពេញនៅពេលដែលពួកគេកាន់អំណាច។ នៅពេលដែលមេដឹកនាំសម្រេចកម្មវិធីទាសកររបស់គេ ត្រូវធ្វើឡើងចំពោះប្រជាជននៅតំបន់ជាក់លាក់។ ពួកគេបានជម្លៀសដោយបង្ខំ ហើយបានបង្កើតរឿងរ៉ាវ និងការធ្វើទុក្ខបុកម្នេញ និងការប្រព្រឹត្តធ្វើបាបទៅលើប្រជាជនថ្មី។ នៅក្នុងប្រព័ន្ធនេះ ការជម្លៀសដោយបង្ខំដំណាក់កាលទី២ បានអនុវត្តស្របទៅតាមសេចក្តីសម្រេចសំខាន់ៗធ្វើឡើងដោយមេដឹកនាំជាន់ខ្ពស់ នៅចន្លោះខែឧសភា និងខែកញ្ញា ឆ្នាំ៧៥។ ដូចដែរសហសេវិកបានបង្ហាញ នៅក្នុងខែឧសភា ឆ្នាំ៧៥ មេដឹកនាំបានជួបនៅព្រះវិហារព្រះកែវមរកត នៅក្នុងរយៈពេល

១០ថ្ងៃ។ ពេលនោះ នួន ជា និង ខៀវ សំផន បានចូលរួម។ កិច្ចប្រជុំបានសម្រេចថា ភូមិភាគបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ តំបន់ទាំងអស់ ស្រុកទាំងអស់ ត្រូវតែកំណត់ជនភៀសខ្លួននៅក្នុងសហ -- ជនដែលជម្លៀសនៅក្នុងសហករណ៍ដែលពួកគេត្រូវតែស្ថិតនៅក្នុងក្រោមប្រព័ន្ធពលកម្មដោយបង្ខំ។ ដូចដែល ខៀវ សំផន បានផ្តល់សក្ខីកម្មនៅចំពោះលោក លោកស្រីចៅក្រម ការសំខាន់នោះ គឺធ្វើយ៉ាងណាឲ្យដើរលឿនជាងវៀតណាម។ គំនិតក្នុងការការពារប្រទេសប្រឆាំងនឹងការគំរាមកំហែង គឺផ្អែកទៅលើការភ័យខ្លាចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអំពីការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា -- បក្សកុម្មុយនីស្តវៀតណាមមកលើកម្ពុជា។

[១១:៣៤:៤៥]

សូមកុំជឿទៅលើក្រុមមេធាវីការពារក្តីនៅពេលដែលគេលើកឡើងថា នេះគឺជាកម្មវិធីដើម្បីធ្វើឡើងផ្តល់អំណាចទៅលើប្រជាជន និងលើកកម្ពស់ការរស់នៅរបស់ប្រជាជន។ កម្មវិធីនេះធ្វើឡើងតាមរយៈឧក្រិដ្ឋកម្មរួមទាំងការធ្វើឲ្យទៅជាទាសករ ការជម្លៀសដោយបង្ខំ ការដាក់ឲ្យធ្វើការងារដោយបង្ខំ និងការធ្វើមនុស្សឃាត។ កម្មវិធីឧក្រិដ្ឋទាំងអស់នេះបានកើតឡើងតាមការសម្រេចចិត្តរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលពួកគេគឺជាចៅហ្វាយនៃគ្រប់ទិដ្ឋភាពជីវិតនៅក្នុងប្រទេស។ ពួកគេអនុវត្តកម្មវិធីឧក្រិដ្ឋដោយឃោរឃៅ ពួកគេសម្រេចអ្នកណាត្រូវរស់ អ្នកណាត្រូវស្លាប់ ពួកគេសម្រេចកន្លែង និងរបៀបដែលទាសកររបស់ពួកគេរស់នៅ តើពួកទាសកររបស់ពួកគេនោះត្រូវទទួលបានអាហារប៉ុនណា ហើយការងារបង្ខំប៉ុនណាដែលទាសកររបស់ពួកគេត្រូវធ្វើ រួមទាំងអ្វីដែលពួកទាសកររបស់ពួកគេត្រូវគិត។ ប្រជាជនត្រូវបានបន្ថយតម្លៃរបស់ពួកគេដូចរបស់មានតម្លៃ។

[១១:៣៥:៥៥]

នៅក្នុងសេចក្តីលោកស្រី ជា លាង បានលើកឡើងអំពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នៅក្នុងខែសីហា ឆ្នាំ១៩៧៥ ទៅភូមិភាគពាយ័ព្យ។ នេះរបាយការណ៍នេះត្រូវបានបង្ហាញថា ប្រជាជន ៤០០.០០០នាក់ ទៅ ៥០០.០០០នាក់ ត្រូវបានគេដកទៅពាយ័ព្យ។ វាបានកត់ត្រានូវបេសកកម្មស្វែងរកការពិត បេសកកម្មក្នុងការកំណត់រដ្ឋដែលមានកម្មវិធីទាសករនៅក្នុងពាយ័ព្យ។ ឯកសារនេះបានបង្ហាញឲ្យមេដឹកនាំ ហើយក៏បានជម្រាបមេដឹកនាំអំពីស្ថានការណ៍នៅក្នុងភូមិភាគនានា។ នៅក្នុងឯកសារនេះមេដឹកនាំបានបង្ហាញដោយគ្មានស្ទាក់ស្ទើរថា អ្នកដែលត្រូវបានជម្លៀសគ្មានសេរីភាពដើរហើរ មេដឹកនាំលើកឡើងថា កម្មាភិបាលល្អគឺជាអ្នកដែលគ្រប់គ្រងប្រជាជននៅសហករណ៍ ដូច្នេះពួកគេមិនអាចដើរដោយ

សេរី។ ខ្ញុំសូមដកស្រង់៖ "កម្មាភិបាលមានលទ្ធភាពគ្រប់គ្រងប្រជាជនជាមធ្យម ប៉ុន្តែជាពិសេសនៅកន្លែងខ្លះ គេសង្កេតឃើញថាកន្លែងដែលមានកម្មាភិបាលដឹកនាំល្អ មានថ្នាក់ដឹកនាំស្លូតប្រជាជនមានលំនឹង និងកន្លែងដែលមិនមានកម្មាភិបាល ឬក៏មិនមានថ្នាក់ដឹកនាំដែលនឹកនរនោះឃើញប្រជាជនដើរហើរដោយសេរី"។ ដូច្នេះសេរីភាពដើរហើរគឺជាសញ្ញាមួយនៃការដឹកនាំមិនល្អ ដោយកម្មាភិបាលមូលដ្ឋាន។ មេដឹកនាំក៏បានទទួលស្គាល់ថា ការខ្វះខាតធ្ងន់ធ្ងរគឺបានធ្វើឡើងចំពោះប្រជាជនថ្មីដែលត្រូវបានគេជម្លៀសដោយបង្ខំពីទីក្រុង និងទីជនបទ។ ឯកសារបានលើកឡើងថា "ប្រជាជនថ្មីបានឆ្លងកាត់ការខ្វះខាតអាហារ ការខ្វះខាតអាហារផ្គត់ផ្គង់ រួមទាំងការខ្វះខាតនូវថ្នាំសង្កូវ ប្រជាជនជាច្រើនដែលរស់នៅខាងលិចល្វានៅតាមស្ទឹងមង្គលបុរី មានជំងឺក្តៅខ្លួន"។ ឯកសារនេះគឺគ្មានបញ្ហាជាក់លាក់ណាមួយ ដើម្បីបន្ថយស្ថានភាពអាក្រក់នេះទេឬដើម្បីជួយប្រជាជន និងឲ្យប្រជាជនមានសេរីភាព ដើម្បីជួបជុំជាមួយគ្រួសារដាំស្ល៉ុះនូវម្ហូបអាហារ និងទទួលនូវការព្យាបាលនោះទេ។ ហើយក៏គ្មានការលើកឡើងណាមួយអនុញ្ញាតឲ្យប្រជាជនត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួននៅក្នុងទីក្រុង និងទីជនបទ និងទីប្រជុំជននោះផងដែរ។

[១១:៣៨:២៨]

ផ្ទុយទៅវិញ អំពើទាសករត្រូវបានគេបន្តលើកឡើង ទោះបីជាមានការខ្វះខាត និងជំងឺដង្កាត់ក៏ដោយ។ យើងឃើញថាក្រុមមេធាវីការពារក្តីនឹងលើកឡើងថា ឯកសារនេះបង្ហាញថា "មេដឹកនាំពិតជាបានធ្វើឲ្យជីវភាពរបស់ប្រជាជនប្រសើរ" ក៏ប៉ុន្តែអ្វីដែលច្បាស់នោះ គឺថាពិភាក្សានៃការជួយទៅលើទាសករគឺធ្វើឡើងដើម្បីធានាយ៉ាងណាធានាកុំឲ្យមានអ្នកប្រឆាំងនឹងបដិវត្តន៍តែប៉ុណ្ណោះ។ ខ្ញុំសូមដកស្រង់៖ "ដើម្បីអាចការពារប្រទេសឲ្យមានប្រសិទ្ធភាព ការរស់នៅរបស់ប្រជាជននៅតាមសហករណ៍ត្រូវតែដោះស្រាយ យើងព្យាយាមដោះស្រាយបញ្ហាសម្រាប់ប្រជាជនថ្មីផង ដើម្បីឲ្យពួកគេពេញចិត្តជាមួយនឹងបដិវត្តន៍យើង ហើយធ្វើឲ្យពួកគេមើលឃើញថារបបនេះ គឺជារបបមួយសម្រាប់ពួកគេ។ ដូច្នេះដើម្បីកុំឲ្យពួកគេនោះមានបំណងរត់ចេញទីកន្លែងផ្សេង"។ បញ្ចប់ការដកស្រង់។

[១១:៣៩:២៨]

លោក លោកស្រី ចៅក្រមជាទីគោរព! សូម្បីនៅក្នុងអត្ថបទដែលមេដឹកនាំបានពិភាក្សាអំពីលទ្ធភាពក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនថ្មី ពួកគេទទួលស្គាល់ថា អ្នកទាំងអស់នោះគឺជាអ្នកទោស ទាសករ ផ្តល់អាហារឲ្យពួកគេ គឺដើម្បីកុំឲ្យពួកគេហ្នឹងមានបំណងរត់ទៅកន្លែងផ្សេង។

ក៏ប៉ុន្តែមេដឹកនាំក៏បានបញ្ជាក់ច្បាស់អំពីចេតនាជាហូរហែរបស់ពួកគេ ដើម្បីធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មី។ សូមមើលអត្ថបទមួយទៀត ដែលខ្ញុំសូមដកស្រង់៖ "មុខងាររបស់សហករណ៍ចាប់តាំងពីពេលរំដោះទាំងស្រុង គឺដើម្បីយកប្រមូលយកប្រជាជនថ្មីទាំងអស់ដែលមកពីទីក្រុង និងទីប្រជុំជន ជាពិសេសក្រុងភ្នំពេញ និងខាងពាយ័ព្យបាត់ដំបង។ ធាតុដែលអាក្រក់ៗគ្រប់ប្រភេទមាននៅក្នុងចំណោមប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបង ក៏ប៉ុន្តែសហករណ៍បានប្រមូលពួកគេទាំងស្រុង ដោយផ្តល់អាហារទៅដល់ពួកគេ ហើយជាពិសេសគឺផ្តល់កម្លាំងឲ្យពួកគេធ្វើការ។ កម្លាំងអំណាចរបស់សហករណ៍ គឺធំធេងហើយខ្លាំងក្លាណាស់"។

[១១:៤០:៤៩]

លោក លោកស្រីចៅក្រមជាទីគោរព! អត្ថបទនេះ គឺមានចំណុចលើកឡើងសំខាន់ៗដែលបង្ហាញអំពីចេតនាឧក្រិដ្ឋ។ ទី១ មុខងាររបស់សហករណ៍ គឺដើម្បីប្រមូល បានន័យថាគឺដាក់ឃុំប្រជាជនថ្មី។ ប្រជាជនថ្មីជាក្រុមនេះ ត្រូវតែស្ថិតនៅក្នុងក្រោមប្រព័ន្ធរបស់គេ ដែលគេត្រួតត្រា ពីព្រោះថាសមាសភាពមិនល្អគ្រប់ប្រភេទ ឃើញមាននៅក្នុងចំណោមពួកគេ និងទី៣ ប្រជាជនថ្មីត្រូវបានគេបង្ខំឲ្យធ្វើការងារដោយបង្ខំ ដែលដូចដែលគេលើកឡើងថា ផ្តល់កម្លាំងឲ្យធ្វើការ។ ក្នុងន័យមួយទៀត មេដឹកនាំបានអនុវត្តនិងកំពុងតែប្រព្រឹត្តនូវការត្រួត្រាជាកម្មសិទ្ធិទៅលើគ្រប់មនុស្ស គ្រប់ជីវិតអ្នកជម្លៀស។ នេះជានិយមន័យខុសគ្នានៃអំពើទាសភាព។ ឯកសារនេះ ស៊ីសង្វាក់ជាមួយនឹងភស្តុតាងផ្សេងទៀតដែលយើងបានពិភាក្សាក្នុងរយៈពេលបីថ្ងៃចុងក្រោយនេះ គឺឃើញមានប្រព័ន្ធធ្វើទុកបុកម្នេញបានបង្កើតឡើងដើម្បីដាក់ធ្វើបាបទៅលើប្រជាជនថ្មី។ ប្រជាជនទាំងអស់នេះត្រូវបានគេសង្កត់សង្កិន គាបសង្កត់ ហើយត្រូវបានគេរឹតត្បិតឲ្យរស់នៅតែក្នុងសហករណ៍ ហើយបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ខណៈពេលដែលពួកគេត្រូវបានគេត្រួតពិនិត្យស្រាវជ្រាវរកសមាសភាពមិនល្អនៅក្នុងចំណោមពួកគេ គឺសមាសភាពដែលត្រូវលុបចោលផ្តាច់ជីវិតជាបន្ទាន់។ នៅពេលដែលសាស្ត្រាចារ្យ ឆេនដ័ល័រ ផ្តល់សក្ខីកម្មនៅចំពោះមុខលោក លោកស្រីចៅក្រម យើងបានសួរគាត់ឲ្យរៀបរាប់អំពីគោលបំណងនៃការបែងចែកប្រជាជន ទៅជាប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំគិតថា គិតឲ្យងាយៗទៅវាជាវិធីក្នុងការកំណត់និយមន័យទៅលើប្រជាជន ដែលគេហៅថា "យើងនិងពួកគេ"។ បានន័យថា "អ្នកឈ្នះនិងអ្នកចាញ់"។ ជាមូលដ្ឋាន អ្នកបដិវត្តន៍ និងប្រជាជនដែលចាញ់។ ទាំងអស់នេះ គឺមានន័យ មានសទិសសន័យដូចគ្នា។ ភាសាដែលគេប្រើក្នុងពាក្យខ្មែរក្រហម គឺវាហាក់ដូចជាទន់ជ្រាយ បត់បែន។ ដូច្នេះ គេមិនប្រើពាក្យហ្នឹង

ឲ្យវាឃោរឃៅនោះទេ។ គេប្រើពាក្យ "១៧មេសា ឬថ្មី" ដើម្បីយកមកច្របាច់បញ្ចូលគ្នា។ ប៉ុន្តែខ្ញុំគិតថា ពួកគេដឹងច្បាស់ថា ពួកគេមិនមែនជាអ្នកថ្មី មិនមែន ១៧មេសា នោះទេ។ ពួកគេគឺជាខ្មាំងដែលត្រូវបានគេកំណត់គោលដៅ។ ពួកគេអាចធ្វើការកំណត់គោលដៅ ហើយប្រសិនបើគេមិនជឿទុកចិត្តពួកគេទេ បានន័យថា នៅពេលនោះពួកគេនឹងតាមដានមើលអ្នកទាំងអស់នោះជារៀងរហូត។

[១១:៤៣:៣៩]

លោកសាស្ត្រាចារ្យ ឆេនដ៏ល័រ គាត់លើកឡើងចំណុចចំតែម្តងដែលយើងយល់ឃើញថា វាមានសារៈសំខាន់ "យើងមិនត្រូវមើលត្រឹមតែពាក្យដែលមេដឹកនាំប្រើប្រាស់នោះទេ។ យើងត្រូវតែមើលលើប្រព័ន្ធភ័យខ្លាច និងប្រព័ន្ធទាសករដែលពួកគេអនុវត្ត។ នេះគឺជាបរិបទមួយដែលគណៈអចិន្ត្រៃយ៍បានសម្រេចតាមរយៈសេចក្តីសម្រេចសាមញ្ញរបស់ខ្លួនថា ប្រជាជនកន្លះលាននាក់ត្រូវតែផ្លាស់ទីលំនៅទៅពាយ័ព្យ។ កម្លាំង -- កងកម្លាំងពលកម្មត្រូវតែបង្កើនបីឬបួនពាន់ -- ៣ឬ៤០០.០០០នាក់មិនគ្រប់គ្រាន់នោះទេ។ ប្រព័ន្ធបច្ចុប្បន្ន ១លាននាក់ អាចធ្វើការបានតែ៥០ភាគរយ។ ដូច្នេះត្រូវបន្ថែម ៤ឬ៥០០.០០០នាក់។ លោក លោកស្រីចៅក្រម នៅពេលដែលយើងឃើញស្ថានភាពនៅពាយ័ព្យ នៅពេលដែលយើងឃើញ ទទួលស្គាល់ថាអ្នកដែលត្រូវបានជម្លៀសទទួលរងការខ្វះខាតម្ហូបអាហារ ជំងឺដង្កាត់ នៅពេលដែលយើងទទួលស្គាល់ថា ប្រជាជនទាំងអស់នៅពាយ័ព្យនោះអាចបំពេញការងារត្រឹមតែ៥០ភាគរយ ពួកគេបានសម្រេចបន្ថែមកន្លះលានលាក់ទៀត។ មិនមែនពាក្យដែលផ្តល់ -- ពាក្យដែលលើកឡើងថា ផ្តល់ម្ហូបអាហារគ្រប់គ្រាន់ ទឹក ថ្នាំសង្កូវ ឬទីជម្រកឲ្យពួកគេនោះទេ"។ សេចក្តីសម្រេចនោះ គឺដើម្បីផ្លាស់ទីលំនៅជម្លៀសពួកគេ ដូចដែលលោក លោកស្រី ឃើញតាមរយៈសារណាសេចក្តីសន្និដ្ឋានរបស់លោកស្រី ជា លាង ការជម្លៀសដោយបង្ខំនេះគឺធ្វើឲ្យមនុស្សជាច្រើននាក់ស្លាប់ និងទុក្ខសោក។ កំណត់ហេតុគណៈអចិន្ត្រៃយ៍មួយនេះ គឺក៏បានបង្ហាញថាការស្រាវជ្រាវរកខ្មាំងផ្ទៃក្នុង គឺនៅតែអាទិភាពកំពូលរបស់មេដឹកនាំ។ ករណីដែលប្រជាជនព្យាយាមរត់គេចចេញពីជំរំទាសករនេះ នៅក្នុងក្រសែភ្នែករបស់គណៈអចិន្ត្រៃយ៍ គេយល់ឃើញថាអ្នកទាំងអស់នោះ គឺជាខ្មាំងដែលត្រូវតែរកយកមកកម្ទេចចោល។ ខ្ញុំសូមដកស្រង់៖ "នៅក្នុងជួររបស់យើង ឃើញមានអ្នកដែលមិនទាន់ត្រូវបានបោសសម្អាត។ ពួកគេប្រើដើម្បីនាំប្រជាជនរត់ចេញ យើងអាចចាប់ពួកគេបាននៅពេលនេះមួយម្តងៗ ហើយនៅពេលនេះយើងបន្តស្វែងរកពួកគេទៀត។ ប្រជាជននៅពេលនោះបានរត់គេចខ្លួន ពួកគេគឺជាខ្មាំង យើងបានចាប់ច្រើនហើយ យើងបន្តបោសសម្អាតពួកវាទៀត"។

[១១:៤៦:២២]

លោក លោកស្រីចៅក្រម មេធាវីការពារក្តីបានបញ្ជាក់ថា ទាំង នួន ជា និង ខៀវ សំផន មិនមានអ្វីពាក់ព័ន្ធនឹងសេចក្តីសម្រេចនេះទេ។ នេះការពិតហើយដែលថា ខៀវ សំផន នៅខាងក្រៅ នៅចុងខែសីហា ឆ្នាំ១៩៧៥ ជាមួយលោក អៀង សារី។ ពួកគេស្ថិតនៅដំណើរការទស្សនកិច្ចដ៏សំខាន់នៅចិន និងកូរ៉េ និយាយអំពីការធានាឲ្យសម្តេច សីហនុ ត្រឡប់មកកម្ពុជា។ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៥ គាត់មកវិញ នួន ជា អះអាងថាគាត់មិនបានចូលរួមក្នុងដំណើរការទៅខាងភូមិភាគពាយ័ព្យទេ ដែលធ្វើឲ្យគាត់ថា ការអះអាងនេះ សេចក្តីសម្រេចក្នុងការបញ្ជូនប្រជាជនទៅភូមិភាគឧត្តរ និងពាយ័ព្យនោះគឺត្រូវបានធ្វើឡើងដោយភូមិភាគ ដែលយើងនឹងបានឃើញភស្តុតាងមួយចំនួនបង្ហាញផ្ទុយពីនេះវិញទេ។

ជាបឋមសមាជិកមជ្ឈិមនៃបក្សទាំង នួន ជា និង ខៀវ សំផន បានដឹងអំពីសេចក្តីសម្រេចនេះ។ មិនមែនជាភស្តុតាងណាមួយដែលបង្ហាញថា ពួកគេនៅឆ្ងាយពីពួកនេះ ពួកគេសួរ ហើយនិងប្តូរសេចក្តីសម្រេចទេ។ ជាពិសេសទៅទៀត ពួកគេជាមេដឹកនាំស្ថិតនៅក្នុងប្រព័ន្ធនៃអំពើធ្វើទុក្ខបុកម្នេញ អំពើទាសករ ការផ្ទេរប្រជាជនពីកន្លែងមួយទៅកន្លែងមួយ។ ហើយការចូលរួមរបស់ពួកគាត់នេះសំខាន់ណាស់ ទាក់ទងទៅនឹងឯកសារមួយចំនួនដែលយើងបានពិភាក្សា។

សេចក្តីសម្រេចរបស់មជ្ឈិមបក្សនៅក្នុងការសម្រេចឲ្យមានការជម្លៀសទី២ ហ្នឹងបានកត់ត្រានៅក្នុងឯកសារខែកញ្ញា ឆ្នាំ១៩៧៥ ដែលមានចំណងជើងថា ,ឯកសារលេខ៣, "ការពិនិត្យមើលការត្រួតត្រា ហើយនិងការអនុវត្តមាគ៌ាបក្ស មាគ៌ានយោបាយក្នុងការស្តារសេដ្ឋកិច្ច ហើយនិងរៀបចំកសាងប្រទេសគ្រប់វិស័យទាំងអស់"។ ដើម្បីងាយស្រួលក្នុងការយោង ខ្ញុំនឹងយោងទៅរកឯកសារលេខ៣នេះ។

[១១:៤៨:២៣]

នៅក្នុងសៀវភៅរបស់គាត់និយាយពីរបប ប៉ុល ពត លោក ប៉ែន យៀវនិន បានយោងឯកសារថ្ងៃទី១៩ កញ្ញា ១៩៧៥ ម្យ៉ាងទៀត១០ថ្ងៃក្រោយលោក ខៀវ សំផន និង អៀង សារី បានត្រឡប់មកប្រទេសវិញ។

ចំណងជើងទាំងស្រុងនៃឯកសារលេខ៣ ក៏ស្ថិតនៅក្នុងបរិបទនេះដែរ បង្កើតជាខ្លឹមសារដែលបញ្ជាក់ឲ្យច្បាស់ថាឯកសារដែលបានចេញនេះជាសមូហភាព ដោយមជ្ឈិមបក្ស។ ឯកសារមានការពិភាក្សាពិស្តារអំពីបញ្ហាសំខាន់ៗនយោបាយមួយចំនួន ដូចជាការស្រូបយកមាគ៌ាបក្ស ចាប់តាំងពីគណៈមជ្ឈិមប្រជុំកាលពីខែឧសភា ឆ្នាំ១៩៧៥ អំពីការផលិតផលស្រូវ អំពីការលុបបំបាត់លុយកាក់ ការសង់

ទំនប់ប្រឡាយ ហើយនិងការបង្ខំប្រជាជនឲ្យផ្លាស់ប្តូរទីលំនៅតាមភូមិភាគ។ សេចក្តី -- សភាពការណ៍នៅក្នុងប្រទេស ហើយនិងបញ្ហាមួយចំនួនទាក់ទងទៅនឹងកិច្ចការមួយចំនួនក្រសួងនានានៅក្នុងភ្នំពេញផងដែរ។ គ្មានស្ថាប័នណាមួយ អង្គភាពណាមួយ អង្គការណាមួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ក្រៅពីមជ្ឈិមបក្សមានអំណាច និងធ្វើការលើបញ្ហាទូលំទូលាយសំខាន់បែបនេះទេ។ អង្គហេតុដែលថាឯកសារដែលចេញពីមជ្ឈិមបក្ស គឺស៊ីសង្វាក់ទៅនឹងភស្តុតាងផ្សេងៗទៀត។

[១១:៤៩:៥៦]

នៅក្នុងបទសម្ភាសន៍១៩៨៦ របស់ ស្ទីវ ហេដឌ័រ លោកអៀង សារី បានបញ្ជាក់ថា នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានប្រជុំពិភាក្សាលើបញ្ហាសំខាន់ៗមួយចំនួន។ ការប្រជុំនោះគឺមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, សុន សេន , វន វ៉េត, កុយ ធួន, រស់ ញឹម ហើយនិងកម្មាភិបាលមេបញ្ជាការយោធាផ្សេងទៀតបានចូលរួម។ ការប្រជុំនោះគឺបានសម្រេចអនុវត្តនូវផ្តាច់ការវណ្ណៈអធនដាច់ខាត។ បញ្ហាដែលពិភាក្សានោះ គឺពិភាក្សាអំពីការសាងសង់ទំនប់និងអយស្ម័យយាន ហើយនិងបញ្ហាឧស្សាហកម្មធុនធ្ងន់ផងដែរ។ លោក លោកស្រីចៅក្រម! លោកអៀង សារី បាននិយាយថា នៅក្នុងកិច្ចប្រជុំខែកញ្ញាហ្នឹងគឺមិនបានពិភាក្សាអំពីការជម្លៀសលើកទីពីរទេ។ នេះគឺយើងយល់ឃើញថា គឺយើងយល់ថាជាការនិយាយមិនពិតទេ ពីព្រោះលោក អៀង សារី មិនចង់ទទួលស្គាល់អំពីការចូលរួមក្នុងការបទឧក្រិដ្ឋដ៏ទំលំទូលាយនេះទេ។ ផ្ទុយទៅវិញ ការបញ្ជាក់របស់លោក អៀង សារី ទាក់ទងទៅនឹងការប្រជុំហ្នឹង ទាក់ទងទៅនឹងប្រភពដើមហើយហ្នឹងអ្នកនិពន្ធនៃឯកសារលេខ៣នេះឯង។ លោក អៀវ សារី បានបញ្ជាក់ថា នួន ជា, ខៀវ សំផន ហើយនិងមេដឹកនាំផ្សេងទៀតនៅភ្នំពេញ នៅខែកញ្ញា ឆ្នាំ១៩៧៥ បានជួបហើយនិងពិភាក្សា សេចក្តីសម្រេចនយោបាយសំខាន់ៗសម្រាប់អនុវត្តទូទាំងប្រទេស។ បញ្ហាមួយចំនួនដែលទាក់ទងនឹងការរៀបរាប់របស់លោក អៀង សារី មាននៅក្នុងឯកសារបី គឺការផ្តាច់ការរបស់បក្ស ការកសាងនូវអយស្ម័យយាន និងទំនប់។ យើងសូមជម្រាបថា ចម្លើយរបស់លោក អៀង សារី គាំទ្រនូវសេចក្តីសន្និដ្ឋាននេះគឺឯកសារលេខ៣ គឺជាលទ្ធផលនៃសេចក្តីសម្រេចរបស់មជ្ឈិមបក្សដែល នួន ជា និងខៀវ សំផន បានចូលរួមនោះផង។

[១១:៥២:០៤]

លោកប្រធាន ឥឡូវនេះខ្ញុំនឹងនិយាយអំពីខ្លឹមសារនៃឯកសារលេខ៣ ឲ្យបានពិស្តារ។ ដូចកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ឆ្នាំ១៩៧៥ ខែសីហា ដែរ ឯកសារបីនេះទទួលស្គាល់ថា គេបានដាក់ប្រជា

ជនឲ្យទៅជាទាសករ ហើយនិងពលកម្មដោយបង្ខំ ហើយនិងរងការខ្វះខាតស្បៀងអាហារផងដែរ។ ឥឡូវនេះខ្ញុំសូមដកស្រង់៖ "ចលនាមនុស្សដ៏ច្រើនគឺជាការអនុវត្តនូវមាគ៌ាកសិកម្មរបស់បក្ស គឺបួន-ប្រាំខែកន្លងមកគឺខែឧសភា ឆ្នាំ៧៥។ បក្សហើយនិងប្រជាជនយើងព្យាយាមអនុវត្តមាគ៌ានេះដើម្បីដោះស្រាយនូវកង្វះខាតស្បៀងអាហារហើយនិងទិដ្ឋភាពជីវិត ហើយយើងដោះស្រាយសត្វពាហនៈ ស្បៀង អាហារ ទឹក ជាដើម។ បន្តទៅទៀត នៅកន្លែងខ្លះនៅពេលដែលមានកម្លាំងប្រជាជនប្រមូលផ្តុំដែលគេបានផលិតស្បៀងអាហារថ្ងៃនិងយប់ គឺមិនគិតអំពីភ្លៀងឬក៏ខ្យល់ព្យុះអ្វីនោះទេ។ ដូចដែលលោកស្រី ជា លាង សហសេវិកខ្ញុំបានបញ្ជាក់ គឺថាផ្នែកមួយទៀតនៃឯកសារលេខ៣ បានទទួលស្គាល់ថាប្រជាជនធ្វើការ ១៥ម៉ោងក្នុងមួយថ្ងៃ។ ហើយនេះវាមានផលប៉ះពាល់ទៅលើសុខភាពរបស់ពួកគេ។ ឯកសារនោះបានពិភាក្សាអំពីការបំលាស់ទីដោយបង្ខំនូវប្រជាជន ដើម្បីបង្ខំឲ្យចូលរួមក្នុងកម្មវិធីពលកម្មដោយបង្ខំ។ បញ្ជាក់ថា ការបង្ខំប្រជាជនត្រូវតែប្រមូលផ្តុំទោះបីទៅដាក់កន្លែងណាដីដែលមានជីជាតិល្អ ដីល្អ មានជីជាតិ។ គោលបំណងនោះគឺថា ដើម្បីការពារប្រទេស ដោយការនាំចេញស្រូវ ២លានតោន ក្នុងឆ្នាំ ១៩៧៧ និង ៨០។

[១១:៥៤:១៣]

ដូចដែលយើងឃើញហើយ មជ្ឈិមបក្សចង់នាំចេញស្រូវហើយនិងផលិតផល កសិកម្មតាមរយៈពលកម្មដោយបង្ខំរបស់ប្រជាជនក្នុងឋានៈជាទាសករដែលស្លាប់ដោយអត់អាហារនោះផងដែរ។ ឯកសារលេខ៣ និយាយផងដែរអំពីការបំលាស់ទី ដោយបង្ខំនូវប្រជាជន។ ដំបូងគឺ និយាយណែនាំឲ្យភូមិភាគបស្ចិម តំបន់លេខ១៥ ឲ្យប្រើប្រជាជន ៣០.០០០ ទៅ ៤០.០០០នាក់ ធ្វើការតាមផ្លូវជាតិលេខ៥ ហើយមេដឹកនាំបានពិភាក្សាអំពីបញ្ហានៅភូមិភាគឧត្តរ ហើយនិងភូមិភាគពាយ័ព្យ ហើយដើម្បីកែសម្រួលសេចក្តីសម្រេចគណៈអចិន្ត្រៃយ៍ខែសីហា ឆ្នាំ១៩៧៥ ដែលបានធ្វើរួចមក។ សូមដកស្រង់៖ "នៅក្នុងភូមិភាគពាយ័ព្យយើងត្រូវតែបន្ថែមកម្លាំងបន្ថែម៥០០.០០០ថែមទៀត។ ព្រះវិហារ យើងស្នើសុំ៥០០.០០០មុន។ ព្រះវិហារ យើងមានលទ្ធភាពនៃការដោះស្រាយស្បៀងអាហារបាន។ ព្រះវិហារមានមនុស្សចាស់ ៧០.០០០រួចទៅហើយ។ ដូច្នេះបញ្ជូន២០.០០០ នៅពេលដែលយើងដំណើរទៅមុខ។ នៅក្នុងភូមិភាគឧត្តរគេត្រូវការប្រជាជន ដូចជាកំពង់ធំជាដើម។ ភូមិភាគបូព៌ាក៏ត្រូវកម្លាំងដែលត្រូវផ្តល់ឲ្យទៅតំបន់ដែលខ្វះមនុស្ស។ ដូច្នេះ តំបន់មួយៗត្រូវតែធ្វើការត្រៀមឲ្យបានសមស្រប ហើយមិនធ្វើ មិនឲ្យមានអ្វីឃ្លីងឃ្លោងទេ ហើយត្រូវបញ្ជាក់ទៅថ្នាក់លើថា តើត្រូវការប៉ុន្មាន? ត្រូវប្តូរទីតាំងទៅកន្លែងណាខ្លះ?"

[១១:៥៥:៤៨]

នៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំ គឺឯកសារលេខ៣នេះ គឺមានសារៈសំខាន់ក្នុងមូលដ្ឋានមួយចំនួន។ ទី១ គឺកត់ត្រាអំពីសេចក្ដីសម្រេចចុងក្រោយសម្ងួហភាព ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលមាន នួន ជា ហើយនិង ខៀវ សំផន ដើម្បីប្ដូរទីតាំងដោយបង្ខំនូវប្រជាជន៥០០.០០០ ទៅភូមិភាគពាយ័ព្យ ហើយនិង២០.០០០ ទៅភូមិភាគឧត្តរ។ គណៈអចិន្ត្រៃយ៍បានធ្វើសេចក្ដីសម្រេចក្នុងខែសីហា មានតែមជ្ឈិមបក្សទេដែលមានអំណាចដោះស្រាយបញ្ហាទាំងអស់នេះ នៅក្នុងពេលក្រោយមក នៅខែកញ្ញា។

[១១:៥៦:២៥]

មានកត្តាចង្អុលបង្ហាញជាច្រើនថា នេះជាសេចក្ដីសម្រេចថ្នាក់មជ្ឈិមដែលខុសពីអ្វីដែលលោក នួន ជា បានអះអាង។ ជាទាហរណ៍ សេចក្ដីសម្រេចក្នុងការបញ្ជូនប្រជាជនទៅព្រះវិហារត្រូវបានធ្វើឡើងតាមការឆ្លើយតបពីស្នើរបស់តំបន់។ ហើយក៏ឯកសារនោះ ក៏មានសេចក្ដីណែនាំជូនភូមិភាគទាក់ទងទៅនឹងការជម្លៀសប្រជាជន ហើយមិនធ្វើឲ្យមានការឃ្លីងឃ្លោងនោះទេ។ កត្តាសំខាន់មួយទៀតនៃឯកសារនេះ គឺវាបង្ហាញអំពីការជម្លៀសដោយបង្ខំ គឺជាការកត្តាសំខាន់នៃកម្មវិធីដាក់ប្រជាជនឲ្យជាទាសករ។ តំបន់១៥ ឲ្យបញ្ជូន៣០.០០០ ទៅ៤០.០០០ ទៅការដ្ឋាន។ ២០.០០០ប្ដូរទៅព្រះវិហារ ហើយ ៥០០.០០០ ប្ដូរទៅភូមិភាគពាយ័ព្យ។

ខ្ញុំសូមអនុញ្ញាតពិនិត្យមើលកត្តាសំខាន់មួយទៀតនៅក្នុងឯកសារលេខ៣នេះ ដែលបង្ហាញនៅក្នុងការសន្និដ្ឋានរបស់យើងថា ការពាក់ព័ន្ធរបស់លោក ខៀវ សំផន នៅក្នុងការជម្លៀសលើកទី២នេះ។ នៅក្នុងសេចក្ដីសង្ខេបរបស់ខ្ញុំ យើងបានពិភាក្សាការទទួលខុសត្រូវជាក់លាក់របស់លោក ខៀវ សំផន នៅក្នុងកម្មវិធីដាក់ឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។ និយាយដោយសង្ខេបការទទួលខុសត្រូវនោះ រួមបញ្ចូលទាំងការចែកឧបករណ៍សម្ភារៈទូទាំងប្រទេសដើម្បីធានាឲ្យការអនុវត្តពលកម្មដោយបង្ខំនោះទៅបាន។

[១១:៥៨:០៥]

ការតាមដានគ្រប់គ្រងក្រសួងពាណិជ្ជកម្មដែលនាំស្រូវ អង្ករ រាប់ពាន់ រាប់ម៉ឺនហិកតា ហើយនិងអនុវត្តតួនាទីតាមបក្សកុម្មុយនីស្តកម្ពុជារបស់មជ្ឈិមបក្ស។ ដូចដែលបានដឹងហើយ គឺថា ខៀវ សំផន គាត់តាមដានយ៉ាងជិតស្និទ្ធ ឃ្លាំងរដ្ឋ ដែលផ្ទុកនូវផលិតផលកសិកម្មជាច្រើន ហើយនិងឧស្សាហកម្ម

មួយចំនួន។ នៅក្នុងឯកសារពីរនេះគឺទាក់ទងទៅនឹងការពាក់ព័ន្ធទៅនឹងការក្រសួងពាណិជ្ជកម្ម ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំនូវប្រជាជន។ សូមដកស្រង់៖ "ចំពោះគំនិតផ្តួចផ្តើមរបស់គណៈពាណិជ្ជ-កម្មរដ្ឋ គេមិនត្រូវការព្រួយបារម្ភអ្វីទៅតាមផលិត។ និយាយអំពីបញ្ហានេះ មិនមែនមានន័យ ពាណិជ្ជកម្មរដ្ឋមិនបានគិតទេ គេគិត ដូចជាគេគិតអំពីការប្តូរដឹកជញ្ជូនប្រជាជនរាប់ពាន់ រាប់ម៉ឺននាក់។ ប៉ុន្តែលើកឡើងនៅទីនេះគឺត្រូវតែធ្វើឲ្យបានត្រឹមត្រូវជាបន្ត"។ នេះជាភស្តុតាងមួយដែលថា មជ្ឈិមបក្សបានប្រើការជម្លៀសដោយបង្ខំ ពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្មផងដែរ។ នៅក្នុងចុងឆ្នាំ១៩៧៥ ក្រសួងនេះឯងនៅជាផ្នែកនៃក្របខ័ណ្ឌនៃរណសិរ្សរួបរួមជាតិកម្ពុជា ដែល ខៀវ សំផន បានមានតំណែងជាឧបនាយករដ្ឋមន្ត្រី។ តាមមុខងាររបស់វា គឺក្រសួងនុំងពាក់ព័ន្ធឆ្លើយតបដោយផ្ទាល់ទៅ ខៀវ សំផន, នួន ជា ហើយនិងអ្នកផ្សេងទៀត នៅក្នុងមជ្ឈិមបក្ស។

[១១:៥៩:៣៨]

លោក លោកស្រីចៅក្រម យើងនឹងពិនិត្យបន្ថែមទៀត។ ឯកសារមួយចំនួនទៀត ទាក់ទងនឹងបញ្ហានេះ។ ហើយឥឡូវនេះខ្ញុំឃើញថាពេលវេលាកៀកនឹងដល់ម៉ោងដប់ពីរហើយ ដូច្នេះខ្ញុំសូមជម្រាបសួរលោកប្រធាន ថាតើខ្ញុំគួរអនុញ្ញាតឲ្យខ្ញុំសម្រាកពេលនេះ ឬក៏អាចនឹងតទៅប្រធានផ្សេង?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមភាគី មន្ត្រី និងបុគ្គលដែលគាំទ្រកិច្ចដំណើរការសវនាការ និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ។ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមនៅក្នុងសវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣៦ នាទី)*

[១៣:៣៦:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការធ្វើសេចក្តីថ្លែងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ មុនពេលយើងឈប់សម្រាក គឺយើងបានផ្អាកនៅត្រង់ការពិភាក្សាអំពីការចូលរួមរបស់ នួន ជា និង ខៀវ សំផន នៅក្នុងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងការជម្លៀសលើកទី២ ដែលជាការជម្លៀសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយយើងក៏បានផ្អាកមិនបានពិនិត្យមើលឯកសារ E3 គឺឯកសារមួយដែលនិយាយអំពីការចូលរួមរបស់ក្រសួងពាណិជ្ជកម្ម គឺជាក្រសួងដែល ខៀវ សំផន ជាអ្នកគ្រប់គ្រង ហើយនិងការចូលរួមរបស់ក្រសួងនេះនៅក្នុងការជម្លៀសប្រជាជន។ គឺការជម្លៀសពីផ្នែកជាច្រើននៅក្នុងប្រទេសទៅខាងភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។

ឥឡូវនេះ ខ្ញុំចង់លើកបង្ហាញនូវឯកសារមួយទៀត ដែលបង្ហាញអំពីតួនាទីរបស់ក្រសួងពាណិជ្ជ-កម្មទាក់ទងទៅនឹងការចូលរួមរបស់ក្រសួង ក៏ដូចជារបស់ ខៀវ សំផន ក្នុងការរក្សាឲ្យបាននូវរដ្ឋទាសករមួយនេះ។ ដូចដែលខ្ញុំបានបញ្ជាក់ពីដើមរួចមកហើយ ក្រសួងទទួលខុសត្រូវលើការនាំចេញស្រូវ អង្ករ ហើយខ្ញុំសូមបង្ហាញឯកសារមួយទៀតដែលនិយាយអំពីការគ្រប់គ្រងរបស់ ខៀវ សំផន ទៅលើការប្រមូលផលស្រូវនៅក្នុងរដ្ឋទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។

លោក លោកស្រីចៅក្រម ប្រសិនបើយើងមើលឯកសារនៅលើអេក្រង់ហ្នឹង គឺជាឯកសារដែលចេញនៅថ្ងៃទី០៨ ខែមីនា ១៩៧៧ នៅទំព័រដំបូងគឺយើងមាននូវចំណារដែលថាផ្ញើជូន បងហែម ដែលមានហត្ថលេខាថ្ងៃ១០ ខែមីនា។ ដូចដែលយើងដឹងរួចហើយ បងហែម គឺ ខៀវ សំផន។

[១៣:៣៨:៣៣]

លោក លោកស្រីចៅក្រម ប្រហែលជាអាចសង្កេតឃើញថា ចាប់ពីថ្ងៃទី០១ រហូតដល់ថ្ងៃទី០៧ មីនា ១៩៧៧ ក្រសួងបានទទួលស្រូវជាង ២លានគីឡូក្រាមពីខាងនិរតី និងខាងបស្ចិម។ នៅក្នុងរយៈពេលដដែលគ្នាដែរ គឺភូមិភាគបូព៌ា និងពាយព្យបានផ្តល់នូវស្រូវប្រហែលជា១លានគីឡូក្រាម។ ស្រូវអង្ករប្រហែលជា៣០០.០០០គីឡូទៀត ត្រូវបានគេផ្គត់ផ្គង់ទៅដល់ខាងមជ្ឈិម។ គឺបានន័យថាយើងមានស្រូវជាង៣លានគីឡូក្រាមដែលយើងទទួលបានពីភូមិភាគបួនក្នុងរយៈពេលត្រឹមតែមួយសប្តាហ៍។ ដូច្នេះ

ក្នុងនេះបង្ហាញថា គឺមានស្រូវប្រហែលជា ២៤លានគីឡូក្រាម ដែលគេអាចប្រមូលបានក្នុងមួយពេលណាមួយ។

លោក លោកស្រីចៅក្រម ប្រហែលជាចាំថានៅក្នុងភស្តុតាងរបស់លោក ហ៊ុន ឈុនលី– លោក ហ៊ុន ឈុនលី បានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ផងដែរ អំពីភូមិភាគពាយ័ព្យដែលស្រូវអង្ករដែលប្រមូលបានត្រូវគេទុកក្នុងឃ្លាំង ហើយបន្ទាប់មកត្រូវបានគេដឹកចេញយកទៅក្នុងពេលដែលប្រជាជនក្នុងតំបន់នោះគឺអត់ឃ្លាន។ ភស្តុតាងហ្នឹងបានបង្ហាញយ៉ាងច្បាស់ថា អំពីឥទ្ធិពលនៃសកម្មភាពរបស់ នួន ជា និង ខៀវ សំផន ទៅលើប្រជាជនដែលត្រូវបានគេជម្លៀសទៅខាងភូមិភាគពាយ័ព្យ។

[១៣:៤០:៣៨]

លោក លោកស្រីចៅក្រម ប្រហែលជាចាំនូវសក្ខីកម្មរបស់សាក្សី រស់ ស៊ុយ ដែលក្រុមមេធាវី ខៀវ សំផន បានស្នើឡើង។ លោក ស៊ុយ គឺជាអ្នកគ្រប់គ្រងឃ្លាំងគីឡូម៉ែត្រលេខ៦ ដែលជាឃ្លាំងធំជាងគេបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ។ លោក ស៊ុយ បានផ្តល់សក្ខីកម្មថាស្រូវអង្ករជាច្រើនត្រូវបានទទួលមកពីភូមិភាគនានា ហើយត្រូវបានគេយកមកវេចខ្ចប់ ហើយនាំចេញទៅក្រៅ។ ផលិតផលស្រូវទាំងអស់ស្រូវអង្ករទាំងអស់នោះមិនត្រូវបានគេបញ្ជូនទៅផ្គត់ផ្គង់ប្រជាជននៅក្នុងប្រទេសឡើយ។ ទាំងអស់នេះ គឺកើតឡើងនៅពេលដែលមានការគ្រប់គ្រងរបស់មជ្ឈិមបក្ស ហើយនិងក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន ជាពិសេស។

នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់យើង គឺយើងបានវិភាគទៅលើរបាយការណ៍ជាង ២០ដែលត្រូវបានដាក់បញ្ជូនដោយក្រសួងពាណិជ្ជកម្ម ផ្ញើទៅ ខៀវ សំផន ហើយឯកសារទាំងអស់នេះនិយាយអំពីការនាំស្រូវអង្ករទៅប្រទេសខាងក្រៅ។ នៅក្នុងសារណានេះ គឺភស្តុតាងបានបង្ហាញថា ខៀវ សំផន នៅតែបន្តចូលរួមនៅក្នុងប្រព័ន្ធនៃការដាក់ឲ្យទៅជាទាសករ ការជម្លៀសដោយបង្ខំ និងពលកម្មដោយបង្ខំ។ នេះគឺជាប្រព័ន្ធមួយដែលការជម្លៀសដោយបង្ខំលើកទី២ កើតឡើងនៅក្នុងប្រព័ន្ធនេះ។

[១៣:៤២:០០]

ឯកសារមួយទៀតដែលខ្ញុំចង់បង្ហាញ គឺបង្ហាញអំពីការចូលរួមរបស់ជនជាប់ចោទទាំងពីររូបនៅក្នុងការជម្លៀសដោយបង្ខំលើកទី២។ លោកជំទាវ ជា លាង បានពិភាក្សានៅក្នុងសារណារបស់លោកជំទាវរួចទៅហើយនៅក្នុងតួរលេខ លេខ១៥ មកពី សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា។ ឥឡូវនេះ យើងពិនិត្យមើលទៅលើឯកសារនេះ គឺវាចុះថ្ងៃទី៣០ ខែវិច្ឆិកា ហើយត្រូវបានបញ្ជូនទៅ ប៉ុល ពត, នួន

ជា, ឌឿន ហើយនិង យ៉ែម។ ឯកសារនេះបានជូនដំណឹងដល់មជ្ឈិមអំពីការលំបាកមួយចំនួនដែលភូមិភាគបូព៌ាបានជួបប្រទះនៅក្នុងពេលជម្លៀសប្រជាជនទៅភូមិភាគឧត្តរ រួមបញ្ចូលទាំងការជម្លៀសប្រជាជនចាមប្រហែលជា៥០.០០០នាក់។ សារទូរលេខនេះបញ្ជាក់នៅក្នុងកថាខណ្ឌទី១ថា ការជម្លៀសប្រជាជនទាំងអស់នេះ គឺត្រូវបានអនុវត្តដោយយោងទៅតាមមតិយោបល់ និងការណែនាំរបស់អង្គការ។

[១៣:៤៣:០៥]

ក្រុមមេធាវីការពារក្តី នួន ជា បានជំទាស់នៅក្នុងសារណារបស់ពួកគេថា សារទូរលេខនេះ គឺមិនពាក់ព័ន្ធ។ ពិតហើយថា ពួកគេប្រាកដជានិយាយមែបនេះមែន ព្រោះថាឯកសារនេះដាក់បន្ទុកទៅលើកូនក្តីរបស់ពួកគេដោយផ្ទាល់នៅក្នុងការជម្លៀសប្រជាជនដោយបង្ខំ ដែលស្របជាមួយនឹងការជម្លៀសលើកទី២ ហើយវាបង្ហាញហួសពីវិមតិសង្ស័យទៀតថា ការជម្លៀសទាំងអស់នេះត្រូវបានបញ្ជាដោយមជ្ឈិម គឺវាបញ្ជាក់ថា -- ខ្ញុំសូមដកស្រង់៖ "ការដកចេញ ការជម្លៀសជាគោលការណ៍ គឺសំដៅទៅលើការបំបែកដោយអនុលោមទៅតាមយោបល់របស់លោក ដូចដែលមិត្តបានពិភាក្សានៅក្នុងពេលលើកមុន។

លោក លោកស្រីចៅក្រម នៅត្រង់ឯកសារនេះ គឺយើងឃើញលោក សោ ភឹម ដែលជាសមាជិករបស់គណៈអចិន្ត្រៃយ៍បានបញ្ជាក់អំពីការអនុវត្តរបស់គាត់ចំពោះសេចក្តីណែនាំរបស់មជ្ឈិមបក្ស ដើម្បីឲ្យជម្លៀសប្រជាជន ហើយស្នើសុំដល់មជ្ឈិមបក្សឲ្យមានការជួយអន្តរាគមន៍ដោយសារតែមានការខ្វែងគំនិតគ្នារវាងលោក សោម ភឹម ហើយនិងភូមិភាគឧត្តរ។ វាមិនមានភស្តុតាងអ្វីច្បាស់ជាងនេះទៀតទេដែលថា តាមពិត គឺមជ្ឈិមបក្ស គឺថ្នាក់ដឹកនាំជាសមូហភាពដែលមានមូលដ្ឋាននៅភ្នំពេញបានចេញដីកាណែនាំទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ ហើយនិងធ្វើការដោះស្រាយទៅលើបញ្ហាណាមួយនៅក្នុងការអនុវត្តរបស់ពួកគេ។ នង សុផង់ ដែលជាប្រធានមន្ទីរបកប្រែសារទូរលេខ ដែលជាមន្ទីរមួយនៅក្នុងក-១ បានផ្តល់សក្ខីកម្មថា សារទូរលេខមួយនេះត្រូវបានគេបញ្ជូនទៅ នួន ជា ពីព្រោះក្រុមសារទូរលេខដែលស្ថិតក្រោមការណែនាំថា នួន ជា គឺជាបុគ្គលដែលត្រូវគេបញ្ជូន ដោយសារគាត់ទទួលខុសត្រូវលើប្រជាជន ហើយនិងទទួលខុសត្រូវក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងអស់នេះ។

[១៣:៤៥:០០]

នង សុផង់ ក៏បានផ្តល់សក្ខីកម្មនៅចំពោះមុខ លោក លោកស្រីចៅក្រមផងដែរថា គាត់មានការភ្ញាក់ផ្អើលដែលថាសារទូរលេខមិនត្រូវបានគេចម្លងជូនមន្ទីរ ដោយសារតែជាទូទៅសារទូរលេខទាំងអស់ត្រូវបានគេចម្លងទៅជូនមន្ទីរ៨៧០"។ ខ្ញុំសូមលើកឡើងថាហេតុផលចំពោះការអនុវត្តខុសពីការអនុវត្តនីតិ

វិធីជាធម្មតានេះ គឺច្បាស់លាស់ទេ ព្រោះថាឯកសារនេះត្រូវបានបញ្ជូនទៅ ឌឿន។ ដូច្នេះ វាមិនចាំបាច់អ្វីដែលត្រូវបញ្ជូនទៅមន្ទីរ៨៧០នោះឡើយ។ ឌឿន នៅពេលនោះគឺជាប្រធានមន្ទីរនយោបាយ៨៧០។ ហើយមន្ទីរនេះទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយ និងសេចក្ដីសម្រេចរបស់មជ្ឈិមបក្ស ហើយគឺជាមន្ទីរដែលមានសមាជិកតែពីររូបប៉ុណ្ណោះ គឺឌឿន ហើយនិង ខៀវ សំផន។ បុគ្គលទាំងពីរនាក់នេះគឺថា ខៀវ សំផន មានឋានៈ និងបទពិសោធន៍ច្រើនជាង។

[១៣:៤៦:០១]

ប្រសិនបើយើងមើលទៅលើសក្ខីកម្មរបស់ ឌុច គឺយើងពិនិត្យឃើញថា "បង ខៀវ សំផន គឺជាសមាជិករបស់មន្ទីរមជ្ឈិម នៅពេលដែល ឌឿន ក៏ជាសមាជិកមួយដែរ ប៉ុន្តែគាត់ជាសមាជិកបម្រុងនោះទេ។ ឌឿន មិនអាចជាក្លាយជាសមាជិកពេញសិទ្ធិនោះឡើយ។ ប្រសិនបើគាត់ក្លាយជាសមាជិកពេញសិទ្ធិគាត់ក៏មិនអាចដែរ ហើយក៏គាត់មិនអាចទទួលបាននូវឋានៈជាសមាជិកពេញសិទ្ធិដូចបង ខៀវ សំផន ដែរ។ ទោះបីថា ឌឿន អាចថាជាប្រធាននៃមន្ទីរមជ្ឈិម គាត់នៅតែមានឋានៈទាបជាង ខៀវ សំផន ដោយសារគាត់ក្មេងជាង។ នៅពេលនោះគឺថាគាត់មានវ័យក្មេងប្រហែលខ្ញុំដែរ"។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងចម្លើយរបស់ ឌុច ចំពោះសហចៅក្រមស៊ើបអង្កេត ឌុច បានបញ្ជាក់ដូចតទៅនេះទាក់ទងទៅនឹងតួនាទីរបស់ខៀវ សំផន ហើយនិងឌឿន។ ខ្ញុំសូមដកស្រង់៖ "យើងអាចគិតថាមុនពេលដែលមានការចាប់ខ្លួន សឿ វ៉ាស៊ី គឺឌឿន ហ្នឹង ខៀវ សំផន អាចជាកូនចៅគាត់។ ប៉ុន្តែតាមពិតទៅគឺវាផ្ទុយពីនេះទៅវិញទេ។ គឺថាវាច្បាស់លាស់ណាស់ថា ខៀវ សំផន គឺជាបុគ្គលសំខាន់ជាង សឿ វ៉ាស៊ី ខ្លាំងណាស់"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ទាំងអស់នេះគឺជាពាក្យសម្ដីរបស់ប្រធានមន្ទីរសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា។ គឺជាបុគ្គលម្នាក់ដែលមានតួនាទីសន្តិសុខយ៉ាងសំខាន់នៅក្នុងបក្សទាំងនៅមុន និងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាសម្ដីរបស់បុគ្គលដែលមានសិទ្ធិអំណាចស៊ើបអង្កេត ហើយនិងធ្វើការបោសសម្អាតខ្លាំងដ៏សំខាន់បំផុតរបស់មជ្ឈិមបក្ស។ គឺជាបុគ្គលម្នាក់ដែលស្គាល់ ឌឿន យ៉ាងច្បាស់ ព្រមទាំងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតដែលធ្វើការនៅក្នុងមជ្ឈិមបក្ស។

[១៣:៤៧:៥០]

យើងសូមលើកឡើងថា ភស្តុតាងរបស់ ឌុច រួមជាមួយនឹងសារទូរលេខ១៥ ហើយនិងភស្តុតាងរបស់សមាជិកដែលខៀវ សំផន ជាសមាជិកនៃមន្ទីរនយោបាយ៨៧០ គឺធ្វើឲ្យយើងអាចសន្និដ្ឋានបានតែ

មួយដែលសមស្របបំផុតនោះគឺថា ខៀវ សំផន តាមរយៈតួនាទីរបស់គាត់នៅក្នុងមន្ទីរនយោបាយ៨៧០ គឺខ្លួនគាត់ផ្ទាល់បានចូលរួមទៅក្នុងការអនុវត្តការជម្លៀសដោយបង្ខំនៅចុងឆ្នាំ១៩៧៥។ ជាការចាំបាច់ដែលយើងត្រូវរំឭកថាសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនទៅខាងឧត្តរ និងខាងពាយ័ព្យត្រូវបានធ្វើឡើងនៅក្នុងបរិបទរបស់សេចក្ដីសម្រេចមជ្ឈិមបក្សដើម្បីបង្កើតការផលិតស្រូវនៅក្នុង ឲ្យបានលឿនដូចផ្លេកបន្ទរ។ ឯកសារលេខ៣ គាំទ្រទៅលើការដាក់នូវផែនការបីតោនក្នុងមួយហិកតា ក្នុងឆ្នាំ១៩៧៧។ តាមពិតទៅសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនទៅខាងឧត្តរនិងពាយ័ព្យគឺទទួលឥទ្ធិពលដោយសារទស្សនៈរបស់មេដឹកនាំដែលថា តំបន់ទាំងពីរនេះអាចផលិតស្រុកលើសពី៣តោនក្នុងមួយហិកតា។

[១៣:៤៩:០៣]

ត្រឹមខែវិច្ឆិកា ៧៥ ផែនការបីតោនក្នុងមួយហិកតាត្រូវបានគេដាក់នៅទូទាំងផ្ទៃប្រទេសតែម្ដង គឺថាគេដាក់មុនឆ្នាំ១៩៧៧ទៅទៀត គឺមេដឹកនាំប្រទេសបានសម្រេចដាក់ផែនការលឿនជាងគម្រោង។ ពួកគេបង្គាប់បញ្ជាថាស្រូវបីតោនក្នុងមួយហិកតា ត្រូវតែធ្វើឡើងក្នុងឆ្នាំ៧៦។ ទស្សនាវដ្ដីទង់បដិវត្តន៍លេខថ្មីចុះខែតុលា វិច្ឆិកា ៧៥ បានកត់ត្រានូវសេចក្ដីសម្រេចដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “តើបីតោនក្នុងមួយហិកតា មានន័យយ៉ាងដូចម្ដេចសម្រាប់ឆ្នាំ៧៦? សមាជមជ្ឈិមបក្សបានសម្រេចជាឯកច្ឆន្ទថាការប្រមូលស្រូវជាមធ្យមនៅក្នុងប្រទេសក្នុងឆ្នាំ១៩៧៦ “ត្រូវតែទទួលបានបីតោនក្នុងមួយហិកតា ដោយមិនគិតថាជាការធ្វើស្រូវមួយដងក្នុងមួយឆ្នាំ ឬក៏ពីរដងក្នុងមួយឆ្នាំនោះឡើយ។ នៅក្នុងសមាជសេដ្ឋកិច្ចទូទាំងប្រទេសនៅក្នុងខែវិច្ឆិកា ឆ្នាំ៧៥ មជ្ឈិមបក្សបានអនុម័តជាឯកច្ឆន្ទទៅលើសេចក្ដីសម្រេចរបស់បក្សទាំងមូល ដូចដែលបានបង្ហាញខាងលើ។ ហេតុដូច្នេះហើយ សេចក្ដីសម្រេចរបស់បក្សក្នុងការកំណត់បីតោនក្នុងមួយហិកតា គឺជាដំណោះស្រាយជារួមរបស់បក្សទាំងមូល គឺរបស់ប្រជាជនទាំងមូល ហើយនិងជាដំណោះស្រាយរបស់កងទ័ពបដិវត្តន៍ទាំងមូល”។

[១៣:៥០:៣៩]

ឯកសារទាំងអស់បានបង្ហាញថាបន្ទាប់ពីមានការបង្គាប់ឲ្យមានការជម្លៀសដោយបង្ខំរបស់ប្រជាជនទៅកាន់តំបន់ឧត្តរ និងតំបន់ពាយ័ព្យ ដើម្បីគោលដៅនៃការធ្វើការពលកម្មដោយបង្ខំ មជ្ឈិមបក្សសម្រេចថាដាក់នូវផែនការផលិតផលថ្មីមួយ។ នៅពេលដែលការជម្លៀសដោយបង្ខំកំពុងតែអនុវត្តសេចក្ដីសម្រេចនេះត្រូវបានគេធ្វើឡើង។ ទាំងអស់នេះគឺជាភស្តុតាងដែលបង្ហាញថា ការជម្លៀសប្រជាជនដែលចាប់ផ្ដើមនៅចុងឆ្នាំ៧៥ គឺជាផ្នែកនិងបណ្ដុំនៃផែនការធ្វើឲ្យទៅជាទាសកររបស់មជ្ឈិមបក្ស។

គឺជាផែនការមួយដែល នួន ជា និង ខៀវ សំផន បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំ។

[១៣:៥១:២០]

ផែនការបីគោនក្នុងមួយហិកតា គឺត្រូវបានសម្រេចជាឯកច្ឆន្ទ ហើយត្រូវបានអនុវត្តចំពោះប្រជាជនទូទាំងប្រទេសតែម្តង។

បន្ថែមទៅលើភស្តុតាងដែលយើងទើបតែបានពិភាក្សានេះ លោក លោកស្រីចៅក្រម ត្រូវតែពិនិត្យផងដែរអំពីសកម្មភាពរបស់ជនជាប់ចោទ ដែលបានជំរុញដល់ការបន្តកម្មវិធីទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងការរារាំងជនរងគ្រោះមិនឲ្យត្រឡប់មកផ្ទះវិញបាន។ ទោះបីថាការជម្លៀសដោយបង្ខំអាចផ្តល់ជាយុត្តកម្ម ដែលការពិតគឺមិនអាចនោះក៏ដោយ ក៏វានៅតែជារឿងខុសច្បាស់ដែរ ដោយសារតែជនជាប់ចោទមិនអនុញ្ញាតឲ្យប្រជាជនធ្វើការត្រឡប់មកផ្ទះលំនៅដ្ឋានរបស់ពួកគេវិញ។

ភស្តុតាងដែលបានបង្ហាញថា ការដាក់ឲ្យទៅជាទាសករចំពោះជនភៀសខ្លួននៅតែបន្តរហូតនៅពេលដែលពួកគេមកដល់ភូមិភាគឧត្តរ និងពាយ័ព្យ។ ប្រជាជនទាំងអស់នេះ ដែលភាគច្រើនជាប្រជាជនថ្មីត្រូវបានគេផ្ញើនៅក្នុងសហករណ៍ ហើយមិនអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញឡើយ រហូតទៅដល់ពេលដែលជនជាប់ចោទ និងរបបដែលជនជាប់ចោទដឹកនាំនេះត្រូវបានគេបណ្តេញចេញពីអំណាច ហើយត្រូវបានគេបណ្តេញ ទើបជនរងគ្រោះអាចមានលទ្ធភាពត្រឡប់មកផ្ទះវិញបាន។

[១៣:៥២:៣០]

លោក លោកស្រីចៅក្រម ហេតុដូច្នេះវាចាំបាច់ដែលយើងត្រូវពិចារណាទៅលើសកម្មភាពរបស់ជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលតែម្តង ដែលមានសកម្មភាពជំរុញទៅដល់ប្រព័ន្ធនៃការធ្វើឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។ សកម្មភាពទាំងអស់នេះរួមមាន៖ ការចូលនៅក្នុងការងាររបស់មជ្ឈិមបក្ស ការចេញសេចក្តីណែនាំទៅថ្នាក់ក្រោមនៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជាតាមរយៈសារទូរលេខ ទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន យុវនារី ព្រមទាំងការអប់រំរៀនសូត្រនយោបាយអំពីមាគ៌ាបក្ស ព្រមទាំងការទទួលនិងពិនិត្យទៅលើរបាយការណ៍ ការប្រជុំជាមួយភូមិភាគ តំបន់ កម្មាភិបាលស្រុក ដើម្បីធានាថាមានការគោរពទៅតាមសេចក្តីណែនាំរបស់មជ្ឈិមបក្ស ព្រមទាំងការចេញនូវសេចក្តីថ្លែងជាសាធារណៈ ព្រមទាំងការជំរុញ ការលើកកម្ពស់ និងការអនុម័តទៅលើគោលនយោបាយសហករណ៍ គោលនយោបាយទាសករដែលធ្វើឡើងទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។ ភស្តុតាងទាំងអស់នេះ គឺយើងបានពិភាក្សាជាលម្អិតនៅក្នុងសារណាជាលាយលក្ខណ៍អក្សរ

របស់យើងរួចទៅហើយ។

[១៣:៥៣:៤៣]

ឥឡូវនេះខ្ញុំសូមបង្ហាញឧទាហរណ៍បន្ថែមពីរបីទៀត ទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទទាំងពីរ ដែលបង្ហាញអំពីការចូលរួមរបស់ពួកគេនៅក្នុងការគាំទ្រប្រព័ន្ធធ្វើឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្ដកម្ពុជា។

ខ្ញុំសូមផ្ដល់ឧទាហរណ៍ជាដំបូងមួយទាក់ទងទៅនឹងភស្តុតាងដែលលោក លោកស្រីចៅក្រមបានឮទាក់ទងទៅនឹងការបង្រៀននយោបាយ។ ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានពណ៌នាអំពីវគ្គសិក្សារៀនសូត្រនៅសាលានយោបាយបក្សបុរីកីឡា ដែលនៅទីនោះ ប៉ុល ពត, នួន ជា ហើយ ខៀវ សំផន បានចូលរួមបង្រៀនទាំងអស់នេះ។ ហេតុការណ៍ត្រូវបានចូលរួមដោយសិក្ខាកាមជាង២០០០នាក់ រួមបញ្ចូលទាំងមេដឹកនាំភូមិភាគ តំបន់ និងស្រុក។ អែម អឿន បានផ្ដល់សក្ខីកម្មថា ប៉ុល ពត បានផ្ដល់បានបង្រៀនដល់អ្នកចូលរួមដំបូងអំពីនយោបាយបដិវត្តន៍។ បន្ទាប់មកទៀតគឺ នួន ជា បានបន្ត, ដែល នួន ជា គាត់និយាយអំពីមហាលោតផ្លោះ មហាអស្ចារ្យ ហើយនិងការចាំបាច់ដើម្បីស្វែងរកខ្មាំង។ ខ្មាំងរួមបញ្ចូលទាំងបុគ្គលទាំងឡាយណាដែលបំផ្លាញឧបករណ៍ ឬក៏បុគ្គលទាំងឡាយដែលឈឺ រួមបញ្ចូលទាំងអ្នកដែលបង្កប់ស៊ីរូងផ្ទៃក្នុងបក្ស ព្រមទាំងទាហានអតីតរបប លន់ នល់។ នួន ជា ក៏បានបង្រៀនកម្មាភិបាលអំពីប្រព័ន្ធចារកម្ម សេ.អ៊ី.អា, កា.ហ្សេ.បេ ព្រមទាំងសមាជិកដែលបានក្បត់បក្សថែមទៀតផង។ លោក លោកស្រីចៅក្រម បន្ទាប់មកទៀតគឺ ខៀវ សំផន ជាអ្នកបង្រៀន។ គាត់ប្រកាសថា "កម្មាភិបាលទាំងអស់ត្រូវតែផ្លាស់ប្ដូរខ្លួនគេដើម្បីទទួលបានគោលដៅដែលកំណត់ដោយបក្ស"។ គាត់បានបញ្ជាក់ថា អ្នកណាដែលប្រើប្រាស់វត្ថុដោយមិនត្រឹមត្រូវ ឧទាហរណ៍ថា សេរី ធ្វើឲ្យបាក់ម្ជុលគឺ ឬក៏អ្នកណាធ្វើពុត ជាឈឺនោះត្រូវបានគេចាត់ទុកថាក្បត់បក្សហើយត្រូវតាមដាន។ ខៀវ សំផន ក៏បានបញ្ជាក់ផងដែរថា ទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់ ទាំងសមាជិកបក្សគឺគួរតែត្រូវបានគេតាមដានដើម្បីកំណត់ឲ្យបានពីខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ គាត់បាននិយាយផងដែរថា ប្រជាជនថ្មីជាពិសេសគួរត្រូវបានគេតាមដាន ដោយសារពួកប្រជាជនថ្មីត្រូវជាប់វណ្ណៈសក្តិភូមិ។ ទាំងអស់នេះ គឺជាពាក្យដែលច្បាស់លាស់ដែលបង្ហាញដោយជនជាប់ចោទដែលនិយាយនៅក្នុងវត្តមានរបស់ពួកគេទាំងអស់គ្នា ដោយមានវត្តមានរបស់ ប៉ុល ពត ផងដែរ ដែលពួកគាត់នាំគ្នាអនុម័តទៅលើកម្មវិធីនៃការភ័យខ្លាច និងការធ្វើឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្ដកម្ពុជា។

[១៣:៥៦:០៧]

ខ្ញុំឥឡូវនេះនឹងដោះស្រាយអំពីសេចក្តីថ្លែងការណ៍ជាសាធារណៈដែលធ្វើឡើង ដោយជនជាប់ចោទដែលអនុម័តព្រមទាំងជំរុញដល់គោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខៀវ សំផន បានថ្លែងការណ៍ជាច្រើននៅក្នុងឆ្នាំ១៩៧៥។ នៅថ្ងៃទី២២ មេសា ៧៥ ដែលខ្ញុំបានលើកឡើងពីពេលដើមនេះគាត់បានទទួលស្គាល់អំពីកម្មវិធីពលកម្មដែលបង្ខំដោយបក្សកុម្មុយនីស្តកម្ពុជា។ គាត់អួតអាងថាតើជ័យជម្នះ ១៧ មេសា មហាអស្ចារ្យនេះត្រូវបានសម្រេចដោយប្រជាជនកម្ពុជាដោយរបៀបណា? ខ្ញុំសូមដកស្រង់៖ "គឺថាប្រជាជនធ្វើការទាំងយប់ទាំងថ្ងៃដោយកម្លាំងកាយ កម្លាំងចិត្តមិនឈប់សម្រាកហើយដោយធ្វើការលះបង់យ៉ាងច្រើន"។

នៅក្នុងការសម្ភាស ខែ៨ ឆ្នាំ១៩៧៥ គាត់បានពិភាក្សាថា ប្រជាជនជាងរាប់លាននាក់ត្រូវបានរំដោះ ហើយបានបញ្ជាក់ទៀតថា យើងផ្លាស់ទីកម្លាំងប្រជាជន ព្រមទាំងទាហាន ដើម្បីយកឈ្នះទៅលើស្ថានភាពថ្មី ហើយនិងដោះស្រាយទៅលើបញ្ហារាប់ពាន់។ នៅក្នុងសេចក្តីថ្លែងការណ៍ខែកញ្ញា ៧៥ របស់គាត់បន្ទាប់ពីគាត់ត្រឡប់មកពីប្រទេសចិនជាមួយសម្តេច នរោត្តម សីហនុ, ខៀវ សំផន បានប្រកាសថា "ប្រជាជនបានចូលរួមនៅក្នុងការផលិត និងការស្តារសេដ្ឋកិច្ច"។ នៅក្នុងសេចក្តីថ្លែងការណ៍ ខែធ្នូ ៧៥ នៅពេលដែលគាត់និយាយអំពីពង្រាងរដ្ឋធម្មនុញ្ញ ខៀវ សំផន បានលើកឡើងនូវចំណុចជាច្រើននៃកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការធ្វើឲ្យទៅជាទាសករ។ គាត់បានលើកឡើងថា "ប្រព័ន្ធជាសមូហភាពក្នុងការដឹកជញ្ជូន និងពលកម្ម"ត្រូវបានអនុវត្តតាំងពីមុនឆ្នាំ៧៥ នៅក្នុងតំបន់ទាំងអស់ដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា ហើយវាត្រូវបានបន្តនៅទូទាំងប្រទេសបន្ទាប់ពីមានការរំដោះ។ ដោយសារតែប្រព័ន្ធនេះជួយយើងមិនឲ្យមានកំហុសតទៅមុខទៀត។ គាត់ប្រកាសថា "នៅតាមគ្រប់ការដ្ឋានទាំងអស់គ្នាប្រជាជនទាំងអស់ធ្វើការនៅក្នុងវាលស្រែដោយសារតែប្រជាជនយើងបានអនុវត្តនូវប្រព័ន្ធកម្លាំងជាសមូហភាព"។ នៅក្នុងសន្ទរកថាដដែលនេះ ខៀវ សំផន បានលើកឡើងដោយមោទនភាពអំពីការហាមឃាត់សេរីភាពរបស់ប្រជាជនដែលជាផ្នែកមួយដ៏សំខាន់នៃរដ្ឋទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានបញ្ជាក់ថា "រដ្ឋថ្មីជំទាស់ទៅលើវប្បធម៌ស្អុយរលួយ វប្បធម៌ប្រតិកិរិយា ដែលជាប្រភេទនៃចក្រពត្តិអាណានិគមនិយមនៅក្នុងប្រទេសកម្ពុជា"។ ការនេះមានន័យថា "ទស្សនាវដ្តី សារព័ត៌មានដែលប្រើប្រាស់ដើម្បីផ្សព្វផ្សាយវប្បធម៌ស្អុយរលួយមិនមានតទៅទៀតឡើយដោយសារតែ វប្បធម៌ទាំងអស់នេះត្រូវបានបោសសម្អាតរួមជាមួយនឹងពួកចក្រពត្តិបរទេស"។

[១៣:៥៩:០៥]

លោក លោកស្រីចៅក្រម, ខៀវ សំផន ក៏បានបង្ហាញផងដែរអំពីការស្អប់ខ្ពើមចំពោះសង្គមដែលបក្សកុម្មុយនីស្តកម្ពុជាបានផ្តួលរំលំនៅក្នុងថ្ងៃ ១៧ មេសា ឆ្នាំ៧៥ ហើយដែលបានបញ្ចូលទៅក្នុងសហករណ៍។ គាត់បាននិយាយអំពីប្រជាជនទាំងអស់នេះថា “ជនបណ្តាផ្ទះនៅតាមទីក្រុងភ្នំពេញពោរពេញទៅដោយអ្វីដែលយើងមិនអាចគិតដល់។ ខ្ញុំមិនថាតើយើងត្រូវពិពណ៌នាអំពីពួកគេយ៉ាងដូចម្តេចទេ? ផ្ទះទាំងអស់នេះមិនមានលក្ខណៈជាតិអ្វីទាំងអស់ ដោយសារហេតុផលទាំងអស់នេះហើយយើងជំទាស់យ៉ាងខ្លាំងទៅលើវប្បធម៌បែបនេះ។ ប្រសិនបើយើងឲ្យមានវប្បធម៌ស្អុយរលួយបែបនេះបន្តស៊ីរូងប្រទេសរបស់យើង យើងប្រាកដណាស់ជាមិនអាចការពារប្រទេសជាតិយើងបាននោះទេ”។

លោក លោកស្រីចៅក្រម សេចក្តីថ្លែងការណ៍ទាំងអស់នេះបានបង្ហាញអំពីគំនិតរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងប្រជាជនថ្មី។ គាត់ដឹងថាពួកគេត្រូវបានបណ្តេញចេញពីប្រជាជន ហើយមិនអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញទេ។ គាត់ដឹងថាប្រជាជនត្រូវបានរារាំងមិនឲ្យរស់នៅជាមួយគ្រួសាររបស់គេ ប៉ុន្តែហាក់ដូចជាមិនមានការអាណិតអីទាំងអស់។ ចំពោះគាត់ ផ្ទះដែលប្រជាជនដែលត្រូវបានគេបណ្តេញចេញគឺពោរពេញទៅដោយវត្ថុដែលមិនអាចគិតទៅដល់បាន។

[១៤:០០:២៥]

លោក លោកស្រីចៅក្រម, ខៀវ សំផន ក៏បានជម្រាបផងដែរអំពីការហាមឃាត់សាសនាប្រតិកិរិយានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលគាត់បាននិយាយថា “គោលជំហររបស់យើង គឺមិនអនុញ្ញាតឲ្យមានចក្រពត្តិបរទេស ប្រើប្រាស់សាសនាដើម្បីធ្វើវិទ្ធង្សនាយើងបានឡើយ។ យើងសម្រេចថាវាយប្រយុទ្ធជាមួយពួកគេទោះបីពួកគេប្រើប្រាស់មធ្យោបាយបែបណាក៏ដោយ។ ពួកចក្រពត្តិព្យាយាមស្វែងរកមធ្យោបាយដើម្បីវាយប្រហារពួកយើង ក្នុងចំណោមនោះគឺការប្រើប្រាស់សាសនា ដើម្បីជ្រៀតចូលក្នុងប្រទេសយើង។ ដូច្នេះយើងត្រូវជំទាស់ប្រឆាំងទៅនឹងពួកគេតាមគ្រប់រូបភាព”។

លោក លោកស្រីចៅក្រម នៅក្នុងសុន្ទរកថាខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន បានលើកឡើងថា “បក្សកុម្មុយនីស្តកម្ពុជាបានបង្កើននៃចលនារីកចម្រើន ដើម្បីលើកកម្ពស់ការផលិតកសិកម្ម”។ នេះគឺជានិយាយច្បាស់អំពីសេចក្តីសម្រេចឆ្នាំ១៩៧៥ ដែលយើងបានពិភាក្សាពីពេលមុន។ នៅក្នុងខែមេសា ១៩៧៧ គាត់បានលើកសរសើរអំពីគម្រោងពលកម្មដោយបង្ខំនៅក្នុងសុន្ទរកថារបស់គាត់។ ការដ្ឋានជាច្រើននៃការកសាងទំនប់ ប្រឡាយ គឺមានប្រជាជនចូលរួមប្រហែលជា ១០.០០០, ២០.០០០ ឬក៏ដល់តែ

៣០.០០០នាក់ឯណោះ។ ការងារទាំងអស់នេះត្រូវធ្វើដោយដៃ ពីព្រោះថានេះគឺជាអ្វីដែលមជ្ឈិមបក្សបានកំណត់។ នៅក្នុងការនិយាយរបស់ ខៀវ សំផន គាត់និយាយថា "យើងគ្មានម៉ាស៊ីនទេ យើងធ្វើអ្វីៗទាំងអស់ដោយពឹងផ្អែកទៅលើកម្លាំងប្រជាជន។ ទោះបីថាដៃទទេក៏ដោយ ក៏ប្រជាជនយើងអាចធ្វើអ្វីបានគ្រប់យ៉ាង"។ គាត់ក៏បានកត់សម្គាល់ពីការឯកភាពពីលើការផ្ទេរសហករណ៍ ដើម្បីជួយបំពេញការងារនៅលើសមរភូមិមុខដទៃទៀតនៅក្នុងភូមិភាគតំបន់ និងស្រុកនានា។ ដែលនេះគឺជាការនិយាយយោងផ្ទាល់ទៅលើការអនុវត្ត ការជម្លៀសប្រជាជនដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:០២:៣៤]

ខៀវ សំផន ក៏បានគាំទ្រទៅដល់ការប្រើប្រាស់កុមារធ្វើជាទាសករផងដែរ។ កុមារមិនបានចូលរួម -- មិនបានទៅសាលាទេដោយសារមិនមានសាលា។ ពួកគេត្រូវបានគេបំបែកចេញពីឪពុកម្តាយ ហើយត្រូវបានបញ្ជូនទៅធ្វើការនៅតាមវាលស្រែ ប៉ុន្តែយោងតាម ខៀវ សំផន, ក្មេងៗទាំងអស់នោះគឺដូចជារីករាយនៅក្នុងបំពេញការងារ។ "ក្មេងៗគឺរីករាយនៅពេលដែលពួកគេចូលរួមនៅក្នុងការដេញចាបមើលថែគោក្របី ប្រមូលជីធម្មជាតិ និងចូលរួមនៅក្នុងការកសាងទំនប់ ប្រឡាយ ឬក៏ជីកអាងស្តុកទឹក។ កុមារយើងបានធ្វើការចូលរួមយ៉ាងខ្លាំង ហើយពួកគេធ្វើការបណ្តុះបណ្តាលយ៉ាងខ្លាំង"។

លោក លោកស្រីចៅក្រម! នៅក្នុងសុន្ទរកថាដដែលនេះ ខៀវ សំផន បានទទួលស្គាល់ថា របបម្ហូបអាហារត្រូវបានកំណត់ដោយរដ្ឋ។ នេះគឺជាឧទាហរណ៍ដែលថាគាត់គាំទ្រទៅដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការប្រើប្រាស់កុហក ដែលវាខុសទាំងស្រុងទៅនឹងការពិតដែលជាការឈឺចាប់ដែលប្រជាជនបានទទួលស្គាល់។ គាត់បានពណ៌នាថា "របបអាហារប្រចាំថ្ងៃគឺមានប្រហែលជាបី, ពីរកន្លះ ឬក៏ពីរកំប៉ុងអង្ករ"។ គាត់អះអាងថា "ជាទូទៅ ប្រជាជនហូបបង្អែមបីដងក្នុងមួយខែ ដែលរបបទាំងអស់នេះគឺគ្រប់គ្រាន់ដើម្បីពួកគេមានសុខភាពល្អបរិបូរ ហើយនិងធ្វើឲ្យពួកគេធំធាត់បាន"។ ខៀវ សំផន ក៏បានឃើញដោយផ្ទាល់ភ្នែកនូវស្ថានភាពពលកម្មដោយបង្ខំ។ ឧទាហរណ៍នៅក្នុងចុងឆ្នាំ១៩៧៥ ឬក៏ដើមឆ្នាំ១៩៧៦ គាត់ធ្វើដំណើរជាមួយសម្តេច នរោត្តម សីហនុ ទៅខាងភូមិភាគឧត្តរ។ គាត់មានមោទនភាពដែលបានបង្ហាញដល់សម្តេចព្រះបិតាជាតិ នូវការសម្រេចរបស់កម្មវិធីទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា"។ នេះគឺជាអ្វីដែលសម្តេច នរោត្តម សីហនុ បានពណ៌នា៖

"ខ្ញុំមើលទៅកាន់លោក ខៀវ សំផន ដែលជាដៃគូធ្វើដំណើរជាមួយខ្ញុំនៅតាមទីរួមខេត្តនានា។ ខ្ញុំអរគុណដែលបានសរសើរ ហើយខ្ញុំជឿជាក់ចំពោះគាត់ថា -- ឧទាហរណ៍គាត់ប្រាប់ខ្ញុំថា ក្នុងខែទី១

បន្ទាប់ពីការរំដោះ ស្ត្រី និងបុរសត្រូវបានគេឲ្យមកអូសរទេះ ដើម្បីដាំដំណាំ”។

នេះគឺជាការទទួលស្គាល់យ៉ាងច្បាស់លាស់ដោយ ខៀវ សំផន។ ដោយគាត់ទទួលស្គាល់យ៉ាងច្បាស់ ហើយនិងគាំទ្រទៅដល់កម្មវិធីទាសករ និងកម្មវិធីពលកម្មដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា។ ទោះបីថា នៅពេលនោះការជម្លៀសដោយបង្ខំជាលើកទី២ កំពុងតែបន្តក៏ដោយ។ ខៀវ សំផន ក៏បានទទួលស្គាល់ផងដែរ នៅក្នុងសៀវភៅរបស់គាត់នៅឆ្នាំ២០០៤ ហើយនិងមុនពេលមកតុលាការនេះ អំពីការទៅមើលទំនប់ត្រពាំងថ្មៃ(*ស៊ីក*)។ ទំនប់នេះស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាស្ថិតនៅក្នុងភូមិភាគ៥នៃ -- នៅក្នុងតំបន់៥នៃភូមិភាគពាយ័ព្យ។ តំបន់នេះគឺជាកន្លែងប្រមូលផ្តុំប្រជាជនយ៉ាងច្រើន ដែលគេត្រូវបានគេបញ្ជូនទៅក្នុងការជម្លៀសដែលបង្ខំលើកទី២។ នៅទីនេះគឺប្រជាជនថ្មីរាប់ពាន់រួមទាំងបញ្ចូលទាំងកុមារផង ត្រូវបានគេបង្ខំឲ្យបំពេញការងារជាទាសករនៅត្រពាំងថ្មី(*ស៊ីក*)។ ប្រជាជនភាគច្រើន បានសម្លាប់ដោយសារតែការអត់អាហារ ជំងឺ ហើយនិងសម្លាប់នៅតំបន់ត្រពាំងថ្មី ក្នុងការអនុវត្តកម្មវិធីដាក់ឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:០៦:២៧]

លោក លោកស្រីចៅក្រម ឥឡូវនេះ ខ្ញុំនឹងត្រឡប់ទៅការចូលរួមរបស់លោក នួន ជា ក្នុងឋានៈគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងគណៈអចិន្ត្រៃយ៍។ គាត់ដើរតួនាទីដ៏សំខាន់ក្នុងការបង្កើតនិងការអនុវត្តកម្មវិធីដាក់ឲ្យទៅជាទាសករបក្សកុម្មុយនីស្តកម្ពុជា។ គាត់បានទទួលស្គាល់ថា គាត់បានសរសេរសារចរទង់បដិវត្ត ដែលគាត់បានពិនិត្យមើល ឃើញថាមានការបកស្រាយយ៉ាងច្បាស់ពីមាគ៌បក្ស ហើយនិងការណែនាំដល់កម្មាភិបាលក្នុងការអនុវត្ត។ ដូចសមមិត្ត ខៀវ សំផន របស់គាត់ដែរ លោក នួន ជា ក៏បានអនុវត្ត ហើយនិងទទួលស្គាល់កម្មវិធីដាក់ឲ្យទៅជាទាសកររបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងសុន្ទរកថាខែមករា ឆ្នាំ១៩៧៧ ក្នុងបុណ្យខួបកងទ័ពទី៩ នួន ជា បានិយាយថា សូមដកស្រង់៖ “អ្វីបានយើងត្រូវតែបន្តអនុវត្តសកម្មភាពដ៏ល្អរបស់យើង? យើងត្រូវតែធ្វើបែបនេះ ដើម្បីការពារកម្ពុជាប្រជាធិតេយ្យ។ កម្មករ ពលករកម្ពុជា សហករណ៍ ដើម្បីសម្រេចបាននូវគោលដៅ ១០០០ឆ្នាំ, ១០.០០០ឆ្នាំ ទៅមុខទៀត។ យើងត្រូវកសាងកម្ពុជាប្រជាធិបតេយ្យឲ្យបានឆាប់រហ័សបំផុត។ ដោយមូលហេតុនេះហើយ យើងត្រូវបេសកកម្ម ការងារភារកិច្ចរបស់យើង”។

[១៤:០៧:៥១]

ឥឡូវនេះ គាត់បាននិយាយអួតសំអាងអំពីការប្តេជ្ញារបស់រដ្ឋអំពីរបបអាហារ ក្នុងការដាក់ប្រជា

ជនឲ្យទៅជាទាសករ។ ហើយការទទួលស្គាល់ថារបាយការណ៍មេដឹកនាំបានទទួលគ្រប់គ្រងអំពីអនុវត្តកម្មវិធីនេះ។ សូមអនុញ្ញាតដកស្រង់៖ “បន្ទាប់ពីសង្គ្រាម យើងបានជួបការលំបាកមួយចំនួន ប៉ុន្តែបញ្ហាទាំងអស់នេះ យើងបានដោះស្រាយអស់ហើយ។ បន្ទាប់មកយើងមានបញ្ហាផ្សេងទៀត តើយើងដោះស្រាយបានទេ? តើយើងសម្រេចបាននូវផែនការ ១៩៧៦ទេ? តើយើងអាចអនុវត្តនូវរបបអង្ករដែលរដ្ឋកំណត់ទេ? បញ្ហាទី១ គឺថាត្រូវ៣០គីឡូក្រាម។ ទី២) ២៥គីឡូក្រាម ហើយនិងទី៣) ២០ -- អង្ករ ២០ គីឡូក្រាមសម្រាប់បុគ្គលម្នាក់ក្នុងមួយខែ។ ការងារនេះ គឺត្រូវផ្អែកទៅលើទំហំការងារក្នុងការអនុវត្តបទបញ្ជានេះ។ អនុលោមតាមរបាយការណ៍នេះ គឺយើងត្រូវធ្វើឲ្យបានគ្រប់តំបន់ គឺផ្អែកទៅតាមទស្សនកិច្ចរបស់យើង យើងពិនិត្យឃើញថា ការអនុវត្តតាមការណែនាំនេះ គឺត្រឹមត្រូវ”។

លោក លោកស្រីចៅក្រម ភស្តុតាងដែលបង្ហាញថា នួន ជា ថាមានអាហារគ្រប់គ្រាន់នោះ គឺជាការកុហកទេ។ គាត់គឺជាការកុហក ដើម្បីអនុវត្តការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីការពារនិងលើកកម្ពស់របបនៃការដាក់ឲ្យទៅជាទាសករ។ ការថ្លែងជាសាធារណៈរបស់ នួន ជា ដែលចេញពីមន្ទីរថ្នាក់ខ្ពស់បំផុតនៅលើប្រទេស គឺនិយាយអំពីការអនុវត្តគោលនយោបាយរបស់បក្ស រំឭកពួកគេពីភារកិច្ច ហើយធានាអំពីការគោរពតាម។

[១៤:០៩:៣៦]

ចម្លើយរបស់ នួន ជា ដែលធ្វើនៅពេលនោះ នៅពេលដែលអ្នកជម្លៀសរាប់លាននាក់រងគ្រោះពីការអត់អាហារនៅក្នុងការដ្ឋានពលកម្ម ប៉ុន្តែកម្មាភិបាលមួយៗត្រូវតែឆ្លើយតបទៅមជ្ឈិមបក្ស។ សាក្សីម្នាក់បាននិយាយថាអំពីការថ្លែងការណ៍ជាសាធារណៈរបស់មេដឹកនាំ ទាក់ទងទៅនឹងរបបអាហារកម្ពុជាប្រជាធិបតេយ្យនៅក្នុងបទសម្ភាសន៍ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឯកសារ E3/5234 សូមដកស្រង់៖ “ខ្ញុំមិនដែលបំភ្លេចទេ នៅពេលមួយគឺថាអង្ករមួយកំប៉ុងសម្រាប់៤០នាក់ ហើយមនុស្សជាច្រើនបានស្លាប់អំពីការអត់អាហារ”។

លោក លោកស្រីចៅក្រម នៅថ្ងៃទី៣០-៣១ កក្កដា ឆ្នាំ១៩៧៨ នួន ជា បានផ្តល់បទសម្ភាសន៍ទៅឲ្យគណៈប្រតិភូមិមកពីបក្សពលករកុម្មុយនីស្តរបស់ដាណឺម៉ាក។ គាត់បាននិយាយក្នុងនាមបក្សកុម្មុយនីស្តកម្ពុជាក្នុងសមត្ថភាពជាអនុលេខា។ ក្នុងការធ្វើសេចក្តីប្រកាសនោះ គាត់បានយល់ស្របទៅលើផែនការឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា កោតសរសើរ ហើយនិងពន្យល់ទៅដល់ភ្ញៀវអន្តរជាតិ។ នៅពេលដែលគេសួរថា “តើកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាដូចម៉េច?” គាត់និយាយថា “បាទ យើង

មានកម្មវិធី ប៉ុន្តែមានតែកម្ពុជាទេ។ យើងមានភារកិច្ចជាច្រើន យើងមិនទាន់បានធ្វើការឃោនាគ្រប់គ្រាន់នៅអន្តរជាតិទេ។ ខ្មាំងវៀតណាម មាន -- ធ្វើការ -- បានធ្វើការឃោសនាខ្លាំងប្រឆាំងនឹងយើងនៅអន្តរជាតិ ហើយយើងខ្វះការងារឃោសនាការនៅក្នុងឆាកអន្តរជាតិ”។

[១៤:១១:២៧]

លោក លោកស្រីចៅក្រម នៅបទសម្ភាសន៍ដែលនោះ លោក នួន ជា បញ្ជាក់ថា “បន្ទាប់ពីការរំដោះភារកិច្ចរបស់បដិវត្តន៍សង្គមនិយម ហើយនិងការកសាងសង្គមនិយមនោះ គឺត្រូវបានចាប់ផ្តើម”។ ហើយខ្ញុំសូមជម្រាបថា សេចក្តីយោងទៅសេចក្តីសម្រេច ឆ្នាំ១៩៧៥ ប៉ុន្តែខ្ញុំមិននិយាយលម្អិតពីខាងដើមនោះ។ នួន ជា បានយោងទៅរកជីវិភាពរស់នៅរបស់ប្រជាជន ហើយសូមដកស្រង់សម្តីគាត់៖

“ចំពោះជីវភាពរស់នៅវិញ ជាមូលដ្ឋានយើងដោះស្រាយបញ្ហានោះបានហើយ តាមកម្មវិធីធារាសាស្ត្រ។ យើងមានកម្លាំងគ្រប់គ្រាន់ដើម្បីការអភិវឌ្ឍន៍ប្រទេសរបស់យើង ដើម្បីឱ្យយើងអាចរស់រានដោយខ្លួនឯងបាន”។ ចប់សេចក្តីដកស្រង់។

ប្រព័ន្ធធារាសាស្ត្រដែលគាត់បានយោងទៅរកនោះ គឺត្រូវបានសាងសង់ដោយកងកម្លាំង -- ដោយកម្លាំងពលកម្មទាសករ ដូចដែលយើងបានដឹង។ នួន ជា ក៏បានពន្យល់ជាបន្តបន្ទាប់ថា អាទិភាពរបស់បក្សកុម្មុយនីស្តកម្ពុជាម្យ៉ាងទៀតនោះ គឺធាតុផ្សំនីមួយៗត្រូវបន្តក្នុងលក្ខណៈជាផែនការឧក្រិដ្ឋ ហើយគេបន្តកសាងការពាររបស់បក្សរបស់គេ ហើយចាប់អ្នកទាំងអស់ណាដែលគេចោទថា ស៊ីរូងផ្ទៃក្នុង ហើយផែនការរបស់គេមិនត្រឹមតែភ្នាក់ងារវៀតណាមទេ គឺមិននិយាយត្រឹមតែចក្រពត្តិនិយមអាមេរិក កា.ហ្សេ.បេ ទេ គឺអ្នកទាំងអស់គ្នាណាដែលគេយល់ថាជាខ្មាំង។

[១៤:១២:៥៦]

លោក ខៀវ សំផន ហើយនិង នួន ជា ដែលបានធ្វើសេចក្តីថ្លែងការណ៍ និងសុន្ទរកថា នៅពេលដែលគាត់បានបង្រៀន ពន្យល់អំពីការអនុវត្តមាគ៌ាបក្ស គេយល់ថាគេពង្រីកមាគ៌ាបក្សឧក្រិដ្ឋរបស់គេ ហើយគេនិយាយថា “មិនមានអ្នកណាធ្វើដូចពួកគេទេ។ ប្រជាជនទូទាំងប្រទេសត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពួកគាត់ ដែលពួកគេទាំងពីរនាក់ជាមេដឹកនាំជាន់ខ្ពស់ជាអ្នកសម្រេចថាសមស្រប”។

ដើម្បីរំឭកអំពីសេចក្តីសន្និដ្ឋាន អំពីការទទួលខុសត្រូវពីជនជាប់ចោទទាំងពីរក្នុងការជម្លៀសទី២នេះ គឺបទឧក្រិដ្ឋទាងអស់ដែលបានប្រព្រឹត្តឡើងនៅក្នុងការជម្លៀសដោយបង្ខំ ជាផ្នែកមួយនៃផែនការឧក្រិដ្ឋរួម ហើយនិងការដាក់ឲ្យទៅជាទាសករ ពលកម្មដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ ដែលតម្រង់ទៅ

រកជាសំខាន់ គឺប្រជាជនថ្មី។ ផែនការនេះត្រូវបានបង្កើត ហើយនិងអនុវត្តដោយមជ្ឈិមបក្សកុម្មុយនីស្ត កម្ពុជា ដែល នួន ជា និង ខៀវ សំផន បានដើរតួនាទីយ៉ាងសំខាន់។ ដើម្បីត្រឡប់ទៅគំនិតមួយដែលនិយាយអំពីការបំបាត់មនុស្សធម៌ ហើយនិងការបង្កនូវភាពឈឺចាប់ទៅលើជនរងគ្រោះ ដោយសេចក្តីសម្រេចរបស់មជ្ឈិមបក្សក្នុងការអនុវត្តការជម្លៀសលើកទី២នេះ ខ្ញុំសូមអនុញ្ញាតដកស្រង់សម្តីរបស់ ហ្វីលីព ស្សូត ដែលលោកសរសេរថា សូមដកស្រង់៖ "ពេលនោះ គឺអាក្រក់ណាស់ មិនមានថាពាយ័ព្យមិនអាចគ្រប់គ្រងមនុស្សរាប់រយពាន់នាក់នោះបានទេ គេមិនអាចដាំដំណាំស្រូវថ្មី ដើម្បីចិញ្ចឹមអ្នកទាំងអស់នេះ ដែលថាគេមិនមានដីគ្រប់គ្រាន់ គឺសម្រាប់តែប្រជាជនមួយចំនួនតូចក្នុងតែប៉ុន្មានខេត្តប៉ុណ្ណោះ ជាពិសេសទៅទៀត នេះជាមេរៀនដ៏ធ្ងន់បំផុត ដែលបន្ទាប់ពីការជម្លៀសក្នុងខែមេសា។ ចំពោះ ប៉ុល ហើយនិងអ្នករួមការងាររបស់គាត់ ប្រជាជនលែងក្លាយជាមនុស្សលោកទៀតហើយ ម្នាក់ៗគឺមានសេចក្តីសង្ឃឹម ភ័យខ្លាច អស់សង្ឃឹម ហើយគេក្លាយទៅជាឧបករណ៍ដាច់ថ្លៃរបស់បក្សដោយគ្មានព្រលឹងទេ ត្រូវតែធ្វើការឲ្យបក្សតាមតែគេកំណត់"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១៤:១៥:១២]

លោកប្រធាន! ឥឡូវនេះខ្ញុំសូមអនុញ្ញាតចូលទៅដល់ផ្នែកទី៣។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំដែលថាអ្នកទាំងពីរនេះបានចូលរួមទៅនឹងបទឧក្រិដ្ឋ ដែលមានការចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។ ឥឡូវនេះខ្ញុំជម្រាបជូនថា ជនជាប់ចោទទាំងពីរនេះជាអ្នកទទួលខុសត្រូវចំពោះការកាប់សម្លាប់ទាហានលន់ នល់ ហើយនិងរដ្ឋការលន់ នល់ នៅទួលពោធិ៍ជ្រៃ។

លោក លោកស្រីចៅក្រមនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះថា បទឧក្រិដ្ឋទាំងអស់នេះត្រូវបានប្រព្រឹត្តដោយអនុលោកតាមផែនការឧក្រិដ្ឋកម្មរួមទូលំទូលាយ ដោយប្រើហិង្សាបដិវត្តន៍ដើម្បីវាយប្រហារលុបបំបាត់ខ្មាំងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ មន្ត្រីសាធារណរដ្ឋខ្មែរ និងទាហានជាខ្មាំងលេខ១ ទាំងនៅក្នុងពេលវេលាមុន ហើយនិងភ្លាមៗបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ភស្តុតាងបានបង្ហាញឲ្យហួសពីវិមតិសង្ស័យថា ទាំង នួន ជា ហើយនិង ខៀវ សំផន បានចូលរួម ហើយបានយល់ព្រមជាមួយផែនការបក្សកុម្មុយនីសកម្ពុជាដើម្បីប្រើហិង្សា ដើម្បីបំបាត់ខ្មាំងរបស់បក្ស។ ហើយជនជាប់ចោទបានដឹង ហើយបានយល់ស្របជាមួយការកំណត់ទិសទៅទៅលើអ្នករដ្ឋការលន់នល់ និងទាហានលន់នល់ ថាជាក្រុមខ្មាំងមួយដែលត្រូវស្វែងរក និងត្រូវលុបបំបាត់ដោយបក្សកុម្មុយនីស្តកម្ពុជា។ គឺ នួន ជា រួមជាមួយប៉ុល ពត បានធ្វើមាគ៌ាបក្សពីដំបូងដែលអនុញ្ញាតឲ្យប្រើហិង្សា

បដិវត្តន៍ប្រឆាំងនឹងខ្មាំងវណ្ណៈ តាមរយៈវិធានការខុសច្បាប់ ហើយដែលសម្រេចនៅក្នុងសមាជទី១ ក្នុងឆ្នាំ១៩៦០របស់បក្ស ហើយនិងសមាជបក្សជាបន្តបន្ទាប់ដូចជាសមាជិកសមាជ ដែលខៀវ សំផន បានចូលរួមនៅក្នុងឆ្នាំ១៩៧១ និង១៩៧៦។

[១៤:១៧:១៧]

នួន ជា បានបញ្ជាក់ថាគាត់យល់ព្រមជាមួយមាគ៌ាបក្សស្ទួលនេះ នៅក្នុងសន្ទរកថាដែលគាត់បានថ្លែងទៅកាន់មហាជននៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ នៅក្នុងឱកាសឆ្នាំខួបទី៩ នៃបក្សកុម្មុយនីស្តកម្ពុជា។ សូមដកស្រង់៖ "យើងបានប្រកាន់ជំហរដ៏ប្រាកដនិយមដើម្បីផ្តួលរលំ និងកម្ទេចចក្រពត្តិនិយមសហរដ្ឋអាមេរិក និងបរិវាររបស់វា ហើយនិងវណ្ណៈជិះជាន់គ្រប់សកម្មភាពទាំងអស់។ ក្រោយពីឆ្នាំ១៩៦០ អង្គការបដិវត្តន៍បានសម្រេចយ៉ាងច្បាស់ថាចំណាត់ការនយោបាយ ប្រដាប់អាវុធត្រូវតែប្រើដើម្បីផ្តួល និងកម្ទេចខ្មាំង"។ សូមចប់សេចក្តីដកស្រង់។

លោក នួន ជា បានទទួលថានៅក្នុង -- តាំងពីចាប់ផ្តើមនូវសវនាការនេះ មាគ៌ាយុទ្ធវិធីរបស់បក្សគឺត្រូវបានអនុម័តនៅក្នុងសមាជដំបូង ហើយត្រូវប្រើវិធីស្របច្បាប់ និងមិនស្របច្បាប់ក្នុងការតស៊ូ។ ដូចដែលលោកជំទាវ ជា លាង បានពិភាក្សាកាលពីថ្ងៃព្រហស្បតិ៍ ការប្រើហិង្សាដោយបក្សកុម្មុយនីស្តកម្ពុជាមិនកម្រិតត្រឹមតែជាការការពារខ្លួនស្របច្បាប់ ការប្រយុទ្ធប្រឆាំងនឹងយុទ្ធជននៅក្នុងសង្គ្រាមប្រឆាំងនឹងរបបរដ្ឋាភិបាលសីហនុ ហើយនិងសាធារណខ្មែរនោះទេ។ ចាប់ផ្តើមនៅឆ្នាំ១៩៦១ នួន ជា, ប៉ុល ពត បានបង្កើតអង្គភាពមួយហៅថា "កងការពារសម្ងាត់"។ នួន បានបញ្ជាក់នៅក្នុងសុន្ទរកថាខែមករា ឆ្នាំ១៩៧៧ ហើយគាត់បានទទួលស្គាល់នៅក្នុងសវនាការនេះថា "បក្សបានជ្រើសរើសយុវជនហើយនិងកុមារកសិករ ដើម្បីធ្វើការនៅក្នុងកងការពារសម្ងាត់ ហើយលាក់ពួកគេនៅក្នុងភូមិ និងមូលដ្ឋាន ហើយនៅក្នុងទីប្រជុំជន។ កងសម្ងាត់ទាំងអស់នេះគឺមិនមានភារកិច្ចត្រឹមតែការពារប៉ុណ្ណោះទេប៉ុន្តែរក្សាសន្តិសុខកម្មាភិបាលផងដែរ"។ ដូចដែលបានបញ្ជាក់នៅក្នុងទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ កងការពារសម្ងាត់ហ្នឹងគឺមានភារកិច្ចសម្ងាត់ ដើម្បីកម្ទេចខ្មាំងជាសម្ងាត់ភ្នាក់ងាររដ្ឋាភិបាល ហើយនិងពួកប្រតិកិរិយាផ្សេងៗ។

[១៤:១៩:៤៨]

នៅពេលដែល នួន ជា ត្រូវបានសួរដោយចៅក្រម ខាតវ៉ាយថ៍ អំពីចម្លើយរបស់គាត់ទាក់ទងទៅនឹងទង់បដិវត្តនោះ គាត់បានទទួលស្គាល់ថា កងសម្ងាត់នៃយុវជននេះ គឺបានទទួលអំណាចនៅក្នុងការ

សម្លាប់គិញដែលបង្កប់នៅក្នុងអង្គប្រជុំនានា។ នេះក៏ជាការអនុវត្តដែល ខៀវ សំផន បានដឹងដែរ ដែលគាត់បានទទួលស្គាល់ក្នុងចម្លើយ ដែលលោកស្រី នួន ជា (*ស៊ីក*) បានលើកឡើងពីសប្តាហ៍មុនថា សូមដកស្រង់៖ "ភ្នាក់ងារសម្ងាត់មូលដ្ឋានដែលគេពិនិត្យឃើញថា ធ្វើចារកិច្ចនៅក្នុងការប្រជុំត្រូវបានគេចាប់ចង ហើយគេកម្ទេចចោលភ្លាមនៅពេលនោះ"។ ចប់ដកស្រង់។

នៅពេលដែលសហព្រះរាជអាជ្ញាសួរទៅលោក នួន ជា ថា "តើគិញ ហើយនិងខ្មាំងដែលគេចាប់បាន ដែលកងការពារសម្ងាត់គេរកឃើញ...?" គាត់បានឆ្លើយចំណុចបន្តិចនៅក្នុងចម្លើយរបស់គាត់។ ខ្ញុំសូមអនុញ្ញាតដើម្បីផ្សាយនៅក្នុងវីដេអូបាទ។

[១៤:២០:៥៥]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"...អំពីបដិវត្តន៍ អំពីខ្មាំង ដែលប្រឆាំងនឹងអង្គការ។ ជាលទ្ធផលខ្មាំង គិញ ត្រូវបានចាត់តាំង។ "នួន ជា៖ លោកប្រធាន, ពាក់ព័ន្ធនឹងបញ្ហានេះកម្ពុជាប្រជាធិបតេយ្យមានប្រុងប្រយ័ត្នណាស់អំពីបដិវត្តន៍របស់ខ្លួន ហើយនិងជនក្បត់ ដែលបង្កប់ៗចូលទៅក្នុងអង្គការ។ ជាលទ្ធផលគិញត្រូវបានគេចាត់តាំងដើម្បីឱ្យចូលប្រមូលព័ត៌មានពីអ្នកទាំងនោះមុនពេលដែលគេរាយការណ៍ព័ត៌មានទាំងអស់នោះទៅឱ្យមេរបស់គេ ដែលនឹងធ្វើការពិភាក្សាលើបញ្ហាមួយចំនួន មុនពេលដែលគេដាក់នូវវិធានការរបស់គេ ដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ។ លីសាក់៖ តើអ្នកណាជាអ្នកត្រូវពិភាក្សាបញ្ហា ដែលត្រូវធ្វើឡើងប្រឆាំងនឹងខ្មាំង? នួន ជា៖ អ្នកទាំងអស់នោះដែលមានអំណាចក្នុងធ្វើការនោះ គឺជាអ្នកដែលមានភារកិច្ចក្នុងការធ្វើចារកម្ម ហើយនិងតាមដានមនុស្សដែលធ្វើសកម្មភាពឱ្យសង្ស័យ ហើយដែលមានសកម្មភាពរបស់អ្នកទាំងនោះត្រូវបានចាត់ទុកជាសកម្មភាពរបស់ពួកអ្នកបង្កប់នៅក្នុងបក្ស។ លីសាក់៖ ប៉ុន្តែនៅពេលដែលគេកំណត់ថាបុគ្គលណាម្នាក់ថាជាចារកិច្ច ដែលបង្កប់នៅក្នុងកិច្ចប្រជុំរបស់បក្សដូចដែលលោកបាននិយាយនោះ តើគេយកទៅមន្ទីរសន្តិសុខ? តើគេសម្លាប់អ្នកនោះ ឬគេអនុញ្ញាតឱ្យអ្នកហ្នឹងទៅខ្មាំងវិញ? តើគេយកអ្នកទាំងហ្នឹងទៅធ្វើដូចម្តេចនៅពេលដែលអង្គភាពសម្ងាត់ត្រូវបានកំណត់ថា អ្នកហ្នឹងជាអ្នកបង្កប់ក្នុងបក្សហើយនោះ? នួន ជា៖ ការងារនេះត្រូវតែប្រើវែងក្នុងការស៊ើបអង្កេតអ្នកទាំងនោះ។ វាអាចថាប្រើពេលមួយឆ្នាំ ឬក៏ពីរឆ្នាំ ឬក៏លើសពីហ្នឹង។ ហើយអ្នកដែលក្រោយមកត្រូវបានគេប្រមូលផ្តុំហើយបញ្ជូនទៅស-២១ ជាកន្លែងដែលគេប្រមូលចម្លើយសារភាព ហើយនិងសក្ខីកម្មអ្នកទាំងនោះត្រូវបានគេប្រមូលយក"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២៥:៤៩]

**លោក វីណ្ឌៀម ស្មីត៖**

លោក លោកស្រីចៅក្រម នៅពេលពិនិត្យត្រង់ចំណុចនេះជាមួយលោក នួនជា នោះបន្ទាប់មក លោក នួន ជា ហាក់ដូចជាដឹងថាមានចំណុចដាក់បន្ទុកនៅក្នុងចម្លើយរបស់គាត់។ ហើយនៅពេលសួរចំណុចដែលមាននៅក្នុងវីដេអូ នៅពេលដែលនិយាយអំពីសន្តិសុខមុនពេល៧៥ គាត់ក៏ថយត្រឡប់ទៅរកចម្លើយពីមុនរបស់គាត់។ គាត់ឆ្លើយថា៖ “ខ្ញុំមិនដឹងរឿងនេះច្បាស់លាស់ទេ ប៉ុន្តែខ្ញុំមិនដែលបានទទួលបន្ទុកសន្តិសុខទេ តួនាទីរបស់ខ្ញុំគឺគ្រាន់តែមើលខាងការងារសភា” គាត់ឆ្លើយបែបនេះវិញ។

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំត្រឡប់ទៅយកភស្តុតាងវិញពីព្រោះថា បង្ហាញថាវាជាការយល់ដឹងរួមគ្នាហើយនិងការយល់ព្រមជាមួយគ្នារវាង នួន ជា និង ខៀវ សំផន ហើយនិងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតអំពីការប្រើហិង្សាតាមវិធីខុសច្បាប់ដើម្បីលុបបំបាត់បុគ្គលទាំងឡាយ ដែលគេចាត់ទុកថាជាខ្មាំងគិញ ឬក៏ជាជនក្បត់។

ទោះជាតាមវិធីណាក្តី ការប្រើហិង្សាដោយបក្សកុម្មុយនីស្តកម្ពុជា គឺស្ថិតនៅក្រៅវិសាលភាពនៃការការពារខ្លួនស្របច្បាប់ ជម្លោះប្រដាប់អាវុធ ហើយនិងដំណើរការយុត្តិធម៌ឆ្ងាយណាស់។ មាគ៌ាបក្សក្នុងការប្រើអំពើហិង្សាបដិវត្តន៍ក្នុងការវាយប្រហារកម្ទេចខ្មាំង មិនបញ្ឈប់នៅពេលដែលសង្គ្រាមប្រឆាំងលន់នល់ ត្រូវបានបញ្ចប់ទេ ហើយនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាទទួលបានអំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះទេ។ ប្រសិនបើការសម្លាប់ក្រៅផ្លូវច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ចប់ ហើយនិងការប្រើប្រាស់អំពើហិង្សាដែលខុសច្បាប់លើសលប់នោះបានបញ្ឈប់នៅថ្ងៃទី១៧ មេសា ឆ្នាំ ១៩៧៥ លោក-លោកស្រីចៅក្រមប្រហែលជាតាមពិតយើងមិនបានមកអង្គុយនៅទីនេះថ្ងៃនេះទេ។ ប៉ុន្តែតាមពិតអំពើឧក្រិដ្ឋនោះមិនបានឈប់ទេ វាបែរជាកាន់តែលឿនខ្លាំងឡើង កាន់តែអាក្រក់ អាក្រក់កាន់ខ្លាំងនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាចជនជាប់ចោទបានដឹងច្បាស់អំពីលក្ខណៈឃោរឃៅគ្មានមេត្តានៃរបបរបស់គេ ហើយបានដឹងថាយោធារបស់ខ្លួននៅមូលដ្ឋានទទួលការលើកទឹកចិត្តមិនមែនជាការដាក់ទណ្ឌកម្មទេ ឲ្យធ្វើអំពើហិង្សានោះ។ នៅពេលដែលមានការកាប់សម្លាប់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយចេះបន្តច្រើនថ្ងៃ ច្រើនសប្តាហ៍ ច្រើនឆ្នាំក្នុងរបបខ្មែរក្រហម ការទាំងនោះមិនធ្វើឲ្យ ខៀវ សំផន និង នួន ជា មានការភ្ញាក់ផ្អើលនោះទេ។

[១៤:២៨:៣៧]

លោក ខៀវ សំផន បានដឹងពីការចាប់ខ្លួន ហើយនិងការសម្លាប់ខ្មាំងថាបន្តទូទាំងកម្ពុជាប្រជាធិបតេយ្យក្រោយពីទាហានលន់នល់ត្រូវបានចុះចាញ់ហើយនោះ។ ការអះអាងប្រាប់ចៅក្រមស៊ើបអង្កេតថាគាត់មិនដឹងអំពីការចាប់ខ្លួនណាមួយទេ នៅពេលដែលគាត់កាន់អំណាច ហើយបានដឹងតែពីការចាប់ខ្លួននោះក្រោយខែមករា ឆ្នាំ១៩៧៩នោះ គឺជាការកុហកដែលមិនគួរឲ្យជឿបានទាល់តែសោះ។ តើយើងត្រូវជឿថា ខៀវ សំផន គឺជាបុគ្គលតែម្នាក់នៅក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យដែលមិនបានដឹងថាមនុស្សនៅជុំវិញគាត់ត្រូវបានគេចាប់ខ្លួន ហើយបាត់ខ្លួនជាបន្តបន្ទាប់មិនដែលឃើញមកវិញនោះ ជាបុរសដែលធ្វើការនៅមន្ទីរ៨៧០ ដែលទទួលទូរលេខ ប្រចាំថ្ងៃហើយរបាយការណ៍លម្អិតរៀបរាប់អំពីការចាប់ខ្លួន ហើយការប្រហារជីវិតនោះ។ ជាបុរសដែលរស់នៅជាមួយ ប៉ុល ពត និង នួន ជា ដែលអង្គុយក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍ជាទៀងទាត់ ហើយនិងការប្រជុំនៅពេលដែលមេដឹកនាំតំបន់ភូមិភាគដែលបានរាយការណ៍ពីសភាពការណ៍គ្រប់តំបន់ទាំងអស់ឲ្យពួកគាត់ដឹង។ យើងបានឃើញជាច្រើនដងហើយនៅក្នុងកំណត់ហេតុអង្គប្រជុំទាំងអស់នោះ បានបង្ហាញថា ខៀវ សំផន បានទទួលដំណឹងទាំងស្រុង ហើយនិងយល់ស្របជាមួយនឹងគោលនយោបាយ ដែលអនុវត្តដោយបក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងខ្មាំងរបស់បក្សនោះ។ លោក ខៀវ សំផន បាននិយាយកុហកសហចៅក្រមស៊ើបអង្កេតអំពីការដឹងរបស់គាត់ពីការចាប់ខ្លួន ពីព្រោះមានរឿងរ៉ាវច្រើនដើម្បីនឹងលាក់ ពីព្រោះមានការ -- គាត់មានការពាក់ព័ន្ធយ៉ាងជ្រៅនៅក្នុងកិច្ចប្រជុំរបស់មេដឹកនាំរបស់បក្ស ដែលនាំឲ្យមានសេចក្ដីសម្រេចឲ្យមានការចាប់ខ្លួន និងការសម្លាប់មនុស្ស។

លោក លោកស្រីចៅក្រម ដូចជា នួន ជា គាត់បានបញ្ជាក់ច្បាស់នៅក្នុងបទសម្ភាសន៍ដែលបានកត់ត្រាថា គាត់បានដឹង ហើយគាត់យល់ស្របជាមួយនឹងការប្រហារជីវិតពួកខ្មាំង។

[១៤:៣០:៥៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ឆ៖ ១) អប់រំឲ្យឈប់, ២) អប់រំពីរបីដងរៀនសូត្រហើយធ្វើជីវទស្សន៍ ដុះ នែ៎គេហៅថា ធ្វើជីវទស្សន៍បដិវត្តន៍ហើយ រួចហើយទិតៀនកសាងថាបើឈប់ទៀត អាហ្នឹងបណ្ដេញចេញ។ បណ្ដេញចេញហើយនៅតែមិនធ្វើអីទៀត ត្រូវដោះស្រាយ នៅតែជជេស អានេះចូលក្នុងប្រភេទឃោរឃៅហើយចូលក្នុងប្រភេទឃោរឃៅ។ ស៖ អ្នកប្រភេទឃោរឃៅហ្នឹង យើងដោះស្រាយយ៉ាងម្ដេចធម្មតា? ឆ៖*

*សម្លាប់ កម្ទេច។ ទុកធ្វើអី ព្រោះទុកទៅវានាំប៉ះពាល់ដល់មាគ៌ាហើយ ធ្វើបាបប្រជាជនៗ។ សះ អ៊ីចឹង ដែលប៉ុល ពត សម្រេចសម្លាប់អ្នកទាំងអស់ហ្នឹង តើអ៊ំយល់ឃើញយ៉ាងណាដែរ? ឆ៖ អាហ្នឹងមិនដឹងឃើញយ៉ាងណាទេ ពេលហ្នឹងក៏អត់យល់ឃើញយ៉ាងណាទេ យល់ឃើញដោះស្រាយឲ្យស្រឡះទៅ ដោយយល់ដោះស្រាយត្រូវ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:៣១:៥៩]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន បើយើងបន្តកាសែតនេះនៅគាត់និយាយថា "នេះជាដំណោះស្រាយត្រឹមត្រូវ"។ លោក លោកស្រីចៅក្រម នៅពេលដែល ថេត សម្បត្តិ សួរលោក នួន ជា អំពីមូលហេតុនៃមេដឹកនាំបក្សកម្ពុជាសម្រេចថា សម្លាប់ប្រជាជននោះ ដែលគេជឿថាជា "ខ្មាំង" នោះ ដោយមិនយកគេទៅដាក់មួយជីវិត លោក នួន ជា បានឆ្លើយដូចខាងក្រោមនេះ។ សូមដកស្រង់៖ "នេះជាបញ្ហាងាយក្នុងការសួរ ប៉ុន្តែពិបាកឆ្លើយ ប៉ុន្តែនៅពេលនោះយើងមិនមានគុកត្រឹមត្រូវទេ ហើយប្រសិនបើទុកពួកគេ ពួកគេអាចរីកដុះដាលហើយមានកូនមានចៅ ហើយយើងពិបាកនឹងធ្វើការគ្រប់គ្រងនិងសម្លាប់" សូមបញ្ចប់សេចក្តីដកស្រង់។ ដូចវិធីសាស្ត្រខាងដើមចម្លើយជាច្រើនដែល ខៀវ សំផន បានធ្វើឡើងរាប់ទាំងបទសម្ភាសន៍ឆ្នាំ១៩៨០ ជាមួយលោក ស្ទីវ ហេដឌ័រ ដែលគាត់បញ្ជាក់យ៉ាងពេញលេញក្នុងការគាំទ្រ យល់ស្របជាមួយ ប៉ុល ពត ទាក់ទងនឹងការចាប់ខ្លួន ហើយនិងការសម្លាប់កម្មាភិបាល ហើយក៏បានទទួលស្គាល់ថាគាត់បានដឹងអំពីការចូលរួមក្នុងការស៊ើបអង្កេតកម្មាភិបាលហើយនិងការបោសសម្អាត។ នៅក្នុងបទសម្ភាសន៍នោះ ខៀវ សំផន បានប្រកាសថា៖ "ត្រឹមឆ្នាំ១៩៧៥ ភ្នាក់ងារខ្មាំងរាប់បញ្ចូលទាំង តិចជាងពាក់កណ្តាលនៃគណៈមជ្ឈិម ប៉ុន្តែស្ទើរតែពាក់កណ្តាលនៃគណៈអចិន្ត្រៃយ៍"។ គាត់ប្រាប់លោក ហេដឌ័រ ថា "នេះគឺជាការប៉ុនប៉ងវាយប្រហារយើងមកពីខាងក្នុងមកវិញ" ចប់សេចក្តីដកស្រង់។ ប៉ុន្តែទោះជាយ៉ាងណាក្តី យើងវាយប្រហារជាបន្តបន្ទាប់ប្រឆាំងពួកការប៉ុនប៉ង ហើយបានបំបាត់ពួកវាទាំងស្រុងអស់ហើយ។

[១៤:៣៣:៥៤]

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ក៏បានធ្វើសុន្ទរកថា ដែលបង្ហាញពីភស្តុតាងថា គាត់ចូលរួម ហើយគាត់យល់ស្របជាមួយនយោបាយបក្សកុម្មុយនីស្តកម្ពុជាអំពីខ្មាំង ដែលរំឭកដល់

កម្មាភិបាលថា “ខ្មាំងស្ថិតនៅគ្រប់ទីកន្លែង ហើយយើងត្រូវតែដកឲ្យអស់ទាំងឫស ហើយនិងលុបបំបាត់ចោល”។

នៅក្នុងសុន្ទរកថាឆ្នាំ១៩៧៧ អបអរសាទរខួបថ្ងៃទី១៧ មេសា ថ្ងៃជោគជ័យនោះ ខៀវ សំផន បាននិយាយថា សូមដកស្រង់៖ “យើងត្រូវតែបំបាត់ខ្មាំងឲ្យអស់នៅក្នុងសមត្ថភាព ដើម្បីម្ចាស់ការលើស្ថានភាព។ អនុវត្តតាមមាគ៌ាក្នុងប្រទេស មាគ៌ានយោបាយបរទេស យោធា ហើយនិងបដិវត្តន៍អង្គការបដិវត្តន៍ អ្វីៗត្រូវតែធ្វើឲ្យបានស្អាត ឲ្យបានហ្មត់ចត់។ យើងមិនត្រូវមានការខកចិត្ត ឬក៏ធ្វេសប្រហែល ឬបំភ្លេចអំពីជោគជ័យនេះទេ ប៉ុន្តែផ្ទុយ យើងត្រូវតែពង្រឹងឲ្យរឹងមាំ ដឹងខ្លួនជានិច្ច ត្រូវតែប្រកាន់ការប្រុងប្រយ័ត្នបដិវត្តដើម្បីវាយប្រហារ ហើយបំបាត់គ្រប់ខ្មាំងទាំងអស់ គ្រប់ពេលវេលា។

[១៤:៣៥:១៧]

លោក លោកស្រីចៅក្រម នៅខែមេសា ឆ្នាំ១៩៧៨ ខៀវ សំផន បានអំពាវនាវឲ្យបំផ្លាញលុបបំបាត់ខ្មាំងឲ្យអស់។ គាត់បាននិយាយថា៖ “បក្សបានចាត់តាំងយើងម្នាក់ៗ ឲ្យធ្វើការងារប្រចាំថ្ងៃ ដើម្បីឲ្យយើងលុបបំបាត់ឲ្យអស់ទាំងស្រុង ឲ្យអស់សាបសូន្យ ខ្មាំងឈ្លានពានគ្រប់ប្រភេទ។ ជាពិសេសពួកវាទទីនិយម ឈ្លានពានវៀតណាម មកទឹកដីយើង”។ គាត់បានយល់ស្របជាមួយការណែនាំរបស់បក្សអំពាវនាវឲ្យមានការកម្ទេចខ្មាំង ដោយនិយាយថា៖ “មានតែការអនុវត្តមាគ៌ាបក្សទេ ដែលយើងអាចការពារប្រទេសរបស់យើង ទាំងខ្មាំងខាងក្នុង ហើយខ្មាំងមកពីខាងក្រៅ។ អង្គភាពរបស់យើងទូទាំងប្រទេសត្រូវតែបន្តឲ្យបានជាប្រចាំដើម្បីពង្រឹងការប្រុងប្រយ័ត្នបដិវត្តខ្ពស់”។ ចប់សេចក្តីដកស្រង់។

លោក លោកស្រីចៅក្រម នៅក្នុងមហាប្រជុំមហាជនមួយនៅពេលដែល ខៀវ សំផន អានសុន្ទរកថាគាត់បាននិយាយថា៖ “ដើម្បីលុបបំបាត់ឲ្យអស់ទាំងស្រុងនូវពួកភ្នាក់ងារវៀតណាម និង សេ.អ៊ី.អា ពីអង្គភាពរបស់យើងទាំងអស់ ហើយនិងពីទឹកដីរបស់កម្ពុជាឲ្យអស់ជារៀងរហូត”។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោក ខៀវ សំផន ថាតើគាត់យល់ស្របជាមួយខ្លឹមសារនៃសុន្ទរកថាដែលគាត់បានអាននោះដែរឬទេ? សូមដកស្រង់សម្តីគាត់ “ជាទូទៅ ខ្ញុំយល់ជាមួយខ្លឹមសារ ពីព្រោះវាជាឱសានវាទដែលវៀតណាមបានដាក់ឡើងនៅក្នុងខែឧសភា ឆ្នាំ១៩៧៦ ប៉ុន្តែបញ្ហាមួយចំនួន ខ្ញុំក៏មិនស្របដែរ ជាមួយអ្វីដែលនិយាយនៅក្នុងសុន្ទរកថាជាឧទាហរណ៍អំពីការលុបបំបាត់ចោលរូបិយបណ្ណ ដែលទុកឲ្យមានតែឧស្សាហកម្មខ្នាតតូច ហើយនិងសិប្បកម្មនោះ”។

[១៤:៣៧:១៣]

លោក លោកស្រីចៅក្រម ភស្តុតាងផ្សេងទៀត បានបង្ហាញអំពីការយល់ចូលរួមរបស់ជនជាប់ចោទ ហើយនិងការយល់ស្របរបស់គាត់ទៅនឹងនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកម្ទេចខ្មាំង ដូចដែលយើងបានឮពីសាក្សីមួយចំនួនក្នុងដំណាក់កាលនៃសវនាការនេះ ទាំង ខៀវ សំផន, ទាំង នួន ជា បានបើកវគ្គសិក្សាអប់រំនយោបាយជាទៀងទាត់ ដែលចំណុចមួយៗគាត់បានបំពាក់បំបន ហើយបានបង្រៀនកម្មាភិបាលបក្សស្តីពីនយោបាយ ហើយពិភាក្សាពីការចាប់ខ្លួន ហើយចម្លើយសារភាពអ្នកណាដែលគេចោទថា ជាជនក្បត់ ដូចជា កុយ ធួន។

លេខាស្រុកត្រាំកក់ គឺលោក ពេជ្រ ជឹម បានផ្តល់សក្ខីកម្មថា គឺលោក នួន ជា គាត់បានធ្វើ បានបើកវគ្គបណ្តុះបណ្តាលនយោបាយរយៈពេលមួយខែ ដើម្បីបង្រៀនដល់លេខាស្រុកនៅទូទាំងប្រទេស។ ហើយតាមរយៈការណែនាំរបស់ នួន ជា គឺធ្វើឲ្យគាត់ ព្រមទាំងលេខាស្រុកដទៃទៀត ដឹងថាតើខ្មាំងគឺជាអ្នកណា។ ទាំង នួន ជា, ទាំង ខៀវ សំផន បានចូលរួមនៅក្នុងផែនការឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយការចូលរួមនៅក្នុងការប្រជុំរបស់គណៈមជ្ឈិម ដែលនៅក្នុងការប្រជុំហ្នឹង គឺការធ្វើសម្រេចអំពីគោលនយោបាយបក្សពាក់ព័ន្ធទៅនឹងខ្មាំង។ ឧទាហរណ៍ដូចជា សេចក្តីសម្រេចថ្ងៃទី៣០ មីនា ៧៦ គឺជាសេចក្តីស្តីពីសិទ្ធិកម្ទេចទាំងខាងក្នុងជួរ និងខាងក្រៅជួរ។ ព្រមទាំងការសម្រេចខែមិថុនា ឆ្នាំ៧៨ ធ្វើការកែសម្រួលទៅលើគោលនយោបាយទាក់ទងទៅនឹងខ្មាំងយួន សេ.អ៊ី.អា និងកា.ហ្សេ.បេ។

លោក លោកស្រីចៅក្រម ខ្ញុំគិតថាឥឡូវនេះម៉ោងគឺម៉ោងពីរសាមសិបនាទីជាង តើគួរអនុញ្ញាតឲ្យខ្ញុំបន្តទៀត ឬក៏យើងឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោក វីល្លៀម ស្មីត។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មុននេះយើងបានពិភាក្សាអំពីភស្តុតាងដែលបង្ហាញថា នួន ជា ហើយនិងខៀវ សំផន បានឯកភាពគ្នា និងបានចូលរួមជាមួយគ្នាក្នុងគោលនយោបាយបក្សកុម្មុយនីស្ត កម្ពុជាក្នុងការកម្ទេចខ្មាំង។ ឥឡូវនេះខ្ញុំចង់ពិនិត្យបន្ថែមទៀតទៅលើភស្តុតាង ដើម្បីបង្ហាញចំណុច ទាំងអស់នេះនៅក្នុងការជំនុំជម្រះមួយនេះ។ លោក លោកស្រីចៅក្រមប្រហែលជាដឹងថា នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងការប្រជុំគណៈអចិន្ត្រៃយ៍ដែលនៅក្នុងការប្រជុំនេះ មេដឹកនាំបក្សបាន ពិភាក្សាអំពីបញ្ហាប្រជាជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងសម្រេចអំពីវិធានដែលត្រូវធ្វើប្រឆាំងនឹង មនុស្សទាំងអស់នេះ។ យើងបានឃើញកំណត់ហេតុការប្រជុំថ្ងៃទី០៨ មីនា ៧៦ ដែលចូលរួមដោយ នួន ជា, ខៀវ សំផន ដែលនៅក្នុងការប្រជុំហ្នឹងពិភាក្សាអំពីវិធានការទាក់ទងទៅនឹងខ្មាំងដែលត្រូវបានគេ រាយការណ៍ពីភូមិភាគឧត្តរតំបន់១០៣ និង១០៦។ យើងបានឃើញកំណត់ត្រាការប្រជុំថ្ងៃ១១ ថ្ងៃ១៣ មីនា ១៩៧៦ ដែលការប្រជុំហ្នឹងចូលរួមដោយ នួន ជា និង ខៀវ សំផន ហើយនិងការប្រជុំសម្រេចដើម្បី សម្លាប់សម្តេច នរោត្តម សីហនុ និងរាជបុត្រ រាជបុត្រីរបស់ព្រះអង្គ។

[១៥:០១:៤៥]

យើងបានស្តាប់សក្ខីកម្មរបស់ប្រធានស-២១ គឺលោក ឌុច ដែលបានជម្រាបថាតើ សុន សេន ជម្រាបគាត់យ៉ាងដូចម្តេចអំពីសេចក្តីសម្រេចចិត្តពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ឬក៏ការកម្ទេចមន្ត្រី ការ កម្ទេចកម្មាភិបាលជាន់ខ្ពស់តាមភូមិភាគ។ ហើយនៅក្នុងនោះគឺថាមានការប្រជុំមួយដែល ឌុច ត្រូវបាន គេប្រាប់ជាពិសេសថា ចូលរួមដោយ ខៀវ សំផន។

ខ្ញុំបានស្តាប់សក្ខីកម្មក៏ដូចជាភស្តុតាងជាច្រើនដែលបង្ហាញថា នួន ជា បានចូលរួមនៅក្នុងការ ចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់នៅមន្ទីរសន្តិសុខស-២១។ ពិតហើយថាគឺ ខៀវ សំផន ជាអ្នក ចុះហត្ថលេខាទៅលើការបង្គាប់ឲ្យមានការសម្លាប់មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ។

លោក លោកស្រីចៅក្រម ភស្តុតាងបានបង្ហាញហួសពីវិមតិសង្ស័យថា នួន ជា ហើយនិងខៀវ សំផន បានឯកភាពជាមួយហើយបានចូលរួមជួយទៅដល់ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការប្រើប្រាស់អំពើហិង្សាដើម្បីកម្ទេចបុគ្គលដែលគេចាត់ទុកថាជាខ្មាំងរបស់បក្ស។

[១៥:០២:៥៦]

ភស្តុតាងក៏បានបង្ហាញផងដែរថា ជនជាប់ចោទទាំងពីរដឹង ហើយបានឯកភាពជាមួយការកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ និងយោធាខ្មែរ សាធារណរដ្ឋខ្មែរ គឺជាក្រុមមួយដែលគេចាត់ទុកថាជាខ្មាំងរបស់បក្ស។ មាគ៌ាបក្សដែលត្រូវបានរៀបចំដោយ នួន ជា និងប៉ុល ពត ហើយត្រូវបានអនុម័តដោយសន្និបាតបក្សបានកំណត់យ៉ាងច្បាស់ថា ក្រុមនេះគឺជាក្រុមខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចដែលបានបញ្ជាក់នៅក្នុងសារាចររបស់បក្ស ហើយនិងទស្សនាវដ្ដីទង់បដិវត្តន៍។ ខ្ញុំសូមធ្វើការដកស្រង់៖ “នៅតែមានការបះបោរប្រឆាំងនៅក្នុងវណ្ណៈអភិជនរួមបញ្ចូលទាំងម្ចាស់ដី និងពួកអភិជនដូចជាប្រធានភូមិ ប្រធានមេស្រុក ចៅហ្វាយខេត្ត អ្នករដ្ឋការ នគរបាល និងទាហាន។ ការប្រឆាំងបះបោរនេះ គឺជាការប្រឆាំងបះបោរស្លាប់រស់ ហើយជាមូលដ្ឋានភាគច្រើនទាំងអស់នេះ ដែលការជំទាស់គឺជាអ្នករដ្ឋការ នគរបាល ទាហាន និងនិស្សិត”។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងខែតុលា ៧៥ ដល់ខែមករា ៧៦ គឺជាទស្សនាវដ្ដីទង់បដិវត្តន៍ដែលមានចំណងជើងថា “កម្មាភិបាលថ្នាក់ដឹកនាំរបស់បក្ស” គឺនៅក្នុងពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០ បានបញ្ឆេះឲ្យមានចលនាកសិករប្រឆាំងជាមួយនឹងចក្រពត្តិ ប្រឆាំងជាមួយពួកសក្តិភូមិ ម្ចាស់ដី ហើយនិងវណ្ណៈដឹកនាំដូចជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ ប៉ូលិស ទាហាន ប៉ូលិសសម្ងាត់ និងអ្នករដ្ឋការពន្ធដារជាដើម។ នៅឆ្នាំ១៩៦៩ នួន ជា និងមេដឹកនាំបក្សដទៃទៀតបានឯកភាពថា ពួកគេនឹងផ្ដោតការវាយប្រហារទៅលើផ្នែកប្រតិកិរិយាសេរីរបស់រដ្ឋាភិបាលដែលដឹកនាំឡើងដោយលោក លន់ នល់។

[១៥:០៥:០៧]

លោក លោកស្រីចៅក្រម គឺវាច្បាស់លាស់ណាស់ទៅហើយថា ហេតុអ្វីបានជាក្រុមហ្នឹងគឺជាគោលដៅនៃការសម្លាប់ជាទ្រង់ទ្រាយនៅទួលពោធិ៍ជ្រៃ ហើយនិងតំបន់ដទៃទៀត។ គឺថាពួកគេត្រូវបានកំណត់ជាពិសេសដោយមេដឹកនាំបក្សថាជាខ្មាំង។ ទោះបីជាអតីតទាហានបក្សកុម្មុយនីស្តកម្ពុជា និងកម្មាភិបាលមួយចំនួនមិនហាក់ដូចជាចង់និយាយអំពីការសម្លាប់ទាហាន លន់ នល់ ក៏ដោយ មានមនុស្សមួយចំនួនទៀតបានផ្ដល់សក្ខីកម្មយ៉ាងច្បាស់លាស់អំពីគោលនយោបាយ ដូចជា ឌុច ហើយនិង ពាន

ឃាន ដែលបានផ្តល់សក្ខីកម្មថា "ទាហាន លន់ នល់ ត្រូវបានគេចាត់ទុកថាជាខ្មាំងស្លាប់រស់ ហើយខ្ញុំបញ្ជាក់ប្រសិនបើគេត្រូវបានចាប់ខ្លួន ពួកគេត្រូវតែកម្ទេច"។

លោក លោកស្រីចៅក្រម ការដឹង ក៏ដូចជាការឯកភាពរបស់ ខៀវ សំផន ចំពោះគោលនយោបាយបក្សត្រូវបានបញ្ជាក់ច្បាស់ដោយការថ្លែងជាសាធារណៈ ដែលគាត់តែងតែចេញក្នុងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាចន្លោះឆ្នាំ៧២ ខែមេសា ឆ្នាំ១៩៧៥ ដែលនិយាយយោងដល់មេដឹកនាំខ្មែរសាធារណរដ្ឋខ្មែរថា ជាជនក្បត់ដែលត្រូវតែកម្ទេច។

នៅខែកញ្ញា ឆ្នាំ១៩៧២ គាត់បានចេញនូវសេចក្តីថ្លែងការណ៍មួយដែលស្នើសុំឲ្យប្រជាជនទាំងអស់ធ្វើការវាយប្រហារ ដើម្បីកម្ទេចពួកក្បត់សំខាន់ៗដូចជា"អាលន់ នល់, អាសិរិមតៈ, សឺង ង៉ុកថាញ់, អ៊ិន តាំ, លន់ នន់, ហង់ ធុនហាក់ និងអ្នកដែទៀត ព្រមទាំងកូនចៅរបស់ពួកវា ដោយប្រើប្រាស់នូវគ្រប់មធ្យោបាយទាំងអស់ ដូចជាកាំភ្លើងធំ កាំភ្លើងតូច កាំបិត ដំបង ដើម្បីកម្ទេចពួកអាក្បត់ទាំងអស់នេះ"។

[១៥:០៧:១១]

លោក លោកស្រីចៅក្រម ក្នុងឆ្នាំ១៩៧៣ ខៀវ សំផន បាននិយាយយោងទៅលើ លន់ នល់, សិរិមតៈ និង សឺង ង៉ុកថាញ់ ថាជាបនក្បត់ ហើយនិងជារបបអាក្បត់។ នៅថ្ងៃ១៥ មករា ឆ្នាំ១៩៧៥ គាត់បានបញ្ជាក់ថា កងទ័ពប្រជាជនរំដោះប្រជាជាតិកម្ពុជាបាន -- ខ្ញុំដកស្រង់៖ "បានកម្ទេចជិត២០កងវរសេនាតូចរបស់ខ្មាំង ហើយបានរំដោះប្រជាជនរាប់ម៉ឺននាក់ពីក្រញាំបិសាចរបស់អាក្បត់ លន់ នល់ និងបនរបស់ពួកវា"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

ហើយនៅចុងខែកុម្ភៈ ឆ្នាំ១៩៧៥ ខៀវ សំផន បានចុះហត្ថលេខាលើការបង្គាប់ ដែលបង្គាប់ឲ្យមានការកម្ទេចមន្ត្រីជាន់ខ្ពស់ប្រាំពីររូបរបស់របបសាធារណរដ្ឋខ្មែរ។ នៅក្នុងខ្សែវីដេអូដែលលោក លោកស្រីចៅក្រមបានពិនិត្យរួចទៅហើយហ្នឹង នួន ជា បានបញ្ជាក់អំពីដឹង ក៏ដូចជាការអនុម័តទៅលើការបង្គាប់នយោបាយ ដើម្បីកម្ទេចមេដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។

លោក លោកស្រីចៅក្រម កាលពីថ្ងៃសុក្រខ្ញុំបាននិយាយអំពីការលើកឡើងរបស់ អៀង សារី ដែលនិយាយថា "មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានធ្វើការសម្រេចដើម្បីពង្រីកវិសាលភាពនៃការកម្ទេចមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ គឺថាក្រោយថ្ងៃ១៧ មេសា ១៩៧៥ បន្តិច គឺនៅអំឡុងថ្ងៃ២០ ខែមេសា។ ដូច្នេះ ធ្វើដូច្នេះដើម្បីកុំឲ្យក្រុមនេះអាចងើបឡើងបះបោរ ហើយនិងប្រឆាំងជាមួយបដិវត្តន៍"។

[១៥:០៨:៥៥]

លោក លោកស្រីចៅក្រម នៅក្នុងចន្លោះថ្ងៃ១៧ និងថ្ងៃ២០ មេសា ឆ្នាំ១៩៧៥ នួន ជា និង ខៀវ សំផន ស្នាក់នៅជាមួយគ្នាជាមួយ ប៉ុល ពត, សុន សេន និងមេដឹកនាំភូមិភាគជាច្រើនទៀត ដែលនៅមូលដ្ឋានបក្សនៅក្នុងឃុំពាម ដើម្បីធ្វើការត្រួតពិនិត្យ និងបញ្ជាឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ នៅក្នុងឃុំពាម នៅក្នុងស្រុកកំពង់ត្រឡាចលើ គឺជាទីតាំងមួយដែលជនជាប់ចោទ និងមេដឹកនាំបក្សផងទៃទៀត គឺស្នាក់នៅប្រហែលជាបួនថ្ងៃ ទៅមួយសប្តាហ៍បន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥។ ហើយជនភៀសខ្លួនដែលគេជម្លៀសចេញខេត្តកំពង់ឆ្នាំង និងទីក្រុងភ្នំពេញត្រូវបានគេបំបែក ហើយទាហាន និងអ្នករដ្ឋការ លន់ នល់ ត្រូវបានគេយកចេញទៅសម្លាប់។

ដើម្បីបញ្ជាក់ឲ្យច្បាស់ លោក លោកស្រីចៅក្រម! ការសម្លាប់ជាទ្រង់ទ្រាយធំទៅលើមន្ត្រី និងរដ្ឋការរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើឡើងនៅក្នុងឃុំតែមួយជាមួយគ្នានឹងឃុំដែល ខៀវ សំផន, នួន ជា និង ប៉ុល ពត កំពុងស្នាក់នៅ នៅក្នុងរយៈបន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥។ គឺបានន័យថា ការសម្លាប់នេះ គឺកើតឡើងនៅក្បែរច្រមុះត្រចៀករបស់ពួកគេតែម្តង។ នេះគឺជាទីតាំងដែល នួន ជា បានទទួលស្គាល់ថាជាមូលដ្ឋានបក្សដ៏រឹងមាំមួយក្នុងចំណោមមូលដ្ឋានទាំងពីរនៅក្នុងប្រទេស។ ហើយនេះ គឺជាស្រុកមួយដែលនៅពេលក្រោយមកបានទទួលនូវទង់ក្រហមកិត្តិយសរបស់គណៈមជ្ឈិមដែលទទួលស្គាល់ថាជាស្រុកគំរូទាំងបីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:១០:៤៦]

ដូចកាលសម្លាប់នៅទួលពោធិជ្រៃដែរ។ ការកាប់ សម្លាប់អ្នករដ្ឋការនិងទាហានខ្មែរសាធារណៈនៅក្នុងឃុំពាម គឺមិនមែនធ្វើឡើងដោយកម្មាភិបាលក្រហម ឬក៏ស្តេចត្រាញ់ភូមិភាគស្វ័យតនោះឡើយ។ ការកាប់សម្លាប់នេះត្រូវបានរៀបចំគ្រប់គ្រងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយជាលទ្ធផលនៃគោលនយោបាយមជ្ឈិមសំដៅទៅលើក្រុមទាំងអស់នេះ។ ការចូលរួមរបស់ នួន ជា និងការឯកភាពជាមួយនឹងគោលនយោបាយរបស់បក្ស កំណត់មុខសញ្ញាមន្ត្រីរដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរត្រូវបានបង្ហាញផងដែរដោយការចាប់ខ្លួន និងការសម្លាប់ក្រុមមនុស្សបែបនេះជាច្រើននៅក្នុងពេលដំបូងៗនៃមន្ទីរស-២១។ ដូចដែល ឌុច បានផ្តល់សក្ខីកម្មអ៊ីចឹង មុនពេលដែល សុន សេន ចាកចេញទៅសមរភូមិនៅភូមិភាគបូព៌ា នួន ជា មានការទទួលខុសត្រូវពិនិត្យមើលជាទូទៅទៅលើ ស-២១។ នួន ជា ទទួលឯកសារពីស-២១ តាមរយៈ សុន សេន ហើយចេញបញ្ជាទៅឌុច តាមរយៈសុន សេន។ ដូចដែល ឌុច

បានផ្តល់សក្ខីកម្មនៅក្នុងពេលដំបូងៗនៃមន្ទីរស-២១ ក្រុមសំខាន់នៃអ្នកទោសដែលត្រូវបានគេបញ្ជូនទៅទីនោះ គឺអតីតអ្នករដ្ឋការនិងទាហានរបបលន់នល់ និងគ្រួសាររបស់ពួកគេ។ សក្ខីកម្មរបស់ឌុច ត្រូវបានអះអាងគាំទ្រផងដែរដោយបញ្ជីអ្នកទោសស-២១ មួយចំនួន។

[១៥:១២:២០]

បញ្ជីអ្នកទោសមួយបានកំណត់បង្ហាញថា មានមន្ត្រីរដ្ឋការ និងអតីតទាហានលន់នល់ ១៦២នាក់ រួមទាំងសាច់ញាតិរបស់ពួកគេដែលបានស្លាប់នៅមន្ទីរស-២១ នៅក្នុងខែមីនា ១៩៧៦ ដែលក្នុងនោះ ១៥៣នាក់ត្រូវបានកម្ទេច ឬក៏ត្រូវបានសម្លាប់ ហើយប្រាំបួននាក់ទៀតត្រូវបានសម្លាប់ដោយសារជំងឺ។ នៅក្នុងបញ្ជីនេះគឺមានសាច់ញាតិ១៣រូបរបស់ជនក្បត់មហាជនក្បត់ ឡុង បូរ៉េត។ ហើយនៅចុងបញ្ចប់គឺ១៥៩ គឺមានកត់ត្រាការកម្ទេចនៅថ្ងៃ៣០ មីនា ៧៦ ដែលបង្ហាញពីការកម្ទេច កូនទាំងបួនរបស់ ថាច់ ជា ដែលជាមន្ត្រីរបស់ក្រសួងអប់រំដែលយើងចាំតាមរយៈសក្ខីកម្មរបស់ ឡុង នរិន្ទ។ ឌុច បានផ្តល់សក្ខីកម្មថា ភរិយារបស់ ថាច់ ជា ក៏ត្រូវបានគេសម្លាប់នៅមន្ទីរស-២១ ផងដែរ ក្នុងលក្ខណៈដ៏គួរឲ្យភ័យរន្ធត់ គឺជាការសម្លាប់ដោយការធ្វើការវះកាត់ទាំងរស់។

ការដឹងហើយនិងឯកភាពរបស់ជនជាប់ចោទជាមួយគោលនយោបាយដែលកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ និងទាហានលន់នល់ ក៏ត្រូវបានបង្ហាញផងដែរដោយសារទូរលេខ ហើយនិងរបាយ-ការណ៍ដែលគេបញ្ជូនទៅ នួន ជា និងមន្ទីរ៨៧០នៅក្នុងអំឡុងរយៈពេលរបបកម្ពុជាប្រជាធិបតេយ្យដែលពណ៌នាអំពីការចាប់ខ្លួន និងការសម្លាប់បុគ្គលនៅក្នុងក្រុមនេះ។

[១៥:១៣:៥៩]

លោក លោកស្រីចៅក្រម សារទូរលេខដែលត្រូវបានទៅមេដឹកនាំមជ្ឈិមបក្សដោយលេខាភូមិភាគឧត្តរ គឺ កង ចាប ហៅ សែ គឺទាក់ទងទៅនឹងការបោសសម្អាតតំបន់១០៣ ព្រះវិហារដែលវាមានលក្ខណៈសំខាន់ចំពោះបញ្ហានេះផងដែរ។ ដូចដែល មាស វឿន បានផ្តល់សក្ខីកម្មនេះគឺជាតំបន់មួយដែល ខៀវ សំផន ហើយ នួន ជា មានការទទួលខុសត្រូវទៅលើ។ មាស វឿន បានផ្តល់សក្ខីកម្មថានៅពេលដែលគាត់ត្រូវបានគេតែងតាំងជាប្រធានតំបន់១០៣ គាត់ត្រូវបានគេណែនាំឲ្យរាយការណ៍ទៅ ខៀវ សំផន។

លោក លោកស្រីចៅក្រមក៏បានឮភស្តុតាងផងដែរថា ខៀវ សំផន មានឥទ្ធិពលព្រមទាំងមានអំណាចក្នុងការជួយដល់ការដោះលែងសាច់ញាតិរបស់គាត់ចេញពីមន្ទីរសន្តិសុខ ភូមិភាគឧត្តរ។ ហើយ នួន ជា គឺជាបុគ្គលដែលធ្វើដំណើរជាមួយ កង ចាប ទៅមន្ទីរតំបន់១០៣ នៅចុងឆ្នាំ១៩៧៧ ដើម្បីធ្វើការ

ប្រកាសជាផ្លូវការអំពីការបង្កើតភូមិភាគឧត្តរថ្មី ហើយនិងតែងតាំង កង ចាប គឺជាលេខានៃភូមិភាគឧត្តរថ្មីនេះ។ លោក លោកស្រីចៅក្រម! ជាមួយនឹងទំនាក់ទំនងទាំងអស់នេះក៏ដូចជាសារទូរលេខ និងរបាយការណ៍ដែលត្រូវបានបញ្ជូនដោយ កង ចាប ទៅមជ្ឈិមបក្សពាកព័ន្ធទៅនឹងតំបន់ទាំងអស់នេះគឺវាមានសារៈសំខាន់បំផុត ទាក់ទងទៅនឹងជនជាប់ចោទទាំងពីររូបនេះ។ ឯកសារនេះគឺជាសារទូរលេខមកពីលេខាភូមិភាគឧត្តរ កង ចាប ហៅ សែ ទៅមន្ទីរ -- ទៅគណៈកម្មាធិការ៨៧០ ចុះថ្ងៃទី០៨ ខែ៩ ១៩៧៧ ដែលចម្លងជូន អ៊ំនួន ហើយនិងមន្ទីរ។ ហើយផ្តល់នូវរបាយការណ៍ដូចតទៅនេះ ចំពោះមេដឹកនាំមជ្ឈិមបក្សទាក់ទងទៅនឹងស្ថានភាពខ្មាំងផ្ទៃក្នុង។ ខ្ញុំសូមធ្វើការដកស្រង់៖

“នៅតាមមូលដ្ឋាន នៅតាមមន្ទីរ ក្រសួង និងយោធា យើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ តាមការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្តន៍ ទាំងតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការ និងប៉ូលិស ទាហានចាស់ យើងរកឃើញជាបន្តបន្ទាប់” សូមបញ្ចប់ការដកស្រង់។

[១៥:១៦:១៨]

លោក លោកស្រីចៅក្រមប្រហែលជាប្រាំមួយខែក្រោយមក គឺនៅថ្ងៃទី១៦ មីនា ១៩៧៨ លេខាតំបន់ សែ បានរាយការណ៍ទៅ នួន ជា ហើយនិងមេដឹកនាំមជ្ឈិមបក្សដទៃទៀតទាក់ទងទៅនឹងស្ថានភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ ខ្ញុំសូមធ្វើការដកស្រង់៖ “នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើង ខ្មាំងទាំងអស់នេះធ្វើការទាក់ទងជាមួយអតីតប៉ូលិសទាហាន និងរដ្ឋាភិបាលពួកគេចាត់ទុកខ្លួនគេថា ជាប្រជាជនថ្មី។ បន្ទាប់ពីពួកគេប្រឆាំងពួកគេ យើងដឹងពួកគេច្បាស់លាស់ ហើយយើងធ្វើការបោសសម្អាតជាប្រព័ន្ធ។ ឥឡូវនេះ ប៉ូលិស ទាហាន និងអ្នករដ្ឋការមួយចំនួនបានរត់គេចបន្ទាប់ពីប្រជាជនជាង ២០នាក់ត្រូវបានបោសសម្អាត។ សកម្មភាពបន្ថែមទៀតត្រូវធ្វើដើម្បីចាប់ខ្លួនប្រជាជនទាំងអស់នេះ” សូមបញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រម នេះជាសារទូរលេខទី២ ដែលត្រូវបានបញ្ជូនដោយ កង ចាប បន្ទាប់ពីគាត់បានជួបជាមួយ នួន ជា នៅព្រះវិហារ។ ហើយពួកគេទាំងពីរនាក់បានចាប់ផ្តើមការប្រជុំជាមួយនឹងកម្មាភិបាលតំបន់១០៣ ដែលនៅក្នុងពេលប្រជុំនោះគេពិភាក្សាអំពីបញ្ហាខ្មាំងផ្ទៃក្នុង។ ការពិតគឺថា កង ចាប គាត់បន្តការបោសសម្អាតមន្ត្រីរដ្ឋការ ប៉ូលិស ទាហាន បន្ទាប់ពីការជួបជាមួយ នួន ជា ហើយរាយការណ៍បញ្ហានេះយ៉ាងទូលាយទៅកាន់ នួន ជា ហើយនិងមេដឹកនាំបក្សដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ ដែលការណ៍ទាំងអស់នេះបង្ហាញអំពីអត្ថិភាពនៃផែនការជារួមដែលបង្កើតឡើងដោយមេដឹកនាំបក្សកុម្មុយ

 

នីស្តនៅក្នុងទីក្រុងភ្នំពេញ ហើយនិងខាងភូមិភាគដើម្បីកំណត់ទៅលើគោលដៅទាំងអស់នេះ ក្រុមទាំងអស់នេះ។

[១៥:១៨:០៩]

ប្រហែលជាលោក លោកស្រីចៅក្រម នៅចងចាំអំពីបញ្ជារបស់ ពិន នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ៧៧ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្ស ដែលបង្ហាញអំពីការបោសសម្អាតមន្ត្រី លន់ នល់ ហើយនិងមានករណីមួយទៀតគឺបោសសម្អាតមន្ត្រីរបស់ពួកគេ។ ហើយយើងអាចពិនិត្យមើលទៅលើដីកា -- ទៅលើការបង្គាប់បញ្ជាដែលធ្វើឡើងនៅពេលនោះ ហើយយើងនឹងអាចឃើញថា ការបង្គាប់បញ្ជាក៏ដូចជាចម្លើយទាំងអស់នេះគឺគោលនយោបាយរបស់បក្ស។

លោក លោកស្រីចៅក្រម ភស្តុតាងទាំងអស់នេះ គឺបង្ហាញហួសពីវិមតិសង្ស័យថា នួន ជា និង ខៀវ សំផន បានដឹងហើយឯកភាព ព្រមទាំងចូលរួមនៅក្នុងផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ និងយោធារបស់ លន់ នល់ ដើម្បីយកទៅធ្វើទារុណកម្ម និងសម្លាប់។

លោក លោកស្រីចៅក្រម ដើម្បីបញ្ចប់បញ្ហាទាំងអស់នេះមុននឹងខ្ញុំផ្ទេរវេទិកាជូនទៅសហការីរបស់ខ្ញុំ ខ្ញុំសូមធ្វើការលើកឡើងនូវបញ្ហាមួយចំនួន។

[១៥:១៩:៣៤]

មុននឹងបញ្ចប់ ខ្ញុំសូមជម្រាបថា លោក នួន ជា ហើយនិង ខៀវ សំផន មានការទទួលខុសត្រូវរឿងព្រហ្មទណ្ឌបទឧក្រិដ្ឋទាំងអស់ដែលគាត់បានទទួលការរងការចោទប្រកាន់៖ ទី១ ការជម្លៀសដោយបង្ខំ ប្រជាជនចេញពីទីក្រុងភ្នំពេញដែលចាប់ផ្តើមឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទី២ ការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ បន្ទាប់ពី អំពីការផ្តាក់នៃរបបនោះ។ ទី៣ ការជម្លៀសលើកទី២ ដែលចាប់ផ្តើមឡើងនៅខែកញ្ញា ឆ្នាំ១៩៧៥។ ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋទាំងអស់នេះដោយសារខ្លួនមានសមាជិក ហើយនិងការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ។ សហកម្មឧក្រិដ្ឋកម្មរួមនេះចាប់ផ្តើមឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបន្តរហូតដល់ខែមករា ឆ្នាំ ១៩៧៩ ដែលជនជាប់ចោទបានធ្លាក់ពីអំណាច។ សមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមនេះរៀបបញ្ចូលទាំង ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, អៀង សារី ហើយនិងសមាជិកផ្សេងទៀត នៃមជ្ឈិមបក្ស លេខានៃភូមិភាគបក្សកុម្មុយនីស្តកម្ពុជា មេបញ្ជាការនៃកងពលបក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃសហាឧក្រិដ្ឋកម្មរួមនេះ គឺប្រើនូវជាចារី ជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ហើយនិងសមាជិកនៃនយោ-

បាយរបស់បក្សដើម្បីប្រព្រឹត្តបទឧក្រិដ្ឋរបស់ខ្លួន។ នៅស្នូលនៃសហឧក្រិដ្ឋកម្មរួមនេះ គឺជាការធ្វើទុក្ខបុកម្នេញ ហើយការធ្វើអំពើឧក្រិដ្ឋទៅលើជនស៊ីវិលក្រុង និងប្រជាជនកម្ពុជា ដែលកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជាដែលគេហៅថា ប្រជាជនថ្មី ឬក៏អ្នក១៧មេសា។ ជនជាប់ចោទត្រូវបានគាបសង្កត់ដាក់ទណ្ឌកម្មទូទាំងប្រទេសនៅក្នុងរបបជាការធ្វើបាបជាទូទៅ។ ជារបបដែលបង្កើតឡើងនៅក្នុងកិច្ចផ្សេងៗ ដែលធ្វើឡើងដដែលៗ ហើយជាបន្តការជម្លៀសជាបន្តបន្ទាប់នូវប្រជាជនទីប្រជុំជន ហើយនិងសហឧក្រិដ្ឋកម្មរួមដាក់បញ្ចូលទាំងការកាប់សម្លាប់ក្រៅផ្លូវច្បាប់នៃអតីតយោធា ហើយនិងរដ្ឋាភិបាលពីមុន នៅក្នុងកន្លែងផ្សេងៗទៀត នៅទួលពោធិ៍ជ្រៃ។

[១៥:២២:១៩]

ភស្តុតាងបានបង្ហាញថា ក្នុងឋានៈជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម នួន ជា និង ខៀវ សំផន មានចេតនាគ្រប់បទឧក្រិដ្ឋកម្មទាំងអស់ដែលខ្លួនរងការចោទប្រកាន់ ជាបទឧក្រិដ្ឋកម្មដែលមិនអាចជៀសវាង ដែលថានឹងមានផលនៅក្នុងសហឧក្រិដ្ឋកម្មរួមនោះឯង។ គេបានអនុវត្តដោយមានការរៀបរយតាមលំដាប់លំដោយ មានរចនាសម្ព័ន្ធអំណាច ហើយដឹកនាំដោយមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ បទឧក្រិដ្ឋទាំងអស់ត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃជាប្រព័ន្ធ ហើយនៃការវាយប្រហារជាទូទៅ ប្រឆាំងនឹងប្រជាជនក្រុងនៃកម្ពុជា។ ការវាយប្រហារផ្អែកទៅលើមូលដ្ឋាននៃនយោបាយ ដោយហេតុថា សមាជិកសហឧក្រិដ្ឋកម្មរួម ដែលមានទាំង ខៀវ សំផន ហើយនិង នួន ជា។ តម្រង់យកប្រជាជនស៊ីវិលក្រុងថាជាខ្មាំងរបស់ខ្លួន។

ប្រព័ន្ធដែលបង្កើតជាស្ថាប័ន ការបំបែកប្រជាជនចាស់ និងប្រជាជនថ្មី ត្រូវបានរៀបចំដើម្បីអនុវត្តនូវការធ្វើទុក្ខបុកម្នេញលើប្រជាជនទូទាំងប្រទេស។ លោក នួន ជា ហើយនិង ខៀវ សំផន ជាអ្នកទទួលខុសត្រូវបទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្ត ក្នុងគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម។ ពួកគេមានពិរុទ្ធភាព គេបង្កើតជាសហឧក្រិដ្ឋកម្ម ដោយសារគាត់ជាសមាជិក ហើយគេជាអ្នកចូលរួមទាំងស្រុងទៅលើកម្មវិធីនេះ។ ខ្ញុំនឹងបញ្ជាក់ក្នុងរូបភាពសង្ខេបនៃការចូលរួមរបស់គាត់ទៅក្នុងសកម្មភាពនេះ។

[១៥:២៤:០១]

១) ការចូលរួមក្នុងការបង្កើត និងការអនុវត្តនូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសំដៅយកខ្មាំងដែលគេសង្ស័យ មានសាធារណរដ្ឋខ្មែរ ដាក់គុក ការធ្វើទារុណកម្ម ហើយនិងការសម្លាប់ក្រៅផ្លូវច្បាប់។ ទី២) ការចូលរួមនៅក្នុងសេចក្ដីសម្រេចជាសមូហភាពរបស់មជ្ឈិមបក្ស ដើម្បី

ជម្លៀសដោយបង្ខំប្រជាជនចេញពីភ្នំពេញ នៅក្នុងកិច្ចប្រជុំនៅខែមិថុនា ឆ្នាំ១៩៧៤ ហើយនិងខែមេសា ឆ្នាំ១៩៧៥។ ទី៣) ចេញនូវការណែនាំដល់កងពលខ្មែរក្រហមទាំងអស់ដើម្បីឲ្យជម្លៀសទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ នៅក្នុងកិច្ចប្រជុំ។ នៅទី៤) ការបញ្ជា ការណែនាំ ការបង្រៀននូវកម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ហើយនិងពួកយោធា ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ រៀបបញ្ចូលទាំងការជម្លៀសប្រជាជនចេញពីទីក្រុង ការដាក់ឲ្យទៅជាទាសករនូវជនស៊ីវិល ហើយនិងស្វែងរក ហើយនិងសម្លាប់នូវអ្នកណាដែលគេយល់ថាខ្មាំង។ ៥) លើកទឹកចិត្ត ហើយនិងយល់ស្របលើការប្រព្រឹត្តបទឧក្រិដ្ឋនៅតាមរយៈតាមការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា រៀនទង់បដិវត្តន៍ សេចក្ដីណែនាំផ្សេងៗ។ ទី៦) លើកទឹកចិត្ត ហើយនិងផ្ដល់ការគាំទ្រការប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈបទសុន្ទរកថា ហើយនិងសេចក្ដីប្រកាសសាធារណៈ។ ប្រកាសឲ្យមានការសម្លាប់ខ្មាំង ហើយការប្រើនូវរបបទាសកម្ម ហើយនិងការពលកម្មដោយបង្ខំ។ ទី៧) ការតាមដាន ការឃ្លាំមើលនៅលើកម្មាភិបាលស៊ីវិល យោធាទាំងអស់ដែលពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋក្នុងរយៈកាលរបបប្រជុំជាទៀងទាត់នៅក្នុងរាយការណ៍ទៅមជ្ឈិមបក្ស ហើយនិងពិនិត្យមើលរបាយការណ៍លម្អិតមកពីភូមិភាគ ហើយនិងស្ថាប័នស្វ័យត។ ៨) ការចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចរបស់មជ្ឈិមបក្សរវាងខែឧសភា និងខែកញ្ញា ១៩៧៥ ដើម្បីបន្តការដាក់ឲ្យទៅជាទាសករ និងប្រជាជនជាយក្រុង ហើយការប្រើអំពើអមនុស្សធម៌។ ហើយជាពិសេសបញ្ជូនប្រជាជន៥០០.០០០នាក់ពីភូមិភាគផ្សេងៗទៅភូមិភាគពាយ័ព្យ ហើយនិងទៅភូមិភាគឧត្តរ។ ទី៩) សមស្របសម្រួល ហើយនិងការតាមដានការជម្លៀសបង្ខំទី២។ ទី១០) ការប្រកាន់នូវប្រព័ន្ធការដាក់ឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ហើយនិងអំពើអមនុស្សធម៌ ការជម្លៀសដោយបង្ខំ កំណត់ដោយខ្មាំងរហូតដល់ចុងបញ្ចប់ដែលថែងនៅក្នុងដីកាដំណោះស្រាយ។ ហើយទី១១) ការហាមឃាត់មិនឲ្យប្រជាជនដែលដាក់ជាទាសករមិនឲ្យត្រឡប់មកផ្ទះវិញ។ ១២) ការប្រកាសដោយខ្លែងបន្លំដែលរៀបចំដើម្បីលាក់លៀមបទឧក្រិដ្ឋ ដើម្បីឲ្យខ្លួនលាក់កំបាំងក្នុងឋានៈជាចារីនៃបទឧក្រិដ្ឋ។

[១៥:២៧:០៣]

លោក លោកស្រីចៅក្រម យើងសូមជម្រាបថាចំណុចទី២ ទម្រង់ទី២ ជាទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមនេះ គឺជាលក្ខខណ្ឌដែលបំពេញ ដែលជនជាប់ចោទបានបំពេញទៅតាមលក្ខខណ្ឌច្បាប់នៃការចោទប្រកាន់នេះ គឺជានិយមន័យទាក់ទងទៅនឹងការបន្តអំពើហិង្សា ដែលតម្រង់ទៅរកជនស៊ីវិលនោះឯង។ ទោះជាយ៉ាងណាក្ដី បើសិនជាលោក លោកស្រីចៅក្រម ត្រូវពិនិត្យអនុវត្តទម្រង់ទី១នៃ

សហឧក្រិដ្ឋកម្មរួមនោះ យើងសូមជម្រាបថា ភស្តុតាងបំពេញទៅតាមទម្រង់នៃការទទួលខុសត្រូវនោះដែរ គឺបទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្តជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមដែលជនជាប់ចោទទាំងពីរមានចេតនា។ លើសពីនេះទៅទៀត ជំនួសទៅនឹងការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមនោះ ជនជាប់ចោទក៏មានការទទួលខុសត្រូវពីការធ្វើការផែនការ ការញុះញង់ ការសម្រួល ការប្រព្រឹត្តបទល្មើសនៅក្នុងបទឧក្រិដ្ឋដែលបានចោទប្រកាន់។ ទម្រង់នៃការទទួលខុសត្រូវនេះក៏បានមានភស្តុតាងហួសពីវិមតិសង្ស័យដូចដែលខ្ញុំបានរៀបរាប់នៅក្នុងភស្តុតាងដែលបានជម្រាបជូន។ ហើយម្យ៉ាងទៀត ជនជាប់ចោទមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌអំពីបទឧក្រិដ្ឋក្នុងឋានៈខ្លួនឯងជាឋានៈលើ ជាចារីផ្ទាល់ ដែលខ្លួនមិនបានដាក់ទោសអ្នកក្រោមដែលខ្លួនដឹងថាបទឧក្រិដ្ឋបានប្រព្រឹត្ត ឬក៏បម្រុងនឹងប្រព្រឹត្ត។

[១៥:២៨:៣៥]

ភស្តុតាងបានបង្ហាញហួសពីវិមតិសង្ស័យថា ក្នុងឋានៈជាសមាជិកនៃមជ្ឈិមបក្សទាំង នួន ជា ហើយនិង ខៀវ សំផន បានបញ្ជាដោយមានប្រសិទ្ធភាព ហើយត្រួតត្រាទៅលើពួកចារីទាំងអស់នោះ។ ពួកគាត់មានសមត្ថភាពក្នុងការចាត់វិធានការដាក់ទោសដល់ចារីនោះបាន។ ពួកគាត់បានដឹងថាបទឧក្រិដ្ឋបម្រុងនឹងកើតឡើង ប៉ុន្តែគាត់មិនបានទប់ស្កាត់ទេ។ ពួកគាត់មិនបានចាត់វិធានការ ដើម្បីទប់ស្កាត់ ឬក៏ដាក់ទោសអ្នកប្រព្រឹត្តនោះទេ។ តាមពិត ពួកគាត់ប្រើអំណាចនិងតួនាទីរបស់គាត់ដើម្បីលាក់កំបាំងចារីទាំងអស់នោះមិនឱ្យទទួលទោសបាន។

លោក លោកស្រីចៅក្រម សហសេវិករបស់ខ្ញុំ លោកជំទាវ ជា លាង នឹងលើកឡើងទាក់ទងទៅនឹងការស្នើសុំឱ្យតុលារដាក់ទោស។ ហើយខ្ញុំសូមអរគុណចំពោះឱកាសដែលខ្ញុំបានឡើងថ្លែងនេះបាទ។

[១៥:២៩:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅលោកជំទាវ ជា លាង សហព្រះរាជអាជ្ញាជាតិធ្វើសេចក្តីសន្និដ្ឋានលើបញ្ចប់ចុងក្រោយអំពីការស្នើសុំឱ្យអង្គជំនុំជម្រះប្រកាសទោសចំពោះជនចោទ។ អង្គជំនុំជម្រះបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ឡើងមកចូលរួមស្តាប់នូវសេចក្តីសន្និដ្ឋានអំពីទោស និងស្ថាននានាជុំវិញការស្នើសុំប្រកាសទោសចំពោះជនជាប់ចោទនៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់។

*(ជនជាប់ចោទ នួន ជា ចូលក្នុងបន្ទប់សវនាការ)*

[១៥:៣៥:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមជម្រាបជូនលោក នួន ជា ថា នៅក្នុងអំឡុងពេលនៃសេចក្តីសន្និដ្ឋានចុងក្រោយស្តីពីសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះប្រកាសទោសចំពោះលោក ចំពោះជនជាប់ចោទទាំងពីររូប ហើយនិងស្ថាននានាពាក់ព័ន្ធនឹងសំណើសុំនេះ លោកមានវត្តមាននៅក្នុងការស្តាប់នូវសេចក្តីសន្និដ្ឋានចុងក្រោយនេះ ហើយក្រោយពេលចប់លោក នួន ជា អាចវិលត្រឡប់ទៅពេលណាក៏បានពីព្រោះតុលាការនៅមានកិច្ចនីតិវិធីខ្លះទៀតនៅក្រោយពេលដែលសហព្រះរាជអាជ្ញាបញ្ចប់នូវសេចក្តីសន្និដ្ឋានកិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

ហើយអនុរក្សមន្ទីរឃុំឃាំងប្រសិនបើមានសំណើសុំក្រោយ ពេលចប់សេចក្តីសន្និដ្ឋានកិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា គឺអនុរក្សមន្ទីរឃុំឃាំងអាចនាំគាត់ត្រឡប់ទៅកាន់បន្ទប់ឃុំខាងក្រោមបានហើយ មិនរង់ចាំរហូតដល់អង្គជំនុំជម្រះបញ្ចប់នូវសវនាការរសៀលនេះទេ ពីព្រោះអង្គជំនុំជម្រះនៅមានកិច្ចនីតិវិធីបន្តបន្ទិចបន្តួចទៀតចុងក្រោយ។

បាទជាបន្តទៅនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកជំទាវសហព្រះរាជអាជ្ញាជាតិដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋាន។

[១៥:៣៧:១២]

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជនទាំងអស់ ហើយនិងអង្គសវនាការទាំងមូលនោះ។ ដូចដែលលោក លោកស្រីចៅក្រមបានស្តាប់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញារួចមកហើយ ដោយយោងទៅតាមដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចលើកយកតែអង្គហេតុដែលបានចោទប្រកាន់ដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺអង្គហេតុពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ និងដំណាក់កាលទី២ និងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ ហើយដែលអង្គហេតុទាំងនេះពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការធ្វើឱ្យមនុស្សឃាត ការសម្លាប់រង្គាលការធ្វើទុក្ខបុកម្នេញ ការជម្លៀស និងការបាត់ខ្លួនដោយបង្ខំ សហព្រះរាជអាជ្ញាយល់ឃើញថា ជនជាប់ចោទ នួន ជា និងខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះដែលបានប្រព្រឹត្តឡើងស្ថិតក្នុង

វិសាលភាពនៃការជំនុំជម្រះរឿងក្តី ០០២/០១នេះ។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ជាអ្នកដាក់ចេញនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហើយគោលនយោបាយទាំងប្រាំនេះរួមមាន៖ ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសា ទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងទី២ ពីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត។ ទី២) ការបង្កើត និងការទាញយកផលប្រយោជន៍តាមរយៈសហករណ៍ និងតាមការដ្ឋាន។ ការអប់រំ សមាសភាពមិនល្អ (ចំណុចទី៣) និងការកម្ទេចខ្មាំងដែលត្រូវបានរកឃើញទាំងនៅក្នុង និងក្រៅជួរបក្ស។ ទី៤) ការចេញនូវវិធានការជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានាដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃសាធារណរដ្ឋខ្មែរ។ រួមទាំងមន្ត្រីរាជការអតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។ ចំណុចទី៥) ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។

[១៥:៤០:១៣]

ក្នុងចំណោមគោលនយោបាយទាំងប្រាំនេះ ដូចបានរៀបរាប់ហ្នឹង មានគោលនយោបាយចំនួនពីរត្រូវបានអនុវត្តបានសម្រេច ដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ ស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះនេះ។ គឺការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់មន្ត្រីរដ្ឋការស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ។ សហព្រះអាជ្ញាយល់ឃើញថា តាមរយៈឯកសារភស្តុតាងដូចជា៖ តេឡេក្រាម វីដេអូ សក្ខីកម្មសាក្សី និងអ្នកជំនាញបានបង្ហាញច្បាស់ថា ជនជាប់ចោទទាំងពីរនាក់ពិតជាបានដឹង និងបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលផែនការនេះបានបណ្តាលឲ្យប្រជាជនរាប់លាននាក់ស្លាប់ក្នុងរបប ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។

យើងខ្ញុំមិនជ្រើសរើសយកវិធីសម្លាប់ ដើម្បីយកមកធ្វើការដាក់ទណ្ឌកម្មចំពោះជនជាប់ចោទទាំងពីរនាក់នេះឡើយ។ យើងខ្ញុំមិនស្នើសុំឲ្យលោក លោកស្រីចៅក្រមថ្កោលទោសជនជាប់ចោទ និងក្រុមគ្រួសារទាំងមូលរបស់ពួកគេ ដោយសារការបណ្តេញចេញពួកគេឲ្យចាកចេញពីលំនៅដ្ឋាន ដោយបង្ខំឲ្យធ្វើដំណើរដោយថ្មើរជើងនៅក្រោមកម្តៅព្រះអាទិត្យដ៏ក្តៅហែងរាប់ថ្ងៃ ដោយទុកចោលនៅក្នុងទីព្រៃ និងវាលរហោស្ថាន ដោយបង្ខំឲ្យធ្វើការយ៉ាងលំបាក និងបង្អត់អាហារដូចក្នុងប្រព័ន្ធទាសភាពដែលមានអង្គការចាត់តាំងមួយ ឬឲ្យទទួលរងនូវការរំលោភបំពាន និងវាយដំដោយឲ្យទទួលរងនូវការភូតកុហក និងបោកប្រាស់ដោយឲ្យគេចាប់ចង និងបាញ់សម្លាប់ចោល ដោយឲ្យឈរមើលកូនរបស់ខ្លួនត្រូវ

គេចាប់ហែកជាពីរ និងបោកខ្ទប់ទៅនឹងគល់ឈើ និងដោយទុកឲ្យមនុស្សជាទីស្រឡាញ់របស់ពួកគេស្លាប់ ដោយបាត់សេចក្ដីថ្លៃថ្នូរ ហើយសូម្បីតែរៀបចំពិធីបុណ្យសពតាមប្រពៃណីក៏គេមិនអនុញ្ញាតឲ្យដែរ។ ដូចដែលជនជាប់ចោទទាំងពីររូប និងសហការីរបស់ពួកគេបានប្រព្រឹត្តមកលើជនរងគ្រោះ។

[១៥:៤២:៤៨]

នៅថ្ងៃនេះក្នុងនាមប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិ យើងខ្ញុំចង់ឃើញការផ្ដល់ជូនយុត្តិធម៌ពីលោក លោកស្រីចៅក្រម ដល់ជនរងគ្រោះទាំងអស់ដែលបានស្លាប់បាត់បង់ជីវិត និងអ្នកដែលនៅរស់រានមានជីវិតដល់សព្វថ្ងៃ ដែលបានឆ្លងកាត់របបដ៏សែនឃោរឃៅ ក្រោមការដឹកនាំរបស់ជនជាប់ចោទទាំងពីរនាក់នេះ និងក្រោមការដឹកនាំរបស់មេដឹកនាំផ្សេងៗទៀត។ យើងខ្ញុំស្នើឲ្យតុលាការធ្វើការផ្ដន្ទាទោសជនជាប់ចោទទាំងពីរនេះទៅតាមច្បាប់។

លោក លោកស្រីចៅក្រម! ជនជាប់ចោទ នួន ជា និង ខៀវ សំផន មិនបានសម្ដែងការសោកស្ដាយ ឬវិប្បដិសារីឡើយចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន មិនបានសហការជាមួយតុលាការ ដើម្បីបង្ហាញការពិត ដើម្បីផ្ដល់ភាពយុត្តិធម៌ជូនជនរងគ្រោះឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ចំពោះជនជាប់ចោទ នួន ជា បានសម្ដែងនូវការខឹងសម្បាតាមរយៈការប្រើពាក្យសម្ដី "កុំយកឈើពុកមកឆ្លាក់ជាព្រះ" នៅក្នុងពេលអង្គជំនុំជម្រះស្ដាប់សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ចំណែកឯ លោកជនជាប់ចោទ ខៀវ សំផន វិញ បាននិយាយថា "អ្វីដែលបានកន្លងផុតហើយ ទុកឲ្យកន្លងផុតទៅចុះ"។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ផ្ដល់ចម្លើយភូតភរ មិនទទួលស្គាល់ឯកសារភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងដាក់ពិភាក្សាដេញដោល ដោយអះអាងថា "ការជម្លៀសគឺដើម្បីដោះស្រាយវិបត្តិស្បៀង និងដើម្បីបញ្ចៀសពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក"។ ជនជាប់ចោទ ខៀវ សំផន អះអាងថា ខ្លួនមិនដែលមានទំនាក់ទំនងជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ប៉ុល ពត និង នួន ជា ជាដើម។ នេះជាអ្វីដែលផ្ទុយស្រឡះពីសក្ខីកម្មរបស់សាក្សីជាច្រើន និងផ្ទុយពីអ្វីដែលគាត់បានផ្ដល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានពីមុនៗមក។ នៅក្នុងវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទី១នេះ យើងខ្ញុំមិនឃើញមានមូលដ្ឋានណាមួយដើម្បីបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំងពីរនាក់នេះឡើយ។

[១៥:៤៥:៤០]

លោក លោកស្រីចៅក្រម! នៅថ្ងៃនេះ អ្វីដែលជនរងគ្រោះបានទទួលរងទុក្ខវេទនាឥតគណនា

ដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលយើងទាំងអស់គ្នា ព្រមទាំងសហគមន៍អន្តរជាតិ ទន្ទឹងរង់ចាំអស់រយៈពេល៣៨ឆ្នាំ ៦ខែ និង៤ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥មក ដែលនៅពេលនោះប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភាពខ្មៅងងឹត និងភ័យខ្លាចអស់រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។ ហើយផលប៉ះពាល់ដែលសល់ពីរបបនេះ នៅតែមាននៅឡើយរហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះពន្លឺយុត្តិធម៌ និងខិតជិតមកដល់ ហើយដែលរកឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន ជាអ្នកទទួលខុសត្រូវ ហើយដែលជនជាប់ចោទទាំងពីររូបនេះ នឹកស្មានមិនដល់។ ដូច្នេះ ឃើញថាមានភស្តុតាងគ្រប់គ្រាន់ចំពោះមុខ លោក លោកស្រីចៅក្រម និងយោងតាមខ្លឹមសារនៃមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស នួន ជា និង ខៀវ សំផន ដោយដាក់ពន្ធនាគារអស់មួយជីវិត ដែលជាទោសមួយគត់សមស្របតាមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទដ្ឋានអន្តរជាតិ។ សូមអរគុណ។

[១៥:៤៧:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកជំទាវសហព្រះរាជអាជ្ញាជាតិ។

ពេលវេលាសម្រាប់សហព្រះរាជអាជ្ញាសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដល់ពេលនេះ គឺត្រូវបានចប់តាមពេលវេលាដែលបានគ្រោងទុករួចហើយ។ ប៉ុន្តែអង្គជំនុំជម្រះនៅមានបញ្ហាមួយទៀត កាលពីព្រឹកមិញ ដោយអង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា នៅក្នុងសវនាការព្រឹកមិញនេះ គឺមានវត្តមានសហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូបឈ្មោះ អេឡូឌី ឌុយឡាក់ ដែលមិនទាន់បានទទួលស្គាល់ដោយអង្គជំនុំជម្រះនៅឡើយ។ ហើយដោយអនុលោមវិធាន ២២(២)(ក)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ជាសហព្រះរាជអាជ្ញា -- អ៎! ជាសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅក្នុងសវនាការនេះ ហើយមេធាវីរូបនោះគឺមិនទាន់បានទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូងពីពេលមុនៗមក។ សូមអញ្ជើញលោក ពេជ អង្គ!

[១៥:៤៩:០២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រីចៅក្រម ភាគី និងសាធារណជន។ បាទ ខ្ញុំបាទ ពេជ អង្គ សូមការអធ្យាស្រ័យផងដែរ ចំពោះការមកយឺតយ៉ាវព្រឹកមិញនេះ។

ថ្ងៃនេះ មានវត្តមានរបស់មេធាវីបរទេសថ្មីម្នាក់ ជនជាតិបារាំង គឺលោកស្រីមេធាវី អេឡូឌី ឌុយឡាក់។ លោកស្រីជាសមាជិកគណៈមេធាវីនៃទីក្រុងបារីស ប្រទេសបារាំង តាំងពីឆ្នាំ២០០៥ រហូតបច្ចុប្បន្ន។ និងបានចុះឈ្មោះ និងកំពុងប្រតិបត្តិជាមេធាវីបរទេសនៅសាំងហ្កាពួរ នាពេលបច្ចុប្បន្នផងដែរ ចាប់ពីឆ្នាំ២០១០។ លោកស្រីជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមយុត្តិធម៌សម្រាប់កម្ពុជា *យុសស្ទីស ពូរឡឺខាំបូដស៍(តាមសូរស័ព្ទ)* និងតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំរូប រួមជាមួយនឹងមេធាវីជាតិរបស់លោកស្រី គឺលោកមេធាវី សំ សុគង់។ លោកស្រីត្រូវបានការឯកភាពដោយគណៈមេធាវី ឲ្យចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេសរបស់គណៈមេធាវីសម្រាប់តំណាងកូនក្ដី នៅចំពោះមុខ អ.វ.ត.ក នៅថ្ងៃទី២៩ ខែសីហា ២០១២។ បន្ទាប់មកបានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញនៅថ្ងៃទី២១ មករា ឆ្នាំ២០១៣។ ដូច្នេះ សូមលោកប្រធាន លោក លោកស្រីចៅក្រមជ្រាប និងទទួលស្គាល់មេធាវីបរទេសរូបនេះ ដើម្បីឲ្យគាត់មានសិទ្ធិបំពេញកិច្ចនៃនីតិវិធីដូចមេធាវីដទៃទៀតចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ករណី០០២ នេះ។ សូមអរគុណលោកប្រធាន។

[១៥:៥០:៣៦]

**ប្រធានអង្គជំនុំ៖**

លោកស្រី អេឡូ ឌីឌុយឡាក់ នាពេលនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ដោយអនុលោមតាមវិធាន២២ អនុវិធាន២ ចំណុច(ក)នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយការទទួលស្គាល់នេះគឺលោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតដែរ។ អង្គុយចុះ!

បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២២ ខែតុលា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅថ្ងៃស្អែកនេះអង្គជំនុំនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនលើសំណុំរឿង០០២/០១។ ហេតុដូច្នេះ សូមភាគី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមឲ្យមុនម៉ោងបានកំណត់នេះ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់មកចូលរួមសវនាការនេះវិញនៅថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួនព្រឹក ដោយលោក ខៀវ សំផន ឲ្យនាំគាត់មកចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥២ នាទី)*